# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៥ លេខ ៥ ខែ ឧសភា

ព.ស. ២៥០៥ គ.ស. ១៩៦៣

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា នឹងអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

– អំពីរឿងអសោក (វិបារណកថា) លោក ផេង.ជ្រីវ រៀបរៀង (តចប់) . . ៤៥០
– រឿងព្រះមហាសីលវរាជ (ពាក្យកាព្យ) លោក ហេង-សមអាន រៀបរៀង (តចប់). . ៤៥៨
– ព្រះអភិធម្មបិដក (គម្ពីរព្រះមហាបដ្ឋាន) លោក ប៊ូ-ប៉ូ ប្រែរៀបរៀង (ត). . . ៤៧៥
– មធុរសវាហិណី សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សា ប្រែរៀបរៀង (ត) . . ៤៨៣
– មហោសថជាតក (តមក) . . . . . . . . . . ៤៩១

*ផ្នែកអក្សរសាស្ត្រ*

– កិត្តិយសនឹងសុភមង្គល (វិបារណកថា) លោក ផេង - ជ្រីវ រៀបរៀង (តចប់) . . ៥០៧
– អក្សរសាស្ត្រខ្មែរ សិលាចារឹក ជយ - នន្ទ ស្រាវជ្រាវ ដោយ ឱ - ជាម. . . ៥១៥
– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះតេជព្រះគុណ ប៉ាង - ខាត់ រៀបរៀង (ត) . . ៥២៦
– រឿងសាមកុក លោកឧកញ៉ា នូ - កន ប្រែរៀបរៀង (ត) . . . . ៥២៨
– ល្បើកឃ្លាហ្សុងតែន លោកផេង - ជ្រីវ ប្រែពីភាសាបារាំង (ត) . . . . ៥៣៥
– រឿងព្រេងចិន លោក ប៉ាយ - ប៊ុក ប្រែពីភាសាបារាំង (ត) . . . . ៥៤១
- ការជំនុំជំរះដោយយុត្តិធម៌នៃតុលាការអន្តរជាតិពីរឿងក្តីព្រះវិហាររបស់ខ្មែរនៅក្រុងឡាហេ (តចប់) ៥៤៥
- បៀប - ក្រុក - ព្រះកក្កុសន្ធោ លោក ផល - ទិត្យ រៀបរៀង . . . , ៥៤៩

*ផ្នែកកំណត់ទីនប្រវត្តិការណ៍*

– អំពីការតាំងមន្ត្រីសង្ឃ . . , . . . . . . . ៥៥៩

---

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៛០០



ព្រះវិហារវត្តពោធិវាល នៅមាត់ស្ទឹងសង្កែ ត្រើយខាងកើតទល់មុខផ្សារបាត់ដំបងជាព្រះវិហារល្អជាង ព្រះវិហារដទៃក្នុងខេត្ត

# ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការលាមក | ឲ្យធ្វើល្អទៅ |
| ឲ្យជុសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា |

ប.ព.

## វិចារណកថា

# អំពីរឿងអសោក

លោក ដេង - ជ្រីវ រៀបរៀង

(តមក)

បណ្ឌិតប្រកបដោយសេចក្ដីព្យាយាម ត្រូវតែទុនលំពោនគោរពស្រមណ៍ទាំងឡាយ ទឹងធ្វើនូវកុសលកម្មជាប្រយោជន៍នៃអាត្មា នេះហើយដែលគេហៅថាបាននូវវត្ថុដែលមានសភាពទៀងទាត់ ៗ ហេតុអ្វីក៏ខ្ញុំពោលរៀបរាប់នូវរឿងនេះ ? ព្រោះរូបកាយនេះប្រព្រឹត្តទៅយ៉ាងរហ័សដូចជាផ្គុំពពុះទឹក ដូចផ្កាខ្យាច់ ដូចជាដើមចេក រូបកាយមិនមានគ្រាប់ធំមាំមួនទេ ៗ ប៉ុន្តែ បើរូបកាយមិនស្ថិតថេរនេះ ធ្វើកុសលកម្ម ត្រូវតាំងនៅអស់មួយរយកប្ប មានសភាពមាំមួនដូចជាភ្នំព្រះសុមេរុ នឹងដូចជាមហាប្រឹថពី ៗ ដូច្នេះ បណ្ឌិតត្រូវតែស្វែងរកឲ្យបាននូវវត្ថុមិនបែកធ្លាយ មិនវិនាស » ៗ

---

(១) ក្នុងគម្ពីរបាលីពុទ្ធសាសនាខាងថេរវាទៈ អាការៈ មានតែ ៣២

៣) អំពីពានបុនក្រោយបង្អស់នៃព្រះបាទអសោក គម្ពីរមហាវង្ស ពោលថា «ផ្លែស្រម៉មួយចំហៀង» សេចក្តីប្រែព្រះតេជព្រះគុណ គឹម-អាន ថា« ផ្លែកន្ទួតព្រៃមួយចំហៀង» សេចក្តីនៃលោក ហ៊ុយ-ប៊ែរ ថា» ផ្លែស្វាយមួយចំហៀង» ។

ចំពោះផ្លែស្រម៉ នឹងផ្លែកន្ទួតព្រៃ ឃើញថាមានការស្រដៀងគ្នា អាចផ្លាស់ប្តូរគ្នាបាន ព្រោះស្រម៉ នឹងកន្ទួតព្រៃ សុទ្ធសឹងជារុក្ខជាតិដុះនៅក្នុងព្រៃដូចគ្នា ហើយសណ្ឋានផ្លែក៏ប្រហែលគ្នាទៀត គ្រាន់តែរស់ជាតិផ្សេងគ្នាបន្តិច គឺមួយចត់ល្វីង មួយជូរល្វីង គឺថាក៏មិនសូវជាប្លែកគ្នាឆ្ងាយៗ ដូច្នេះ ខ្ញុំសន្និដ្ឋានថា គេអាចកន្តច្រឡំយកមួយជាមួយបាន ។ តែឯផ្លែស្វាយវិញ មានការផ្សេងគ្នាយ៉ាងធំរវាងផ្លែស្រម៉នឹងកន្ទួតព្រៃ គឺទ្រង់ទ្រាយក៏ខុស ទំហំក៏ខុស ហើយរស់ជាតិក៏ខុសទៀត ។ ហើយមួយយ៉ាងទៀត ផ្លែពីរខាងដើម ជារុក្ខជាតិដុះនៅតែក្នុងព្រៃ ស្វាយជារុក្ខជាតិស្រុកៗ អំពីរឿងនេះ យើងគួរពិចារណាដែរ ថាហេតុអ្វីក៏ផ្សេងគ្នាខ្លាំងម្ល៉េះ? ។

ចំណែករឿងដែលថា តើខាងណាសមជាង : ខាងកន្ទួតព្រៃនឹងស្រម៉ ឬខាងផ្លែស្វាយ? សូមអ្នកអានទាំងឡាយជួយវិនិច្ឆ័យផង ។

សេចក្តីក្នុងមហាវង្សនឹងសេចក្តីប្រែរបស់ព្រះតេជព្រះគុណ គឹម-អាន ថា ព្រះបាទអសោក ទ្រង់សព្វព្រះរាជហឫទ័យចំណាយព្រះរាជទ្រព្យ បូជាចំពោះព្រះពុទ្ធសាសនាឲ្យបានមួយរយកោដិដំឡឹងមាស ព្រោះទ្រង់បាន

ប្រាប់ថា អនាថបិណ្ឌិកសេដ្ឋីបានចំណាយទ្រព្យធ្វើទានក្នុងព្រះពុទ្ធសាសនា អស់មួយរយកោដិដំឡឹងមាស ចំណែកព្រះអង្គ ដោយបូករួមទាំងអស់ទៅ ទើបទឹងបានតែ ៩៦ កោដិដំឡឹងមាស ។ ដើម្បីចំណាយបង្គ្រប់ជា ១ រយកោដិ ទើបទ្រង់ព្រះបញ្ញាឲ្យនាយឃ្លាំងយកព្រះរាជទ្រព្យចំណាយឲ្យបានគ្រប់ដូចព្រះរាជបំណង តែជាអកុសលក្នុងឱកាសនោះព្រះបាទអសោកទ្រង់ប្រឈួនធ្ងន់ ៗ ដោយខ្លាចអំណោះអត់ពីព្រះអង្គទៅព្រះរាជាអង្គក្រោយឡើងទ្រង់រាជ្យ ត្រូវខ្វះខាតកោតទ្រព្យក្នុងការកសាងរដ្ឋ ទើបមាននាម៉ឺនខ្លះដែលមិនសូវជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានទៅក្រាបទូលចំពោះព្រះអង្គម្ចាស់សម្បទី ជាព្រះរាជតាយាទថា បើទ្រង់បណ្តោយឲ្យព្រះអយ្យកោ ចេះតែចំណាយព្រះរាជទ្រព្យដូច្នេះ ព្រះអង្គម្ចាស់ដែលត្រូវទ្រង់រាជ្យក្នុងពេលក្រោយ នឹងខ្សត់ខ្សោយដោយកោតទ្រព្យជាប្រាកដ ៗ ព្រះអង្គម្ចាស់សម្បទី ដោយទ្រង់យល់ឃើញផង ទើបបញ្ជាដល់នាយឃ្លាំងថា ត្រូវឈប់យកទ្រព្យក្នុងព្រះឃ្លាំងថ្វាយចំពោះព្រះ-អយ្យកោទៀត ហើយក៏ឲ្យរាជចំរើយកតែផ្លែស្រម៉ឬកន្ទួតព្រៃមួយចំហៀងទៅថ្វាយដល់ព្រះអយ្យកោ ។ ឯសេចក្តីរបស់លោក ហ៊ុយ-ប៊ែរ មិនឃើញមានពោលរៀបរាប់ដូចខាងលើនេះទេ គ្រាន់តែដាក់សេចក្តីថាព្រះបាទអសោកទ្រង់ប្រឈួនខ្លាំង ពួកអាមាត្យមុខមន្ត្រី ដោយយល់ឃើញថាទ្រង់ចំណាយព្រះរាជទ្រព្យអស់ច្រើនហើយ ក៏យកតែផ្លែស្វាយមួយចំហៀង

ទៅថ្វាយតែប៉ុណ្ណោះ ។

អំពីរឿងថ្វាយផ្លែឈើតែមួយចំហៀងនេះ គម្ពីរមហាវង្ស សេចក្តីប្រែគឹម-ឝាន និងសេចក្តីប្រែរបស់លោកហ៊ុយ-ប៊ែរ មិនឃើញមានចង្អុលប្រាប់ហេតុសោះ ។ បើថ្វាយផ្លែទាំងមូលចំពោះព្រះបាទអសោកទៅ តើពានឹងខាតប៉ុន្មាន ហេតុដូចម្តេចក៏ថ្វាយតែផ្លែមួយចំហៀង? យោបល់ផ្ទាល់របស់ខ្ញុំថាជាបញ្ហាមួយដែរ ដើម្បីបញ្ជាក់ថ្វាយចំពោះព្រះបាទអសោក គឺថាឲ្យព្រះអង្គជ្រាបអំពីអំណាចរបស់ទ្រង់ ។ ឥឡូវនេះអំណាចរបស់ព្រះអង្គប្រេះឆាហើយ ពុំមែននៅគង់វង់មាំទាំដូចផ្លែឈើទាំងមូលនោះទេ ជាអំណាចដែលត្រូវគេបំបែកបានហើយ គឺថានឹងត្រូវវិនាសក្នុងពេលដ៏ខ្លីណាមួយជាពុំខាន ។

ខ្ញុំសូមលើកយកសេចក្តីរបស់លោកហ៊ុយប៊ែរមកផ្សាយជូនដូចតទៅ :

ព្រះបាទអសោកជាធម្មិករាជ ទ្រង់ប្រឈួនយ៉ាងធ្ងន់ ។ ព្រះរាជទ្រព្យទាំងអស់របស់ព្រះអង្គ ទ្រង់បានថ្វាយជាទានដល់សង្គមពុទ្ធសាសនា ។ ទ្រង់បង្គាប់ឲ្យមន្ត្រីយកទ្រព្យផ្សេងដទៃទៀតមកថ្វាយដល់ព្រះអង្គទៀត តែមន្ត្រីទាំងនោះឈប់ត្រូវការថ្វាយដល់ព្រះអង្គ ។ ទ្រង់បានទទួលផ្លែស្វាយមួយចំហៀង ។ ទ្រង់សព្វព្រះរាជហឫទ័យប្រគេនផ្លែស្វាយមួយចំហៀងនេះដល់ព្រះសង្ឃ ។ ទ្រង់ប្រជុំអស់នាម៉ឺនមុខមន្ត្រីរបស់ព្រះអង្គហើយមានព្រះបន្ទូលថា : ថ្ងៃនេះ តើអ្នកណាជាស្តេច ហើយត្រូវគេគោរពបញ្ជា

របស់អ្នកណា ?» ។ នាម៉ឺនទាំងអស់ក្រាបបង្គំទូលថា : «មានតែព្រះមហារាជនេះហើយដែលគ្រប់គ្រងព្រះរាជាណាចក្រនៃព្រះអង្គ ក្នុងជម្ពូទ្វីបទាំងមូល គេត្រូវគោរពព្រះបញ្ញារបស់ព្រះអង្គ» ។ ឱកាសនោះ ព្រះបាទអសោកទ្រង់សំដែងនូវគាថាដូចតទៅ : អស់លោកពោលថា ខ្ញុំជាព្រះមហាក្សត្រ ហើយថាគេត្រូវគោរពបញ្ជាការខ្ញុំ ។ អស់លោកពោលយ៉ាងនេះ គឺដើម្បីបញ្ចោរខ្ញុំទេ ។ សំដីដែលអស់លោកនិយាយគឺជាពាក្យកុហក ។ អំណាចខ្ញុំស្លាប់ហើយ ខ្ញុំអស់សមត្ថភាពទឹងទាត់ការអ្វីហើយ ។ មានតែផ្លែឈើមួយចំហៀងនេះទេ ដែលខ្ញុំត្រូវជាធំបណ្ដាច់លើ ។ អំណាចជាវត្ថុជាទីស្អប់ខ្ពើម ។ ឱ គួរឲ្យអនិច្ចា ! អំណាចនេះត្រូវគេមើលងាយក្រៃពេក ! អំណាចប្រៀបដូចជាទន្លេដែលហូរធ្លាក់ចុះពីកំពូលភ្នំឥតបង្អង់ ។ ខ្លួនខ្ញុំជាព្រះចៅកជាធិពជនៃមនុស្សទាំងឡាយ ទុគ្គតភាពស្រាប់តែមកដល់ខ្ញុំភ្លាមដោយមិនដឹងខ្លួន ទុគ្គតភាពដែលមនុស្សទាំងអស់ត្រូវតែភ័យខ្លាច បានមកប៉ះលើរូបខ្ញុំមួយរំពេច ។

កាលបើពោលគាថានេះហើយ ទ្រង់សែក្រឡើងថា : « ព្រះឱវាទនៃព្រះលោកនាថពេញហៅត្រូវពិត មិនមែនខុសត្រង់ណាឡើយ ! » ។ រួចទ្រង់សំដែងនូវគាថាតទៅទៀតថា :

សុភមង្គលដ៏យ៉ាងភ្លឺត្រចះត្រចង់អស្ចារ្យ នឹងត្រូវរលាយរលុំធ្លាក់ចុះនៅទីបំផុត ។ សុភមង្គលនិងសេចក្ដីរីករាយនៃមនុស្សលោក នឹងត្រូវតែ

រលាយរលំចុះមិនខាន គឺជារឿងដែលមនុស្សទាំងអស់តែងភ័យខ្លាច ។ ព្រះឱវាទនៃព្រះគោតម ពិតជាប្រកបដោយសារៈ ។ ក្នុងថ្ងៃទាំងឡាយកន្លងផុតទៅ កាលណាខ្ញុំយល់ច្បាស់ក្នុងចិត្តថាត្រូវបញ្ជាអ្វីហើយ ខ្ញុំគ្រាន់តែបញ្ចេញនូវបញ្ជាការនោះ សំដីខ្ញុំ មិនមែនទៅកើតទៅឥតប្រយោជន៍ឡើយ ។ សូម្បីតែយក្សនឹងទេវតាក៏ត្រូវទទួលនូវបញ្ជាការរបស់ខ្ញុំ ។ គ្រប់ទីទាំងអស់ ពួកខាងក្នុងសមុទ្រទាំងបួន អ្នកណាដែលបានឮបញ្ជាការរបស់ខ្ញុំហើយ ត្រូវតែយកទៅអនុវត្ត គ្មាននរណាម្នាក់ហ៊ានរឹងទទឹងឡើយ ។ ដូច្នេះ កាលណាទន្លេហូរទៅប៉ះនឹងភ្នំដ៏ធំ ទឹកបែកពពុះហូរប្រាលមកក្រោយ ។ ខ្ញុំរលាយរលំចុះដូចជាភ្នំមួយដ៏ធំ គេរឹងទទឹងនឹងខ្ញុំ គេមិនយកបញ្ជាការខ្ញុំទៅអនុវត្ត ។ ពីដើមមិនមានអ្នកណាម្នាក់ហ៊ានទប់នឹងបញ្ជាការរបស់ខ្ញុំ ។ មិនដែលមានការច្របូកច្របល់សោះឡើយ ខ្ញុំបានបំបាក់បំបបពួកខ្មាំងគ្មានសល់ ខ្ញុំបានបើកស្វេតច្ឆត្ររបស់ខ្ញុំលាតសន្ធឹងគ្របលើមហាប្រថពីទាំងមូល គ្មាននរណាអាចរឹងទទឹងនឹងខ្ញុំបាន ប្រុស ស្រី ធំ តូច គ្មាននរណាដែលមិនគោរពខ្ញុំ ។ ហើយប្រសិនបើលោកជាមានអ្នកណាហ៊ានរឹងទទឹងនឹងបញ្ជាការខ្ញុំ ខ្ញុំត្រូវតែបង្ក្រាបដោយអាវុធ ។ អ្នកណាដែលមានទុក្ខ ខ្ញុំត្រូវលួងលោមព្រមទាំងជួយផង ខ្ញុំសង្គ្រោះរហូតដល់អ្នកជម្ងឺនិងអ្នកទីទ័លក្រ ឥតរើសមុខ ។ តែឥឡូវ សុភមង្គលរបស់ខ្ញុំដល់នូវទីបំផុតហើយ ទុគ្គតភាពមកដល់មួយរំពេច ហើយខ្ញុំជា

មនុស្សប្រកបដោយសេចក្ដីទុក្ខវេទនា ។ ប្រសិនបើខ្ញុំជាស្ដេចអសោកពិតប្រាកដមែន ហេតុអ្វីក៏ខ្ញុំធ្លាក់ក្នុងសេចក្ដីទុក្ខវេទនាយ៉ាងនេះ? ខ្លួនខ្ញុំប្រៀបដូចជាដើមអសោកដែលត្រូវគេកាត់ឫសចោល ហើយគេកាប់រំលុំទៀត: ផ្កា ស្លឹកនឹងមែកទាំងឡាយ ស្ងួតក្រៀមអស់ហើយ ។ រិទ្ធិអំណាចប្រៀបដូចជាការស្រម័យ (យល់សប្តិ) រិទ្ធិអំណាចនេះមិនស្ថិតថេរទេ ។

រួចព្រះបាទអសោក ទ្រង់ទតឆ្ពោះទៅលោកគ្រូពេទ្យដែលអង្គុយនៅខាងព្រះអង្គ ហើយទ្រង់ស្រែកថា: ត្រូវអៀនខ្មាសអំពីរិទ្ធិអំណាចដែលតាំងនៅតែមួយស្របក់ ដូចជាផ្គរបន្ទោរដែលវិនាសភ្លាមនៅពេលដែលវាបញ្ចេញឲ្យឃើញពន្លឺ ដូចជាស្លឹកត្រចៀកដំរី ដែលបក់ជានិច្ច មិនដែលឈប់នៅនឹង ដូចជាអណ្ដាតពស់ ដែលលៀនក្លិបក្លែតឥតឈប់ឈរ ដូចជាទឹកសន្សើមពេលព្រឹក ដែលស្ងួតបាត់ នៅពេលដែលប្រទះនឹងព្រះអាទិត្យ! ពីដើមខ្ញុំបានឮគេពោលវាចាដូច្នេះថា:

គេអាចគ្រប់គ្រងទ្រព្យសម្បត្តិបានដោយកម្រណាស់ ទ្រព្យសម្បត្តិរមែងវិនហួត ហើយមិនស្ថិតនៅអស់កាលជាយូរអង្វែងឡើយ ។ នេះហើយ ដែលបណ្ឌិតគួរតែយល់ឲ្យជាក់ច្បាស់ ខ្លួនមិនត្រូវរាយឫកក្រអឺតសង្ហា នឹងរស់នៅដោយគ្មានក្ដីព្រួយបារម្ភឡើយ ។ ក្នុងជីវិតបច្ចុប្បន្នរហូតដល់ជីវិតអនាគត ត្រូវតែស្វែងរកនូវអត្ថប្រយោជន៍ ប្រកបដោយ

សារៈ ។ កាលបើគេមានសម្បត្តិច្រើន គេត្រូវរក្សាទុកសេចក្តីប្រណែន ព្រោះការរមែងវិនាសទៅវិញ ដោយហេតុមួយរយប្រការ ។ អ្នកមានទ្រព្យ កាលនៅរស់ ប្រៀបដូចជាសត្វពស់ដែលមានដំណើរបត់បែនក្រវិកក្រវក់ ។ ជនណាដែលមានការពិចារណាក្នុងពេលដែលគេនៅពេញកំឡាំងយ៉ាងស្វាហាប់ ត្រូវតែប្រញាប់ប្រញាល់ស្វែងរកធម៌ឲ្យមានក្នុងអាត្មា ។ កាលណាគេមានជម្ងឺ គេមានព្រះធម៌ក្នុងខ្លួនស្រេច ព្រោះគេមិនទៀងថានឹងនៅរស់តទៅឡើយ ។ ចំណែកគ្រួសារនឹងបងប្អូនទាំងឡាយ កាលបើយល់ច្បាស់ថា អ្នកឯងមុខជាស្លាប់ហើយ អ្នកឯងមានសម្បត្តិយ៉ាងណាក៏ដោយ អ្នកឯងមិនអាចយកសម្បត្តិនោះមកធ្វើទានតាមចិត្តខ្លួនបានឡើយ ។ ទ្រព្យសម្បត្តិទាំងឡាយដែលគេរកបាននៅពេលនៃសេចក្តីរុងរឿង កាលណាបើគេបានជួបនឹងបុញ្ញក្ខេត្រហើយ គួរគប្បីតែចំណាយធ្វើជាទានយ៉ាងរហ័ស „ កាលណាអ្នកនៅមានកំឡាំង មុនពេលដែលជម្ងឺមិនទាន់មកញាំញី ត្រូវអ្នកធ្វើកុសលកម្មជានិច្ច ព្រោះទ្រព្យសម្បត្តិតែងតែនាំមកជាមួយនូវសេចក្តីទុក្ខ ។ កាលណាអ្នកឯងជិតស្លាប់ ឪពុកម្តាយ ប្រពន្ធនឹងកូន រមែងតែជំទាស់ចំពោះហេតុដែលអ្នកត្រូវការបង់យកទ្រព្យធ្វើទាន ទោះបីទ្រព្យនោះជារបស់អ្នកក៏អ្នកមិនអាចយកទៅចំណាយជាទានបានដូចបំណងឡើយ ។ នៅពេលដែលអ្នកធ្លាក់ក្នុងសភាពជាទម្ងន់ហើយ អ្នកមិនអាចធ្វើអ្វីតាមអំពើចិត្តបានទេ” ។

# រឿងព្រះមហាសីលវរាជ

(ពាក្យកាព្យ)

លោក ហោង - សំអាង រៀបរៀង

ចាកមហាសីលវជាតក ឯកនិបាត អហឹងសវគ្គ

---

ទូលព្រះបង្គំសូមលានា » ព្រះចមយោធាស្តេចទ្រង់ត្រាស់
« អ្នកនាំអាមាត្យទៅទុកផ្ទះ កុំឲ្យសល់ខ្វះទោះតូច - ធំ ៗ
ហើយអ្នកនាំយើងទៅឲ្យដល់ ព្រះចៅកោសលក្នុងបទុំ »
យក្ខនាំអាមាត្យទាំងតូច - ធំ ដល់ផ្ទះជួបជុំក្រុមគ្រួសារ ៗ
ហើយយក្ខមកយាងព្រះសីលវៈ ចូលក្នុងដំណាក់ទីសយនា
ព្រះចៅកោសលជាបច្ចា- មិត្រនៃក្សត្រាក្នុងយប់នោះ ៗ
ស្តេចហូតព្រះខ័នកាន់យ៉ាងខ្ជន់ ភ្ជង់ចុងបំត្រង់កហើយគោះ
ព្រះចៅកោសលមុខដូចផេះ ភិតភ័យផឹតពោះញ័រញាក់ប្រាណ ៗ
ក្រោកឡើងក្រាបថ្វាយបង្គំថា « បពិត្រក្សត្រាព្រះទ័យក្សាន្ត
ព្រះអង្គយាងចូលដល់សយដ្ឋាន តើយាងមកបានដោយសារអ្វី ? » ៗ
ព្រះមហាសីលវៈប្រាប់សព្វគ្រប់ ពីដើមដល់ចប់ផុតសេចក្តី
ព្រះចៅកោសលភ្ញាក់ស្មារតី ត្រេកអរមេត្រីស្មោះចំពោះ ៗ
ទូលថា « បពិត្រក្សត្រឧត្តម ទូលព្រះបង្គំមនុស្សមានទោស
សូមសម្តេចម្ចាស់ទ្រង់សន្តោស អត់ទោសដល់ទូលបង្គំផង ៗ

ទូលព្រះបង្គំអន្ធពាលខ្លៅ    ចិត្តខ្លៅអាក្រក់ល្អក់សៅហ្មង
មិនដឹងព្រះគុណព្រះអង្គផង    គុណធ្ងន់កន្លងឥតឧបមា ។
សូម្បីតែយក្ខកក្ខឡជាតិ    ស៊ីខ្មោចសត្វធាតុជាអាហារ
គង់ដឹង-ស្គាល់គុណព្រះករុណា    ទ្រទ្រង់សីលាស្អាតផូរផង់ ។
ចាប់ពីថ្ងៃនេះទូលបង្គំ    លែងចងគំនុំនឹងព្រះអង្គ
សូមតាមបំរើដោយស្មោះត្រង់    ចំពោះព្រះអង្គមួយជីវិត ។
ទូលហើយក៏ថ្វាយពរជបន្ទំ    ទៅព្រះអង្គផ្ទុំយ៉ាងស្លាលស្និទ្ធ
ព្រះចៅកោសលស្តេចអន់ឫទ្ធិ    ផ្ទំទាបជាងពិតប្រាកដច្បាស់ ។
ព្រឹកឡើងព្រះចៅដែនកោសល    ប្រជុំរេហ៍ពលហើយទ្រង់ត្រាស់
ថា « អ្នកទាំងឡាយស្តាប់ឲ្យច្បាស់ ព្រះចៅជាម្ចាស់ដែនកាសី ។
ព្រះនាមមហាសីលវៈ    ស្តេចទ្រង់សច្ចៈនឹងខន្តី
ស្តេចរក្សាសីលជាប្រក្រតី    សីលប្រាំ ប្រាំបីស្អាតផូរផង់ ។
ៈហេតុនេះអស់លោកអ្នកទាំងឡាយ ចូរថ្វាយជីវិតនឹងព្រះអង្គ
ថ្វាយខ្លួនបំរើដោយស្មោះត្រង់    ផ្ចិតផ្ចង់គោរពព្រះចក្រី » ។
ប្រកាសរួចស្រេចស្តេចកោសល    តម្កល់អញ្ជលីឱនសិរសី
សូមខមាទោសព្រះចក្រី    នៅមុខមន្ត្រីពលសេនា ។
ខមាទោសស្រេចស្តេចកោសល    បំរើគន់គាល់ព្រះចេស្តា
ជាមួយមន្ត្រីពលសេនា    ហើយក្រាបទូលថា « ព្រះមហាកជ ។

ចាប់តាំងពីថ្ងៃនេះតទៅ បើមានសត្រូវចិត្តគោងកាច
ចូលមកបៀតបៀនទាំងអំណាច ទូលបង្គំអាចហ៊ានធានា ។
ទទួលភាសាចេញតតាំង កំចាត់ពួកខ្មាំងគ្រប់វេលា
មិនឲ្យចូលដល់ព្រំភាក មិនឲ្យពជាទ្រង់កង្វល់ » ។
ព្រះមហាសីលវៈទ្រង់ត្រាស់ថា « អរគុណហើយណាស្តេចកោសល
តើទ្រង់ធ្លាប់ឮឬធ្លាប់ស្គាល់ លោកនាយពលចម្ប.វិចិត្រ ។
ជាមេទ័ពធំដែនកាសី ក្លាខ្លាំងល្បាញល្បីកបដោយឫទ្ធិ
ទោះយក្សទោះគ្រុឌខ្លាចវិចិត្រ មិនហ៊ានតយុទ្ធតបេស្តា ។
បើខ្ញុំជាមនុស្សល្មោភចង់បាន ដែនទាំងប៉ុន្មានក្នុងលោកា
ប្រើតែមេទ័ពចេញតវ៉ា ស្តេចក្នុងលោកាថ្វាយភាករ ។
ស្តេចគ្រប់រដ្ឋដែលមានឫទ្ធិក្រៃ ខ្លបខ្លាចថ្វៃដៃមិនហ៊ានត
ខ្ញុំមិនត្រូវការសួយភាករ ជាមេបង្កអសន្តិសុខ ។
បពិត្រព្រះចៅដែនកោសល សូមទ្រង់កុំឆ្ងល់ឲ្យវិតក្ក
បើធ្វើឲ្យគេរងទោសទុក្ខ យើងមិនបានសុខយូរប៉ុន្មាន ។
ព្រោះរដ្ឋទាំងអស់ទោះតូច-ធំ តែងតែខិតខំប្រឹងប្រែងប្រាណ
សួយប្រទេសគេខានតែបាន រុងរឿងចម្រើនថានគ្រប់ ៗ គ្នា ។
ជាតិណាធ្លាក់ចុះអំណាចគេ ជាតិនោះចាំគ្នាមិនរេក
រកឧបាយកលគ្រប់វេលា ដកខ្លួនពីទាស់គេនោះបាន ។

បើហេតុដូច្នោះព្រះចមចៅ    ទ្រង់ចង់គង់នៅជាសុខសាន្ត
សូមទ្រង់កុំធ្វើឲ្យរំខាន    អន្តរាយសុខសាន្តណាកុំបី ៗ
ដូចមានភាសិតសម្តែងថា    សុខា សង្ឃស្ស សាមគ្គី(១)
ជាសុភាសិតព្រះមុនី    មានក្នុងគម្ពីរពុទ្ធសាសនា ៗ
បានសេចក្តីថា ការមូលមិត្រ    ស្រុះស្រួលគំនិតជាគ្រួសារ
រវាងជាតិមនុស្សក្នុងលោក    មិនឲ្យប្រេះឆាជានិកាយ ៗ
នឹងជាបច្ច័យឲ្យកើតបាន    សន្តិភាពសាន្តត្រាណបានសប្បាយ
ផុតពីញុះញង់ប្រទូសរ៉ាយ    កំចាត់កំចាយមនុស្សនឹងមនុស្ស ៗ
សូមព្រះមហារាជស្តេចទ្រង់ជ្រាប    សន្តិភាពបំណងជនស្រីប្រុស
ជាកំពូលស្នេហ៍នៃជាតិមនុស្ស    ក្នុងលោកចិត្តស្រុះស្របស្នេហា » ៗ
ព្រះអង្គទូន្មានជាសាកល    ព្រះចៅកោសលនឹងសេនា
ទទួលប្រតិបត្តិតាមឱង្ការ    ហេតុជាលុះគ្រាអវសាន ៗ
សម្តេចព្រះមហាសីលវ:    យាងចូលតំណាក់សយនដ្ឋាន
ព្រះអង្គផ្ទំនៅជាសុខសាន្ត    តាំងក្សត្រក៏បានដេកសប្បាយ ៗ
    រីឯព្រះចៅដែនកោសល    ព្រះអង្គនឹកដល់គ្រោះអន្តរាយ
ថា « អញលំបាកយ៉ាកព្រះកាយ    តាំងក្សត្រជិតឆ្ងាយរងទុក្ខា ៗ
នេះព្រោះបក្សីអប្រិយក្រៃ    ពាលក្សត់ចង្រៃញុះញង់ណា
បង្កើតសង្គ្រាមក្នុងរដ្ឋា    មនុស្សរងទុក្ខាជាប្រក្រតី ៗ

១– បាលធម្មបទដ្ឋកថា ខុទ្ទកនិកាយ

វិនាសមាសប្រាក់សព្វធនធាន　　វិនាសថ្នល់ស្ពានគោក្របី
នង្គ័លរនាស់កស់ក្ឈូរដី　　ទាំងស្រះដំរីទឹងមានទា ។ល។
អហ្ន៎ ! អំពើញុះញង់នេះ　　គាបញ្ញាំងប្រទេសឲ្យវេទនា
ស្លាប់ក្រស្តពដការពលយោធា　　សូន្យទាំងទ្រព្យពេជ្រមាសប្រាក់ៗ
ហេតុនោះបានជាព្រះពុទ្ធម្ចាស់　　ព្រះអង្គទ្រង់ត្រាស់ទេសន៍បញ្ឈាក់
អំពីបិសុណាពទ:　　ក្លាខ្លាំងអនត្ថឥតឧបមា ”　　។
ទ្រង់ទឹកឃើញហើយព្រះចមហៅ　　បើកបន្ទូលទៅកាន់សេនា
ថា “ ហើយប្រញាប់ឆាប់ ៗ ក៏　　លើកពលសេនាមានថ្វីដៃ　　។
ចូលទៅតាប់ចងកាឡ្យ-បក្សី　　អន្ធពាលអប្រិយចោរចង្រៃ
យកមកឲ្យឆាប់ទាន់នៅថ្ងៃ　　កាត់កប្រល័យថ្ងៃនេះឯង　　។

- ៦ -

លោក កាឡ្យ - បក្សី មេក្បត់ជាតិព្រមទាំងសហការីទាំងអស់ត្រូវព្រះចៅផែនគោសលប្រហារជីវិតបង់　ដោយលោកជាមេញុះញង់បញ្ចុះភ្លើងសង្គ្រាម　។

វីឯបក្សីពាលក្បត់ជាតិ　　កំពុងខ្វីឃ្មាតប្រឹតប្រឹងប្រែង
ប្រមូលញាតិមិត្រឲ្យដើរស្វែង　　គ្រប់ទីកន្លែងគ្មានចន្លោះ　　។
តាប់វេដ្ឋបុរសដែលធ្លាប់ល្បី　　បំរើផែនដីដោយស្ម័គ្រស្មោះ
ដែលលោកគ្មានទោសបន្តិចសោះ　　គ្មានសល់ចន្លោះលោកណាឡើយ ។

ចាប់យកមកចងបង់ប្រាថ្នា ប្រហារជីវិតប្រាកដហើយ
ពួកក្បត់ទាំងអស់ពុំកន្តើយ ខំប្រឹងបង្ហើយនូវគ្រោងការណ៍ ។
គឺដើរលួចប្លន់យកធនធាន គ្រប់ផ្ទះអ្នកមានក្នុងសីមា
ថែមទាំងប្រព្រឹត្តអនាចារ ចាប់យកធីតាមហាសេដ្ឋី ។
ធីតាមន្ត្រីស្ត្រីប្រជា មានរូបសោភាស្រស់ប្រិមប្រិយ
ចាប់ទាំងអំណាចកាចក្ដិយ រួមរសមេត្រីឥតកោតក្រែង ។
ពួកក្បត់កំពុងតែប្រព្រឹត្ត អំពើទុច្ចរិតទាំងនេះឯង
ដោយមានបក្សជាតួស្តែង ជាអ្នកចាត់ចែងនឹងប្រហារ ។
ស្រាប់តែពេជ្ឈឃាតដែនកោសល ដើរចូលមកដល់ជំរាបថា
« ខ្ញុំបានទទួលព្រះអាជ្ញា ពីមហាក្សត្រដែនកោសល ។
ឲ្យចាប់ពួកលោកដើងឆើត ៗ ជាមេបង្កើតចលាចល
មនុស្សជាតិទាំងអស់ជាសាកល ជ្រួលជ្រើមរចល់ខ្វល់ហ្មងសៅ » ។
ថាតែប៉ុណ្ណោះចាប់ចងភ្ជាម មិនឲ្យចាក់ចាម នាំសំដៅ
ចូលកដធានីថ្វាយព្រះចៅ កោសលគង់នៅលើខែនទ័ ។
មានសេនាមាត្យបុរោហិត កវីបណ្ឌិតរដ្ឋមន្ត្រី
គង់នៅគ្រៀបគ្រាពេលរាត្រី ក្នុងដែនកាសីដំនុំការណ៍ ។
ព្រះចៅទ្រង់ទតក្រុមពេជ្ឈឃាត នាំក្រុមក្បត់ជាតិចូលតាមការណ៍
ព្រះអង្គទ្រង់បើកព្រះទន្តារ ត្រាស់ថា « ចូរមកកុំភិតភ័យ ។

នៃលោកបក្សី ! រាស្ត្រប្រជា　　　រងទុក្ខវេទនាតែចូលព្រៃ
ព្រាត់កូនប្រពន្ធទៅទីទៃ　　　ភិតភ័យយំស្រែកទាំងប្រុសស្រី ។
នេះព្រោះតែរូបលោកឯងមួយ　　　ឲ្យកើតទុក្ខព្រួយប្រទេសពីរ
ប្រទេសជិតខាងជ្រួលវក់វី　　　ខំការពារទីជំគ្រប់គ្នា ។
ដូច្នេះពួកក្សត្រគ្រប់ទាំងអស់　　　អ្នកកុំនៅរស់ធ្ងន់វសុធា
ស្លាប់ចុះណ៉ាអ្នកពល់ ៗ គ្នា　　　ឲ្យរាស្ត្រប្រជាបានសុខសាន្ត ។
ខឹងកុំឲ្យមនុស្សជាសាកល　　　កើតចលាចលនាំរំខាន
ព្រោះមនុស្សឥឡូវស្នេហ៍សាន្តត្រាណ ចង់បានគ្រប់គ្នាទាំងប្រុសស្រី » ។
បន្ទូលរួចស្រេចស្តេចកោសល　　　សួរនាយចមពលដែនកាសី
ថា « លោកមេទ័ពបុទ្ធិល្បី　　　កាត់ទោសបក្សីបែបយ៉ាងណា ? » ។
លោកឞ. វិចិត្រទូលប្រញាប់　　　« សូមទ្រង់សណ្ដាប់ច្បាប់មាត្រា
បានចែងរួចហើយព្រះករុណា　　　ច្បាប់ត្រូវប្រហារជីវិតបង់ » ។
បក្សីដឹងថាខ្លួននឹងស្លាប់　　　ក្នុងពេលដាច់ ៗ មិនបង្អង់
ក៏ទូលពិត ៗ តាមត្រង់ ៗ　　　ថា « សូមព្រះអង្គប្រោសប្រណី ។
ទូលព្រះបង្គំខុសពិត ៗ　　　ទោសអស់ជីវិតក្សត់ផែនដី
មុននឹងសម្លាប់សូមប្រណី　　　អាណិតបក្សីមន្ត្រីចាស់ ។
សូមចូលទៅគាល់ព្រះករុណា　　　ព្រះមហាសីលវៈជាអម្ចាស់
បង្គំលាស្លាប់ប្រាកដច្បាស់　　　ខ្ញុំមន្ត្រីចាស់ដែនកាសី ។

ព្រះចៅត្រាស់ថា «មិនបានទេ ព្រោះឯងជាមេក្សត់ចក្រី
បង្កើតសង្គ្រាមឈាមពាសដី ស្លាប់រាស្ត្រប្រុសស្រីទាំងពលការ ។
ព្រះចៅកោសលស្តេចទ្រង់ត្រាស់ បង្គាប់ច្បាស់ ៗ ឲ្យប្រហារ
ហើយ ៗ ពេជ្ឈឃាតចាប់ចងក៏ យកទៅប្រហារកាត់សិរសី ។
ពេជ្ឈឃាតឮហើយស្ទុះប្រញាប់ ចរចូលទៅចាប់ចងបក្ស
ព្រមទាំងពួកបក្សសហការី អូសគ្មានប្រណីទៅប្រហារ ។

– ៧ –

ព្រះចៅដែនកោសល ឡើងគាល់ព្រះមហាសីលវៈដើម្បីថ្វាយបង្គំលាទៅប្រទេសវិញ ព្រះមហាសីលវៈបានថ្វាយដំបូន្មានដល់ព្រះចៅដែនកោសល អំពីទោសនៃបញ្ចវេរ និងអានិសង្សនៃបញ្ចសីល ។

ព្រឹកឡើងព្រះចៅដែនកោសល ព្រមទាំងរេហ៍ពលកងយោធា
ឡើងគាល់សម្តេចធម្មរាជា ថ្វាយបង្គំលាទៅបុរី ។
ដល់ហើយព្រះចៅអភិវាទ សម្តេចនរនាថដែនកាសី
ទូលថា «បពិត្រព្រះនរបតី សូមទ្រង់ប្រណីប្រោសមេត្តា ។
ទូលព្រះបង្គំលាព្រះអង្គ ព្រមទាំងចតុរង្គពលសេនា
ត្រឡប់ចូលទៅកាន់សីមា គ្រប់គ្រងរក្សារាស្ត្រប្រជា ។
ឯរដ្ឋកោសលនិងកាសី ចងស្ពានមេត្រីជិតស្និទ្ធគ្នា
ពង្រឹងមិត្តភាពគ្រប់វេលា ឲ្យរឹងរឹតគ្នាជាអង្វែង ។

ព្រះមហាសីលវ៉ៈទ្រង់ត្រាស់ថា    សូមមហាក្សត្រាកុំគិតក្រែង
លើកទ័ពទៅចុះហើយចាត់ចែង    ស្វះស្វែងប្រឹងប្រែងរកសន្តិភាព ៗ
ឲ្យប្រជាជនជាសាកល    បានយល់បានស្គាល់សេខ្ពស់ទាប
លទ្ធផលតម្លៃនៃសន្តិភាព    មនុស្សទោះខ្ពស់ទាបស្រេកចង់បាន ៗ
ទាំងកុំប្រព្រឹត្តបញ្ឆោក    ជាកម្មវេទនាស្និទ្ធជាប់ប្រាណ
សូមទ្រង់សណ្តាប់ស័ព្ទឲ្យបាន    ដោយប្រឹតប្រឹងប្រាណឲ្យផ្ចិតផ្ចង់ ៗ

១– អំពើបាណាតិបាត    នរណានេសាទចងចិត្តចង់
ពិឃាតមនុស្សដោយចំណង់    ឲ្យស្លាប់បាត់បង់នូវជន្មា ៗ
ឃាតករនោះឯងតែងឆេះក្តៅ    យ៉ាកយ៉ាប់មួយម៉ោឆេះនៅនា
សញ្ញាបនរកទូរទុក    រងទុក្ខវេទនាយូរយារក្រៃ ៗ
និរយបាលចាប់បោះទៅ    ក្នុងក្អកភ្លើងជ្រៅឆេះក្សិណក្ស័យ
កើតឡើងវិញភ្លាមប្រឹងកែខៃ    វាលូនលឿនក្រៃទៅខាងក្រៅ ៗ
និរយបាលបានឃើញជាក់    ស្ទុះចាប់ពេមចាក់ទឹងដែកក្តៅ
ប្ដឹងលំពែងរុញបោះទៅ    ចូលក្នុងរណ្តៅនៅទុរទុក្ខ ៗ
លុះអស់បាបកម្មទើបរដោះ    ពីនរកនោះក៏មិនសុខ
កើតជាមាន់ទានៃអ្នកស្រុក    ប្រាំរយជាតិទុក្ខប្រាកដជាក់ ៗ
ទើបកើតជាមនុស្សគាក្រក់ក្រៃ    ក្ងែងក្ងង់ជើងដៃខ្វិនគមគាក់
កើតឃ្លង់ដំបៅស្រែងក្នេកខ្ទាក់    លំបាកឥតអាក់អាយុខ្លី ៗ

ប្រសិនជាបានបុណ្យស័ក្តិយស ថ្កុំថ្កើងខ្ពង់ខ្ពស់ក្នុងលោកិយ
កម្មតាមមកផ្តល់អាយុខ្លី មិនបាននៅស៊ុំស្លាប់បង់បាត់ ៗ
នរណាខ្មាសបាបខ្លាចបាប វៀរចាកដកបជីវិតសត្វ
មិនហ៊ានបៀតបៀនបំបាត់ សម្លាប់បង់បាត់ផ្តាច់ជីវ ៗ
នរនោះបានកើតនៅលើស្ថាន សួគ៌ទិព្វថ្កើងថ្កានមានអាស្នា
ឈ្មោះចាតុម្មហារាជិកា មានទេពធីតាគាល់កល់ថ្ងៃ ៗ
សោយសម្បត្តិទិព្វសុខសប្បាយ ទាំងរូបរាងកាយល្អល្អះក្រៃ
ប្រាំរយឆ្នាំទិព្វច្យុតញ ត្រកូលថ្លាថ្លៃមានសម្បត្តិ ៗ
មានកម្លាំងខ្លាំងក្លាលើសលន់ ចិន្តាទោរទន់ប្រណីសត្វ
ប្រពន្ធកូនចៅនៅមិនព្រាត់- ប្រាសចាកខ្លាត់ក្លាត់សុខដល់ចាស់ ៗ
កើតមកជាមនុស្សពុំក្សណក្ស័យ ជីវិតប្រល័យគ្រៀងសហ័ស
មានមនុស្សបំរើទាំងក្មេងចាស់ សុខសប្បាយណាស់រកទុក្ខគ្មាន ៗ

២– គឺអទិន្នាទាន:

នរណាលួចប្រាក់ទ្រព្យធនធាន
ដើរលួចដើរប្លន់ពាតរុកពាន រឹបជាន់ឈ្លានពានក្លាឃោរឃៅ ៗ
នរនោះស្លាប់ទៅធ្លាក់រហូត ចុះដល់កាឡសូត្រនរកជ្រៅ
និរយបាលចាប់ចងទៅ ចាក់ទឹងដែកក្តៅឈឺខ្លោចផ្សា ៗ
ហើយទើបពួកខ្លះយកបន្ទាត់ ដែកក្តៅមកផ្ទាត់សព្វកាយា
ខ្លះយករណារភ្លើងមកអារ ពុះពីសិរសារង់ទុក្ខទណ្ឌ ៗ

រយះដាច់សាច់ឈាមស្រោក    ស្រែកយំឥតអាក់ភ័យភាំងភាន់
នៅក្នុងនរកទុក្ខទណ្ឌ    កំណត់មួយពាន់ឆ្នាំរដោះ ៗ
ក្នុងមួយពាន់ឆ្នាំនៃស្ថានត្រៃ–    ត្រឹង្សទើបមួយថ្ងៃនរកនោះ
យូរអង្វែងណាស់ទើបរដោះ    ពីនរកនោះមកកើតបាន ៗ
ជាប្រេតកំពស់ដើមត្នោតលៃ    រង់ទុក្ខទោសពៃរ៍ជាប្រមាណ
អត់បាយអត់ទឹកស្គាំងស្គមប្រាណ    គ្មានបានអ្វីធីចំអែតផ្ទៃ ៗ
ប្រាំរយជាតិទើបចាប់កំណើត    មកកើតជាមនុស្សក្រីក្រក្រៃ
ដើរសូមទានគេអចិន្ត្រៃ    លំបាកយ៉ាកក្រៃនៅខ្ញុំគេ ៗ
ប្រសិននរណាបញ្ញាផ្ទាត    ចិត្តផូរផង់ស្អាតគិតរះរេ
វៀរបាតអំពើលួចទ្រព្យគេ    ដែលមិនឲ្យទេក្នុងលោកា ៗ
នរនោះរមែងតែងតែបាន    ទៅកើតនៅស្ថានត្រៃត្រឹង្សា
មានទេពអប្សរបវរកញ្ញា    គង់គាល់ត្រៀបត្រានៅរហង់ ៗ
សោយសម្បត្តិទិព្វជាសុខសាន្ត    មួយពាន់ឆ្នាំបានច្យុតបាត់បង់
មកកើតជាក្សត្រក្រ្តផូរផង់    ឬសេដ្ឋីខ្ពង់បុណ្យថ្កើងថ្កាន ៗ
សម្បូណ៌មាសប្រាក់កែវកងពេជ្រ    ចោរចូលកំទេចយកពុំបាន
ប្រពន្ធកូនចៅទាំងប៉ុន្មាន    បានសុខសាន្តត្រាណគ្មានគិតក្រែងៗ
៣– គឺកាមេសុមិច្ឆា    នរណាព្រហើនចិត្តរង្វេង
លួចប្រពន្ធកូនគេឥតក្រែង    ឬផិតក្បត់ឯងតែងរងទុក្ខ ៗ

នរនោះលុះស្លាប់បាត់បង់ទៅ　　ធ្លាក់ចុះទៅនៅស្ថាននរក
ឈ្មោះសង្ឃាតៈរង់ទោសទុក្ខ　　ភ្លើងឆេះគគុកក្តៅខ្លោចផ្សា ៗ
និរយបាលឈរចាំយាម　　ក្រឡេកឃើញក្លាមស្ទុះប្រហារ
ដេញចាក់ឲ្យឡើងដើមរកា　　ដែកមានបន្លាស្រួចដុះជ្រោង ៗ
មេស្រីផិតប្តីឡើងមុនប្រុស　　មុតខ្លួនសព្វសុសស្រែកយំងើង
ហើយហុចដៃឲ្យគាប្រុសគោង　　ចាប់យោងទាញឡើងយំស្រោកៗ
ខាងក្រោមមានឆ្កែ-និរយបាល　　ជាច្រើនក្រអាលខាំក្របាក់
ខាងលើមានក្អែកចឹកកន្ត្រាក់　　ធ្លុះធ្លាក់ដល់ដីខ្លួនដេកផ្ងា ៗ
បង្អែមឆ្កែចំពុះសត្វក្អែក　　សុទ្ធតែដែកស្លាតស្រួចមុតថ្ង
គ្របាក់ខាំចឹកដួលដេកផ្ងា　　ឆេះក្តៅគាយាផ្សាវេទនា ៗ
នរកនោះអាយុវែងក្រៃ　　ពីរពាន់ឆ្នាំនៃស្ថានយាមា
ទើបបានមួយថ្ងៃស្ថានសង្ឃាត　　អស់កម្មពៀរទើបរដោះ ៗ
មកកើតបានជាសត្វតិរច្ឆាន　　គេគ្រៀវគ្មានបានសប្បាយសោះ
គ្រប់ប្រាំរយជាតិទើបរដោះ　　ពិតពៀរនោះទើបនឹងបាន ៗ
កើតជាមនុស្សខ្ទើយប្រាំរយជាតិ　　ទើបក្លាយខ្លួនឃ្លាតជាប្រុសប្រាណ
ឬស្រីប្តីក្បត់ផិតសាមាន្យ　　ប្រាំរយជាតិបានជាមនុស្សម្នា ៗ
បើនរណាមានប្រាជ្ញាអាចរំរេ　　វៀរចាកការមេសុមិច្ឆាចារ
នរនោះនឹងបានកើតសួគ៌ា　　ឈ្មោះស្ថានយាមាទិព្វថ្លាថ្លៃ ៗ

ស្តេចទ្ទីទ្ទិបញ្ចប    ចំពេញគ្រងដាចរុងរឿងក្រៃ
ស្រីទេពអប្សរគាល់កល់ថ្ងៃ    ឆើតឆោមល្អក្រៃកាយបរិសុទ្ធ ។
ស្ថានយាមាអាយុពីពាន់·    ឆ្នាំទិព្វគ្រប់គ្រាន់ទើបចុះច្យុត
មកចាប់កំណើតជាកជបុត្រ    កិរិយាបរិសុទ្ធគបកាយល្អ ។
៤– គឺមុសាវាទាជាក់    នរណាចិត្តស្ម័គ្រពោលភូតភរ
ឲ្យកើតចលាចលវឹកវរ    វាតខ្ញូបបោអ្នកដទៃ ។
នរៈនោះធ្លាក់ចុះពោរពនរក    រងទោសរងទុក្ខអចិន្ត្រៃ
និរយបាលកាត់ជើងដៃ    រៀងពល់ថ្ងៃ ៗ ដួលដេកខៅ ។
កាត់មាត់អណ្តាតឈាមស្រស្រាក់    ហើយទាញកន្ត្រាក់បោះចោលទៅ
ចូលក្នុងរណ្តៅឆេះសន្ធៅ    រងទោសទណ្ឌនៅទុក្ខរមរិត ។
ពោរពអាយុយូរយារក្រៃ    មួយពាន់ឆ្នាំនៃស្ថានតុសិត
ទើបបានមួយថ្ងៃនរកពិត    អស់កម្មអតីតទើបរដោះ ។
មកកើតជាប្រេត-អសុរកាយ    ក្រហល់ក្រហាយគ្មានចន្លោះ
ក្អែងឆេះអណ្តាតចេញមាត់ស្មោះ    ស៊ីឈាមស៊ីខ្ទុះជាអាហារ ។
អស់កម្មទើបកើតមកជាមនុស្ស    បានជាស្រីប្រុសមាត់ឆែបឆា
ល្ងិតល្ងង់ល្ងីល្ងើអាប់បញ្ញា    ដល់ពោលវាចាស្អុយសក្តិសិទ្ធិ ។
នរណាវៀរបាកមុសាវាទ    មិនឲ្យឃ្លៀងឃ្លាតចាកពាក្យពិត
នរៈនោះបានកើតស្ថានតុសិត    រុងរឿងថ្កើងឫទ្ធិស្មើសាយ ។

បួនពាន់ឆ្នាំទិព្វទើបច្យុតចុះ    មកកើតជាមនុស្សរូបចេតឆាយ
ជាពហុសូត្រព្រោកប្រាជ្ញប្រាយ    ល្បីល្បាញខ្ចរខ្ចាយក្នុងលោកិយ ៗ
៤ – គឺសុរាមេរយា    នរណាផឹកស្រាទឹកអប្រិយ
ស្រវឹងប្រមឹកចិត្តតិរិយ    វង្វេងស្មារតីភ្លេចធម្មា ៗ
នរនោះលុះស្លាប់បាត់បង់ទៅ    ធ្លាក់នរកជ្រៅស្ថិតនៅនា
ស្ថានបាតនរកទុក្ខមហិមា    ទុរន់ទុកយូរយារណាស់ ៗ
ដោយហេតុប្រមឹកចិត្តវង្វេង    ផឹកទឹកទង់ដែងពុះពេញខ្ទះ
ឆេះថ្លើមប្រមាត់ឆេះក្រពះ    ស្រែកយំខ្លាំងណាស់ឥតឧបមា ៗ
ប្រាំបីពាន់ឆ្នាំនិម្មានរតី    បានមួយពគ្រស្ថានបាតា
អស់កម្មទើបកើតជាយក្ស    ឬមនុស្សលីលាឆ្កួតចង្រៃ ៗ
នរណាមានប្រាជ្ញដ៏ក្លៀវក្លា    វៀរសេពសុរាទឹងមេរ័យ
នរនោះនឹងកើតស្ថានសួគ៌ថ្ងៃ    ខ្ពស់ក្រៃឈ្មោះនិម្មានរតី ៗ
ស្ថិតខ្ពស់នៅលើប្រាង្គប្រាសាទ    វិចិត្រស្អាងស្អាតសុទ្ធតែស្រី
ស្រីទេពអប្សរល្អប្រិមប្រិយ    គង់គាល់ប្រក្រតីមិនដែលខាន ៗ
សោយសុខជាយូរទើបច្យុតចុះ    មកកើតជាមនុស្សខ្ពស់ថ្កើងថ្កាន
មានប្រាជ្ញអង់អាចយ៉ាងក្លាហាន    ដោះប្រស្នាបានក្នុងលោកា ៗ
ព្រះចៅកោសលក្រាបអភិវាទ    សម្តេចនរនាថលើលោកា
ទទួលប្រតិបត្តិតាមទង្គារ    ហើយលើកសេនាចូលបុរី ៗ

# សេចក្ដីសង្ខេបរឿង

## បទកាកគតិ

១) ព្រះមហាសីលវៈ ខត្តិសច្ចៈ ទ្រង់សីលធមិគាថ
ពលរដ្ឋប្រុសស្រី មេត្រីស្នេហា នាំគ្នារក្សា
សីលទាំងប្រុសស្រី ៗ ចេះរួបរួមគ្នា ទាំងក្សត្រប្រជា
នាហ្មឺនកុងវៀយ ស្រឡាញ់គ្នាស្និទ្ធ រួមរឹតមេត្រី
ទាំងប្រុសទាំងស្រី រួមគ្នាជិតស្និទ្ធ ៗ ប្រទេសកាសី
រុងរឿងល្បាញល្បី គ្រប់ទិសឆ្ងាយជិត ក្រោមកិច្ចដឹកនាំ
ឧត្តមពិត ៗ ប្រទេសឆ្ងាយជិត ឧបត្ថាបចេស្ដា ៗ
ព្រះមហាសីលវៈ ជាមហាវីរៈ ក្សត្រឆ្នើមលោកា
ព្រះអង្គចេញច្បាំង តតាំងចេស្ដា ជាមួយក្សត្រា
ប្រទេសកោសល ៗ ទ្រង់ធ្វើសង្គ្រាម គ្មានបង្ហូរឈាម
ឲ្យបលាបល ចម្បាំងឈ្នះស្រេច ទើបស្ដេចកោសល
ទុនសិរសាផល់ ផែនដីបង្គំ ៗ ព្រះមហាសីលវៈ
ព្រះទ័យស្មោះស្ម័គ្រ ស្នេហាក្សត្រតូច-ធំ ទូន្មានប្រដៅ
ព្រះចៅឲ្យចាំ លះបង់គំនុំ គុំគួនព្យាបាទ ៗ
ឲ្យថែរក្សា បញ្ចសីលា បានផូរផង់ស្អាត
ឲ្យចេះស្រឡាញ់ មិនឲ្យប្រមាទ បៀតបៀនព្យាបាទ

ជាតិមនុស្សដូចគ្នា ។

២) ព្រះចៅកោសល ស្ដេចលើកសាគល សេនាយោធា
ចូលមកសំរុក លុយលុកពុះពារ ញាំញីកាក
ពារាណសី ។ លុះបកជ័យ កោសលគិតភ័យ
សិរសាដល់ដី ក្រួញក្រាបអភិវាទ នរនាថកាសី
ថ្វាយខ្លួនទឹកដី ថ្វាយពលសេនា ។ ហើយបានតាំងចិត្ត
លះបង់ទុច្ចរិត ទាំងបីប្រការ លែងដើរកគត្យាត
ព្យាបាទប្រហារ បង្កើតចលា- ចលលើផែនដី ។
ព្រះចៅប្រព្រឹត្ត អំពើសុចរិត សព្វគ្រប់ទាំងបី
បញ្ចសីលា រក្សាប្រក្រតី ទាំងប្រុសទាំងស្រី
មេត្រីស្មោះសរ ។ ព្រះចៅប្រព្រឹត្ត អំពើសុចរិត
បរិសុទ្ធបវរ ទើបស្ដេចទ្រង់ត្រាស់ កម្រាស់ស្មោះសរ
ឲ្យប្រជាករ នឹងអ្នករាជការ ។ ប្រព្រឹត្តទាំងអស់
មិនឲ្យបន្ទោះ សល់ខានលោកណា ដោយព្រះគំនិត
យល់ពិតច្បាស់ថា អាចញុំាងលោកា បានសន្តិភាព ។
ព្រះចៅកោសល ជាធ្មើមលើពល សេនាខ្ពស់ទាប
ព្រះទ័យមិនក្នាញ់ ស្រឡាញ់សន្តិភាព យសស័ក្តិខ្ពស់ទាប
ទ្រង់រាប់ស្មើគ្នា ។

៣) លោកកាឡ-បក្សី សេនាបតី លោភលន់មហិមា

ប្រាថ្នាសម្បត្តិ មហាក្សត្រសោកា បង់តាំងខ្លួនជា

ស្តេចគ្រងផែនដី ៗ ចំបះចំបោរ បង្កើតទ័ពចោរ

កងអញ្ជើញ ឲ្យដើរពតក្បាត ព្យាបាទប្រុសស្រី

ញាប់ញ័រផែនដី កាសីរដ្ឋ ៗ បក្សីអន្ធពាល

ថ្លើមធំពាសពល ចាក់រុកព្រះមហា ក្សត្រដែនកោសល

លើកពលសេនា ចូលប្លន់រដ្ឋ ប្រហារប្រុសស្រី ៗ

បង្កើតសង្គ្រាម បង្ហូរតែឈាម ជាតិខ្លួនឯងខ្ញី

ឲ្យជាតិវេទនា កំព្រាបាត់ប្តី បាត់កូនប្រុសស្រី

បាត់យាយបាត់តា ៗ បក្សីអបលក្ខណ៍ ក្បត់ព្រះសីលវៈ

ក្បត់ជាតិសាសនា ផល់នូវអន្តរាយ រូបកាយមតា

ស្លាប់ដូចឆ្កែឆ្មា អាហារឆ្កែត្មាត! ៗ

ភាសិត

លោភហួសខ្នាត

នាំខាតដើម ៗ

# ព្រះអភិធម្មបិដក

## (គម្ពីរព្រះមហាបដ្ឋាន)

លោក ប៊ូ-ប៉ូ រៀបរៀង

(តមក)

---

ទើបជំនុំប្រឹក្សាគ្នាថា « យើងទាំងឡាយនឹងធ្វើដូចម្តេច នឹងញុំាងទោសឲ្យកើតឡើងដល់ព្រះសមណគោតមបាន » ក៏យល់ឃើញព្រមគ្នាថា " នឹងពឹងពាក់អាស្រ័យនាងចិញ្ចមាណវិកានោះឯង ទើបអាចញុំាងទោសឲ្យកើតឡើងបាន ,, លុះយល់ឃើញព្រមគ្នាដូច្នេះហើយ ក៏គិតសំគាល់ទុកតែក្នុងចិត្ត មិនស្រដីប្រាប់អ្នកណាឡើយ ។

អបរភាគេ ចំណោរបេរកាលខាងក្រោយមក មានមួយថ្ងៃ តិត្ថិយារាមំ គន្ត្វា នាងចិញ្ចមាណវិកាបរិញ្វាជីទៅឯអាភមនៃតិរ្ថិយទាំងឡាយនោះ លុះដល់ហើយក៏លើកដៃឡើងសំពះហើយអង្គុយនៅក្នុងទីដ៏សមគួរដល់ខ្លួន ។ តិរ្ថិយទាំងឡាយធ្វើកលមាយា គ្មានអ្នកណាចរចាជាមួយនាងចិញ្ចមាណវិកាសោះ នៅស្ងៀមឈឹងទាំងអស់គ្នា ។ នាងចិញ្ចមាណវិកាគិតតែក្នុងចិត្តថា « លោកម្ចាស់ទាំងឡាយរបស់អញនេះក្រោធខឹងនឹងអញឬអ្វី បានជាធ្វើអាការយ៉ាងនេះ មិនស្តីនិយាយនឹងអញសោះ » នាងគិតរួចសួរថា : « បពិត្រលោកម្ចាស់ទាំងឡាយ ! លោកទាំងឡាយខ្ញាល់នឹងខ្ញុំដោយហេតុអ្វី បានជាមិនចរចានឹងខ្ញុំសោះយ៉ាងនេះ?

តិរ្ថិយទាំងនោះឆ្លើយថា: «យើងរាល់គ្នាឥតក្រោធខឹងអ្វីនឹងនាងទេ ចុះវេលានេះនាងមិនដឹងទេ ឬថា: យើងទាំងឡាយពុំបានសេចក្ដីសុខ ព្រោះហេតុតែអាស្រ័យនូវព្រះសមណគោតម ព្រះសមណគោតមលោកបៀតបៀនឲ្យយើងរាល់បាត់ប្រាសចាកសេចក្ដីសប្បាយចិត្ត ។

នាងចិញ្ចមាណវិកាសួរថា: កិំ ការោមិ ចុះខ្ញុំនឹងធ្វើដូចម្ដេច ទើបលោកទាំងឡាយសប្បាយចិត្ត ?

តិរ្ថិយទាំងនោះឆ្លើយថា: សចេ ឥច្ឆសិ បើនាងចង់ឲ្យយើងបានសប្បាយរីករាយ ចូរគិតញុំាងទោសណាមួយឲ្យកើតដល់ព្រះសមណគោតម ព្រោះថា អ្នកដទៃមិនអាចញុំាងទោសឲ្យកើតដល់ព្រះសមណគោតមបានឡើយ មានតែនាងម្នាក់ឯងប៉ុណ្ណោះ ទើបអាចញុំាងទោសឲ្យកើតដល់ព្រះសមណគោតមបាន ។

សាធូតិ សម្បដិច្ឆិត្វា នាងចិញ្ចមាណវិកាទទួលពាក្យពួកតិរ្ថិយថា ប្រពៃហើយ ខ្ញុំនឹងធ្វើ ។ នាងនេះទទួលពាក្យតិរ្ថិយរួចហើយក៏លាទៅ ។ កាលមហាជនស្ដាប់ព្រះសទ្ធម្មទេសនានៃព្រះបរមសាស្ដាចប់ហើយ ត្រឡប់ចេញទៅផ្ទះវិញ នៅពេលព្រលប់ នាងចិញ្ចមាណវិកាចេញមកពីត្រិះស្ថានអាត្មាដើរតាមមាគ៌ាជួបនឹងមហាជន ។ សួរនាងចិញ្ចមាណវិកាថា: កុហឹ គច្ឆសិ នាងទៅទីណាក្នុងពេលនេះ ?

នាងចិញ្ចមាណវិកាបរិព្វាជីឆ្លើយថា ខ្ញុំទៅកាន់វត្តព្រះជេតពន ។

លុះដល់វេលាព្រឹកឡើង ជនទាំងឡាយចូលទៅកាន់ព្រះវិហារ នាងចិញ្ចមានវិកានោះ ក៏ដើរត្រឡប់មកពីព្រះជេតពនមហាវិហារវិញ ៗ ជនទាំងនោះសួរថា: នាងមកពីទីណា ? នាងចិញ្ចមានវិកាប្រាប់ថា: ខ្ញុំវិលទៅផ្ទះខ្ញុំវិញ ៗ ជនទាំងឡាយឮដូច្នោះ ក៏មានចិត្តគិតសង្ស័យតែកល់គ្នា ៗ កន្លងពីនោះមកមិនយូរប៉ុន្មាន នាងចិញ្ចមានវិកាប្រាប់ជនទាំងឡាយថា: យើងទៅនៅក្នុងព្រះគន្ធកុដីជាមួយនឹងព្រះសមណ-គោតមក្នុងវត្តជេតពន ៗ

កន្លងពីពេលនោះមកប្រមាណជាពីរ ឬបីខែ នាងចិញ្ចមានវិកាយកឈើដំខ្នងដៃខ្នងជើងឲ្យហើមប៉ោងឡើងដូចជាដៃនឹងជើងនៃស្ត្រីមានគភ៌ ៗ លុះយូរមកទៀត នាងនេះយកកំណាត់សំពត់ចងរុំពោះឲ្យឡើងប៉ោងធំ ធ្វើអាការហាក់ដូចស្ត្រីមានគភ៌គ្រប់ខែជិតនឹងប្រសូតបុត្រ ទើបទៅកាន់-សំណាក់នៃព្រះពុទ្ធអង្គ ដែលកំពុងគង់នៅកណ្តាលជនទាំងឡាយជាសប្បុរសដើម្បីនឹងស្តាប់ព្រះសទ្ធម្មទេសនា ៗ នៅពេលដែលព្រះពុទ្ធជាអម្ចាស់កំពុងត្រាស់ទេសនាធម៌ដល់ពុទ្ធបរិស័ទទាំងបួននោះអក្កោស នាងចិញ្ចមានវិកាស្រែកដេរព្រះមានព្រះភាគថា « បពិត្រព្រះសមណ:ប្រសើរ ព្រះអង្គចូរពិចារណាមើលនូវអាការដ៏គួរចុះ ឥឡូវនេះ ខ្ញុំព្រះអង្គមានគភ៌គ្រប់ខែហើយ ព្រះអង្គមិនដឹងទេ ឬអ្វី ព្រះអង្គធ្វើអាការហាក់ដូចជាមិនបានដឹងសោះ ព្រះអង្គមិនបានដឹងនូវការជួយសង្គ្រោះខ្ញុំព្រះអង្គដែល

មាននាមថាចិញ្ចមានវិកាផងទេ ដឹងតែខាងការគ្រេកគ្រអាលនឹងខ្ញុំព្រះអង្គម្យ៉ាងប៉ុណ្ណោះ ឯការដែលខ្ញុំព្រះអង្គនឹងប្រសូតបុត្រនោះ ទ្រង់បំភ្លេចចោលធ្វើជាមិនដឹងទៅវិញ បើទ្រង់មិនទទួលដឹង មិនជួយទំនុកបម្រុងខ្ញុំព្រះ-អង្គទេ ក៏តាមព្រះទ័យចុះ ប៉ុន្តែគួរនឹងបង្គាប់អ្នកឧបដ្ឋាក គឺព្រះបាទ-បសេនទិកោសល នឹងអនាថបិណ្ឌិក ឬ ចុល្លអនាថបិណ្ឌិកជាដើមឲ្យធ្វើផ្ទះឬរោងសម្រាប់ខ្ញុំព្រះអង្គប្រសូតបុត្រឲ្យផុតពីសេចក្តីទុក្ខលំបាក នេះបង្គាប់អ្នកណាក៏គ្មាន មានតែខាងគ្រេកគ្រអាលនឹងខ្ញុំព្រះអង្គមួយមុខ-ប៉ុណ្ណោះ លុះខ្ញុំព្រះអង្គមានគភ៌ ក៏ទ្រង់ស្ងៀមឈឹងមិនសាកសួរថា ចិញ្ច-មានវិកានេះយ៉ាងណាទៅហើយ ។

កាលនាងចិញ្ចមានវិកាដេរតិះដៀលព្រះមានព្រះភាគដូច្នោះ ប្រៀបដូចជាបុគ្គលប្រទូសកយព្រះចន្ទទៅបុត្រក្នុងអាកាស នាំយកនូវដុំលាមកចូលទៅក្នុងមាត់ ។

អថ សត្ថា ក្នុងលំដាប់នោះ សម្តេចព្រះបរមសាស្តា មានព្រះពុទ្ធ-ដីកាថា "ម្នាលនាងបរិព្វាជី នាងមានឈ្មោះថាចិញ្ចមានវិកា ពាក្យដែលនាងនិយាយចោទតថាគតមិនបានប្រាកដដល់អ្នកដទៃទេ អ្នកដទៃឥតបានដឹងរឿងនេះសោះ ដឹងតែនាងនឹងតថាគតពីរនាក់ប៉ុណ្ណោះ តថាគតបានធ្វើដូចពាក្យនាងថាក្តី មិនបានធ្វើដូចពាក្យនាងថាក្តី គ្មានអ្នកណាដឹងនូវហេតុផលនេះទេ មានតែសម្តេចអមរិន្ទ្រាទេវរាជ ទ្រង់នូវព្រះនេត្រទិព្វ

ទើបអាចដឹងច្បាស់ឃើញច្បាស់នូវព្រឹត្តិហេតុ ដែលនាងពោលនឹងគថាគគនេះ ” ។

តស្មិំ ខណេ ក្នុងខណៈនោះ បណ្ឌុកម្ពលសិលាអាសន៍នៃស្ដេចវីវោបាណសក្រទេវរាជ ក៏មានអាការវិបលាសក្ដៅ ហើយនឹងមិនជាទីសប្បាយព្រះហឫទ័យ អាវជ្ជេន្តោ សម្ដេចអមរិន្ទ្រទ្រង់ចិន្ដាការកំណត់ព្រះហឫទ័យថា ហេតុអ្វីបានជាបណ្ឌុកម្ពលសិលាអាសន៍កើតវិបលាសយ៉ាងនេះ ទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់ជ្រាបថា នាងចិញ្ចមានវិកាពោលពាក្យប្រមាថមើលងាយអង្គសម្ដេចព្រះមានព្រះភាគដោយពាក្យអាក្រក់ត្រគោះបោះបោក មិនសមគួរសោះ ត្រូវតែអញចុះទៅរំលាយបំបាត់នូវសេចក្ដីសង្ស័យ ដែលកើតមានឡើងក្នុងកណ្ដាលបរិស័ទទាំងបួន លុះទ្រង់ជ្រាបយ៉ាងនេះហើយ ក៏ស្ដេចចុះចាកតាវត្តិង្សព្រិភពមកកាន់ជេតពនមហាវិហារ លុះដល់ព្រះជេតពនហើយ ទើបបណ្ដាលដោយទេវបុត្តជាមុសិកជាតិកណ្ដុរចូលទៅកាត់មណ្ឌល នៃចេសនឹងកំណាត់សំពត់ឲ្យដាច់ធ្លាក់ចុះមកចំពោះមុខនៃចតុបរិស័ទ ។ ខ្សែចេសនឹងដុំកំណាត់សំពត់ កាលដាច់ហើយ ក៏ធ្លាក់ចុះលើខ្នងជើងនៃនាងបរិញ្ញាជី ។ មហាជនទាំងឡាយនាំគ្នាប្រហារនាងចិញ្ចមានវិកា ។ ខណៈនោះ ផែនពសុធាដែលឥតចិត្តហាក់ដូចជាមានចិត្ត បើកឲ្យចន្លោះដល់នាងចិញ្ចមានវិកា ។ នាងចិញ្ចមានវិកាក៏ធ្លាក់ចុះទៅក្នុងចន្លោះពសុធា ទៅកើតក្នុងនរកឈ្មោះមហា-

អវិចិ ។ ផលនៃអកុសលដូច្នេះ ក៏រាប់បញ្ចូលក្នុងទិដ្ឋធម្មវេទនីយកម្ម ។

ឯអកុសលកម្មដ៏ជាទិដ្ឋធម្មវេទនីយនោះ ដូចជាព្រះទេវទត្តនិងព្រះ-កោកាលិកៈធ្វើ គឺចាត់ជាទិដ្ឋធម្មវេទនីយកម្មខាងអកុសល ។ កម្មដែលឈ្មោះថាទិដ្ឋធម្មវេទនីយ៍ទាំងពីរចំណែក គឺកុសលនិងអកុសល ។ បើកុសលកម្មឲ្យផលឃើញជាក់ស្តែងក្នុងបច្ចុប្បន្ន ក៏ចាត់ជាទិដ្ឋធម្មវេទនីយ-កម្មខាងកុសល ។ បើអកុសលដែលបុគ្គលធ្វើឲ្យផលឃើញជាក់ស្តែងក្នុងបច្ចុប្បន្ន ក៏ចាត់ជាទិដ្ឋធម្មវេទនីយកម្មខាងអកុសល ។

ហេតុនោះ អ្នកប្រាជ្ញគប្បីធ្វើមនសិការកំណត់ទុកក្នុងចិត្តថា អកុសលកម្មដ៏ធ្ងន់នោះ បើបុគ្គលណាធ្វើខ្លាំងក្លា គឺថាប្រទូសរាយដល់មាតាបិតា ប្រទូសរាយដល់សមណព្រាហ្មណាចារ្យ ប្រទូសរាយដល់អ្នកមានសីលហើយ ក៏អាចឲ្យផលឃើញជាក់ស្តែងជាទិដ្ឋធម្មវេទនីយ៍បាន ។ ចំណែកខាងកុសលវិញក៏ដូចគ្នាដែរ បើធ្វើទានលះបង់ជីវិត រក្សាសីលមិនគិតថាជីវិត និងរលត់បញ្ចក្ខន្ធ ស៊ូលះបង់ ឬរទឹងសីល គិតតែខាងធ្វើសីលឲ្យស្អាតបរិសុទ្ធហើយ ក៏អាចឲ្យផលជាទិដ្ឋធម្មវេទនីយកម្មបាន ។

ប្រការមួយទៀត អាចិណ្ណអកុសលកម្ម គឺអកុសលកម្មដែលបុគ្គលធ្វើសន្សំទុកអស់កាលជានិច្ចរាល់ថ្ងៃ ក៏ជាទិដ្ឋធម្មវេទនីយ៍ ដូចជាព្រះទុដ្ឋរាជកុមារស្តេចទៅកាន់ព្រះរាជឧទ្យាន បានទស្សនាការឃើញផនទាំងឡាយ មានសេចក្តីគោរពក្នុងព្រះបច្ចេកពុទ្ធ ក៏មានសន្តានក្រោធខ្វាល់

បរគជសារឲ្យដេញព្រះបច្ចេកពុទ្ធ ។ ក្រឡេកមើលក៏តែតែក្រោធខ្លាំងឡើង ទើបឆក់យកបាត្រនៃព្រះបច្ចេកពុទ្ធនោះ មកបោះលើប្រថពី ហើយជាន់ឈ្លីទីនជើង រួចនិយាយនឹងព្រះបច្ចេកពុទ្ធថា បើព្រះសមណៈខឹងនឹងយើង តើខឹងធ្វើអ្វីដល់យើងកើត ៗ ក្នុងខណៈនោះ ព្រះហឫទ័យរបស់ទុដ្ឋរាជ-កុមារបណ្ដាលឲ្យក្ដៅក្រហាយមានសេចក្ដីលំបាកយ៉ាងខ្លាំង ស្រេកទឹកណាស់ ទឹកក្នុងកុណ្ឌីក៏រីងស្ងួតអស់ គួរឲ្យអស្ចារ្យពេក ៗ រាជបុរសទាំងឡាយនាំគ្នាត្រាច់រង្គាត់ស្វះស្វែងរកទឹកដែលមានក្នុងពាង ក្នុងស្រះទីង ភាជន៍ដាក់ទឹកដែលមានក្នុងព្រះរាជឧទ្យាន ៗ នៅទីកន្លែងដែលធ្លាប់តែមានទឹកពេញពោរបរិបូណ៌ពីកាលមុននោះ ក៏ប្រែខ្លួនជារីងស្ងួតហួតទឹកអស់ទៅវិញនៅគ្រានោះ ៗ ព្រះរាជកុមារស្រេកទឹកខ្លាំងណាស់ រកទឹកសោយមិនបាន ក៏អស់ព្រះជន្មាយុសង្ខារ ហើយទៅកើតក្នុងអវិចិមហានរក ដោយហេតុអកុសលកម្មជាទិដ្ឋធម្មវេទនីយ៍ ឲ្យផលឃើញជាក់ស្ដែងក្នុងបច្ចុប្បន្ន ៗ

ម្យ៉ាងទៀត អកុសលកម្មនៃព្រះបាទកលាពុរាជដែលប្រទូសរាយដល់សម្ដេចព្រះពុទ្ធអង្គជាម្ចាស់នៃយើង កាលព្រះអង្គសោយព្រះជាតិជាខន្តិវាទីតាបសបរមពោធិសត្វនោះ ក៏បានជាទិដ្ឋធម្មវេទនីយកម្មខាងអកុសល ៗ

ហត្ថិមារកៈព្រានដំរី ដែលប្រទូសរាយដល់សម្ដេចព្រះពុទ្ធអង្គ កាល

ហោយព្រះជាតិជាស្តេចកុញ្ជរឈ្មោះឆទ្ទន្ត អកុសលកម្មនោះ ក៏ឈ្មោះជាទិដ្ឋធម្មវេទនីយ៍ ។

អ្នកប្រាជ្ញគប្បីចូលចិត្តថា អកុសលកម្មដែលបុគ្គលធ្វើក្នុងជាតិនេះ ហើយឲ្យផលក្នុងជាតិនេះ ក៏ឈ្មោះជាទិដ្ឋធម្មវេទនីយកម្មខាងកុសលទាំងអស់ ។

ប្រការមួយទៀត អាចិណ្ណកុសលកម្ម គឺកុសលកម្មដែលបុគ្គលធ្វើសន្សំទុកអស់កាលជានិច្ចកាល់ថ្ងៃ ដូចជាអនាថបិណ្ឌិកមហាសេដ្ឋីថ្វាយបិណ្ឌបាតរាល់ថ្ងៃរហូតដល់តែអស់ទ្រព្យសម្បត្តិមិនអាចថ្វាយអាហារបិណ្ឌបាតឲ្យប្រណីតបាន ក៏នៅតែខ្សោះខ្សាច់ថ្វាយអាហារបិណ្ឌបាតមិនដាច់ ថ្វាយបានតែបិណ្ឌបាតសៅហ្មងជាមួយនឹងទឹកជ្រក់ជាគំរប់តិបប៉ុណ្ណោះ ។ វេលាខាងក្រោយមក ទេវតាដែលអាស្រ័យនៅនាខ្លោងទ្វារជាគំរប់បួន នាំយកទ្រព្យមកដាក់ពេញឃ្លាំង ប្រមូលផ្តួនទ្រព្យសម្បត្តិរបស់អនាថបិណ្ឌិកមហាសេដ្ឋីឲ្យមូលមកពេញឃ្លាំងដូចដើមនោះ ក៏អាស្រ័យអាចិណ្ណកុសលកម្ម គឺការធ្វើសន្សំកុសលកម្មជានិច្ចមិនដាច់ ។

ហេតុនោះអ្នកប្រាជ្ញគប្បីធ្វើមនសិការកំណត់ទុកក្នុងចិត្តថា ផលនៃកុសលកម្មដ៏ជាអាចិណ្ណកុសលនោះ អាចឲ្យផលជាទិដ្ឋធម្មវេទនីយ ដូចបរិយាយមកនេះ ។

ទិដ្ឋធម្មវេទនីយ៍កម្ម សង្ខេបប៉ុណ្ណោះ ។

(នៅមានត)

សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សាប្រែរៀបរៀង

(តមក)

## ១– សីវលិត្ថេរវត្ថុកថា

តតោ ជិនស្ស រចិតំ សោតុកាមា មហាជនា

ទេវមាណវគន្ធព្វា ព្រហ្មានោ ច មហិទ្ធិកា

សមណព្រាហ្មណាចាបិ នមស្សឹ សុកតញ្ជលី

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម

ឧត្តិយេន មហាទានំ ទិន្នំ សត្តាហកាប្បិតេ

សោតុកាមា ផលន្តស្ស ព្យាករោហិ មហាមុនី ។

លំដាប់នោះ មហាជនទាំងឡាយគឺ ទេវតាមាណពនឹងគន្ធព្វទាំងឡាយ គឺ ព្រាហ្មណ៍ទាំងឡាយគឺ ដែលមានរិទ្ធិច្រើន មួយទៀតសមណៈ នឹងព្រាហ្មណ៍ទាំងឡាយគឺ ដែលមានប្រាថ្នាចង់ស្តាប់នូវព្រះពុទ្ធដីកានៃ ព្រះជិនស្រី សឹងធ្វើអញ្ជលីដោយប្រពៃ ក្នុងកិរិយានមស្សការដូចនេះថា : បពិត្រ ព្រះអង្គ ជាបុរសអាជានេយ្យដ៏ប្រសើរ យើងខ្ញុំទាំងឡាយសូម នមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ឧត្តម យើងខ្ញុំទាំងឡាយ សូមនមស្ការ ចំពោះព្រះអង្គ មហាទាន ដែលមហាក្សត្រិយ៍បានបរិច្ចាគ

ហើយកំណត់ប្រាំពីរថ្ងៃ យើងខ្ញុំប្រាថ្នាចង់ដឹងនូវផលទាននោះ សូមព្រះមហាមុនីទ្រង់ព្យាករណ៍ផលទាននោះ ដល់យើងខ្ញុំទាំងឡាយស្តាប់ឥឡូវនេះឯង ។

តតោ អហោច ភគវា សុណាថ មម ភាសិតំ
អបរមេយ្យម្ហិ ពុទ្ធស្មឹ គុណម្ហិ សុបតិដ្ឋិតា
ទក្ខិណា ទាយកំ បត្តា អប្បមេយ្យផលាវហា
អបិ បេសមហាកោតោ ហាធំ បត្តិមុត្តមំ
លាភិ វិបុលលាភីនំ យថាភិក្ខុសុទស្សនោ
តថាហំបិ ភវេយ្យន្តិ លច្ឆតេ តំ អនាគតេ

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរស្តាប់នូវភាសិតរបស់តថាគត ( ដូចមានតទៅនេះ ) ទក្ខិណាទានដែលទាយកបានដល់ប្រពៃហើយ ក្នុងព្រះពុទ្ធដ៏មានគុណមិនគប្បីរាប់ អាចឲ្យទាយកទាំងឡាយបាននូវផលានិសង្សច្រើនមិនមានប្រមាណបានឡើយ ម្យ៉ាងវិញទៀត ព្រះបរមក្សត្រិយ៍នេះ ទ្រង់មានលាភច្រើន ប្រសិនបើប្រាថ្នានូវទីសាវកដ៏ឧត្តមដូច្នេះថា សូមខ្ញុំព្រះអង្គជាអ្នកមានលាភជាងពួកភិក្ខុអ្នកមានលាភច្រើន ដូចភិក្ខុមាននាមថា សុទស្សន (នេះ) ដោយប្រការយ៉ាងណា សូមខ្ញុំព្រះអង្គបាននូវដំណែងនោះក្នុងកាលជាអនាគតដោយប្រការដូច្នោះចុះ ។

សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
សិវលី នាម នាមេន ហេស្សតិ សត្ថុ សាវកោ

ព្រះបរមគ្រូទ្រង់ព្រះនាមថាគោតមៈ ដោយនាមទ្រង់កើតក្នុងសក្យត្រកូល ក្នុងព្រះវង្សនៃព្រះបាទឱក្កាករាជក្នុងសែនកប្ប រាប់អំពីភទ្ទកប្បនេះសឹងនៅមានប្រាកដក្នុងលោក ឯព្រះបរមក្សត្រិយ៍អង្គនេះក៏នឹងបានជាឱរសជាធម្មទាយាទក្នុងធម្មវិន័យ តាំងជាបុត្រដែលព្រះធម៌តាក់តែងរបស់ព្រះគោតមសម្ពុទ្ធអង្គនោះ មាននាមថាសីវលីតាមនាមដើម ហើយជាសាវកនៃព្រះបរមសាស្តាចារ្យផងសឹងមានប្រាកដ ។

តេន បុញ្ញកម្មេនេវ ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសូបគោ អហំ

ដោយបុញ្ញកម្មនោះផង ដោយការដំកល់ចេតនាទាំងឡាយផង លុះខ្ញុំបានលះរាងកាយជារបស់មនុស្សហើយ បានចូលទៅកើតក្នុងភពឈ្មោះតាវតឹង្សទេវលោកនាយ ដោយពិត ។

ឥតោ អបរស្មឹ សមយេ វារាណសីបុរុត្តមេ
សេដ្ឋិបុត្តោ អហំ អាសឹ អឌ្ឍប្បត្តោ មហាធនំ
សហស្សមត្តេ បច្ចេក ទាយកោបិ និមន្តយឹ

មធុរេន អន្នបានេន សន្តប្បេសឹ សមាគតេ

លុះសម័យជាខាងក្រោយ ខ្ញុំបានច្យុតអំពីស្ថានឈ្មោះតាវតឹង្សនោះ ហើយ មកកើតជាសេដ្ឋបុត្តក្នុងនគរពារាណសី ជាបុរីដ៏ឧត្តម បានដល់នូវភាពជាអ្នកមានទ្រព្យសម្បត្តិច្រើនក្រៃលែង ហើយបាននិមន្តព្រះបច្ចេក-នាយកទាំងឡាយប្រមាណមួយពាន់អង្គដែល មានថ្ងៃដ៏ឬក្នុងកាលទាំងពួង ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយទឹងទឹកឆ្ងាញ់ពិសាពន់ពេក ។

តតោ ចុតោ ឥធាគមេ្ត អនុភោសឹ មហាយសំ

ទេវភូតបរិវុតោ បាសាទេ តេជាមយេ

ឯកានវុតិតោ កប្បេ វិបស្សី លោកនាយកោ

ឧប្បជ្ជិ ចារុទស្សនោ សព្វធម្មវិបស្សកោ

សម័យមួយទៀត ខ្ញុំបានច្យុតចាកអត្តភាពជារបស់មនុស្សនោះហើយ បានទៅសោយយសសម្បត្តិយ៉ាងធំធេងក្នុងកាមាវចរសួគ៌ទាំង ៦ ជាន់ សឹងមានស្រីទេពអប្សរហោមរោមជាបរិវារ ស្ថិតនៅក្នុងប្រាសាទកែវទាំងប្រាំពីរប្រការ ជាសុខក្សេមក្សាន្ត គ្រានោះ សម្តេចព្រះលោកនាយកព្រះនាមវិបស្សី ទ្រង់បានត្រាស់ដឹងនូវសម្បត្តិសព្វញ្ញុតញ្ញាណ កើតប្រាកដ ក្នុងកប្បកៅសិបមួយកប្បអំពីកន្លងកប្បយើងនេះ ។ ទ្រង់បានពិចារណាឃើញនូវធម៌ទាំងពួង ព្រះអង្គបញ្ចេញនូវឆព្វណ្ណរង្សីផ្សាយទៅក្នុងលោក ។

តទាហំ ពន្ធុមតិយា កុលស្សញ្ញតស្ស ច
ទយិតោ បត្ថិតោ បុត្តោ អាសិំ កម្មទាយតោ
តទា អញ្ញតរោ បុត្តោ វិបស្សិស្ស មហេសិនោ
បរិវេណំ អការេសិ មហន្តំ បីតិវិស្សុតំ
និដ្ឋិតេ បិ មហាទានំ ទទំ ខជ្ជកសំយុត្តំ
នវនីមធុញ្ចេវ វិចិនញ្ច អត្ថុសុំ
តទា កត្តំ គហោតាន នវនីមធុម្បិ ច
កម្មសាមិយវំគច្ចិ តមេសន្តាមមទ្ទសុំ

កាលនោះ ខ្ញុំបានកើតជាបុត្តនៃត្រកូលមាននាមមិនប្រាកដ គឺញាតិតែងអាណិតរាប់អានជាបុត្តគឺមាតានិងបិតាបានប្រាថ្នាហើយ ជាអ្នកខ្វល់ខ្វាយក្នុងការងារពុំដែលដាច់ មានបុត្តដទៃទៀតមាននាមនិងគោត្រក៏មិនប្រាកដ បានចាត់ដាក់ឲ្យធ្វើទីបរិវេណយ៉ាងធំមិនប្រាកដ ថ្វាយដល់ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី ដែលព្រះអង្គស្វែងរកគុណដ៏ប្រសើរក្នុងកាលនោះឯង ។ កាលបើទីបរិវេណបានធ្វើស្រេចហើយ បុត្តនោះក៏ចាត់ចែងឲ្យធ្វើមហាទានដ៏ប្រកបដោយបង្អែម ឯមនុស្សទាំងឡាយបានពិនិត្យមើលទានក៏ឃើញនៅខ្វះទធិស្រស់និងទឹកឃ្មុំស្រស់ពុំទាន់មានឡើយ គ្រានោះ បុរសទាំងឡាយដែលដើរស្វែងរកទធិនិងទឹកឃ្មុំនោះ បានឃើញខ្ញុំកាន់ថ្វាយនីងទធិស្រស់នឹងទឹកឃ្មុំស្រស់ ត្រាច់ទៅកាន់ព្រះដំណាក់

នៃព្រះបរមក្សត្រិយ៍ជាម្ចាស់ផែនដី ៗ

សហស្សម្បិ ទត្វាន ធលកឹ សុចតំ ទុយំ
តតោ ឃរំ វិចិន្តេសឹ ឈេតិះហោស្សតិឱរកំ
យថា ឥមេ ជនា សព្វេ សក្ការេន្តិ តថាគតំ
អហំ ការំ ការិស្សាមិ សសំឃេ លោកនាយកេ
តទាហមេវំ ចិន្តេត្វា ធនិមធុញ្ញ ឃរកោ
យោជេត្វា លោកនាថស្ស សសំឃស្ស អទាសិតំ
តេន កម្មេន ការេន ចេតនាបណីធីហិច
ហិត្វាន មានុសំ ទេហំ តាវតឹសអគច្ឆហំ

បុរសទាំងឡាយបានឲ្យប្រាក់មួយពាន់កហាបណៈហើយ ក៏នៅតែពុំបានទូវទធិនិងទឹកឃ្មុំនោះ ព្រោះខ្ញុំពុំព្រមលក់ឲ្យ លំដាប់នោះខ្ញុំបានគិតពិចារណាយ៉ាងនេះថា: វត្ថុនេះមិនមែនជាវត្ថុថោកទាបឡើយ ៗ បណ្ដាជនទាំងឡាយទាំងអស់នេះ គេបានធ្វើសក្ការបូជាព្រះតថាគតយ៉ាងណា អាត្មាអញនឹងធ្វើសក្ការបូជាសម្ដេចព្រះលោកនាយក ព្រមទាំងព្រះសង្ឃសាវកយ៉ាងនោះដែរ ៗ លុះខ្ញុំបានគិតពិចារណាយ៉ាងនេះហើយ ក៏ប្រមូលផ្សំទធិស្រស់និងទឹកឃ្មុំស្រស់ជាមួយគ្នាហើយបានថ្វាយនូវទធិនិងទឹកឃ្មុំនោះដល់ព្រះលោកនាថ ជាម្ចាស់ព្រមទាំងព្រះសង្ឃសាវកក្នុងកាលនោះឯង ៗ ដោយអំពើដែលខ្ញុំបានធ្វើនោះឯង ដោយសេចក្ដី

ប្រាថ្នា ដែលខ្ញុំបានដក់លប់បេតនាទាំងឡាយនោះផង ខ្ញុំក៏បានលះបង់រាងកាយជារបស់នៃមនុស្សហើយ បានអន្ទោលទៅកើតក្នុងស្ថានសួគ៌ឈ្មោះតាវតឹង្សពិត ។

បុនាហំ ពារាណសិយំ រាជា ហុត្វា មហាយសោ
សត្តុតស្សូតធារុន្ធា ទ្វាភិវតោរយឹ
តទា តបស្សិនោ រុន្ធា ឯកាហំ រក្ខិតោ អាហុ
តតោ តស្ស វិបាកេន បាបត្តំ និរយំ ភុសំ

ខ្ញុំបានកើតជាស្តេចក្នុងនគរពារាណសីទៀត ហើយមានយសបរិវាររេហ៍ពលច្រើន បានលើកកងទ័ពទៅព័ទ្ធស្តេចសោយរាជ្យក្នុងនគរតូចជាសត្រូវ ហើយចាត់រេហ៍ពលមិនឲ្យបើកបិទទ្វារនគរ មិនឲ្យមនុស្សចេញចូលយកស្បៀងអាហារក្នុងកាលនោះឯង ។

បន្ទាប់ពីនោះមក ខ្ញុំបានក្រោធខឹងនឹងតាបសមួយរូប ហើយបានចាត់មនុស្សឲ្យឃុំឃាំងតាបសនោះអស់មួយថ្ងៃ ដល់ខ្ញុំធ្វើមរណកាលទៅ បានទៅកើតក្នុងនរកសោយទុក្ខដ៏ក្តៀវក្លាដោយវិបាកនៃកម្មនោះឯង ។

បច្ឆិមេ បកវេភនិ ជាតោហំ កោលិយេ បុរេ
សុប្បវាសា ច មេ មាតា មហាលច្ឆវី មេ បិតា
ខត្តិយេ បុញ្ញកម្មេន ទ្វាររោធស្ស វាហសា
សត្តមាសវស្សានិ មាតុកុច្ឆិម្ហិ ទុក្ខិតោ

សត្តាហំ ទ្វារមុឡ្ហហំ មហាទុក្ខសមប្បិតោ

មាតា មេ ឆន្ទសាតេន ឯវមាសិ សុទុក្ខិតា

ដល់មកក្នុងភពជាទីបំផុតនេះ ខ្ញុំបានមកកើតក្នុងកោលិយបុរី ព្រះមាតារបស់ខ្ញុំមាននាមថាសុប្បវាសា ព្រះបិតារបស់ខ្ញុំមាននាមថា មហាលិច្ឆវីដោយពិត ៗ ខ្ញុំដល់នូវសេចក្តីទុក្ខលំបាកនៅក្នុងផ្ទៃនៃព្រះមាតាអស់កំណត់ ៧ ខែ ៧ ឆ្នាំ ព្រោះហេតុបាបកម្មដែលខ្ញុំបិទទ្វារព្រះនគរដោយបុញ្ញកម្មរបស់ខ្ញុំជាក្សត្រិយ៍ ៗ ខ្ញុំវង្វេងនៅក្នុងទ្វារកំណើត ៧ ថ្ងៃ ឆ្អែតដោយសេចក្តីទុក្ខយ៉ាងធំ ឯមាតានៃខ្ញុំទៀត ក៏ដល់នូវសេចក្តីទុក្ខដ៏ក្រៃលែងយ៉ាងនេះ ដោយកិរិយាឲ្យនូវឆន្ទៈ គឺប្រាប់នូវឧបាយបិទទ្វារតូចដល់ខ្ញុំ ៗ

(នៅមានត)

## មហោសថជាតក

(តមក)

លំដាប់នោះ ស្ដេចឈ្មោះព្រះបាទវិទេហរាជ ស្ដេចទៅពួងដល់ផ្នែកចន្លោះនៃយោជន៍១នោះ ក៏ដល់ស្រុកដែលព្រះមហាសត្វអ្នករណ្ដាប់ទុកនៅ ៗ រីអស់មនុស្សម្នាមហាជន កាលណាបើបានយល់ព្រះមហាក្សត្រហើយ សឹងត្រៀមយកដំរី សេះ រទេះ សឹងជ្រើសមានកម្លាំងមកថ្វាយស្ដេច ៗ ឲ្យដំរី សេះ រទេះណាដែលថយកម្លាំងអស់ដើរ ឲ្យត្រឡប់មកវិញហើយស្ដេចយកអស់ដំរី សេះ រទេះ មានកម្លាំងទាំងនោះ ស្ដេចឲ្យយកហោង ៗ រីស្ដេចយាត្រាដោយឆាប់ ៗ មានចម្ងាយផ្លូវនោះអនេក ១០០យោជន៍ ដោយនៅបាយកលនោះហោង លុះព្រឹកឡើងវិញ ស្ដេចចូលទៅក្នុងមិថិលានគរអំពីព្រឹកព្រហាមនោះហោង ៗ ពោធិសត្វអ្នកលីលាទៅកាន់ទ្វារឧមង្គ ហើយអ្នកដោះព្រះខ័នស្លាយអំពីអាត្មា ហើយអ្នកកកាយកប់លុបព្រះខ័នទៅឯខ្សាច់មហាឧមង្គនោះហោង ៗ កាលណាបើអ្នកទុកដាវនៅនោះហើយ អ្នកចូលទៅដោយឧមង្គ អ្នកឡើងទៅស្រង់ទឹកអប់ត្រឡប់គន្ធពិដោរ ស្រេចបរិភោគអាហារដ៏ត្រកាលមានឱជារសនោះផ្សេង ៗ ហើយអ្នកចូលទៅផ្ទំសម្រាន្តពួងដ៏បន្ទំប្រសើរ ហើយអ្នកគិតថា រីចំណង់ចិត្តប្រាថ្នានៃអញ ក៏លុះសំរេចបរិបូណ៌ហើយហ្ន៎ អ្នកគិតដូច្នោះហើយ អ្នកផ្ទំទៅហោង ៗ លំដាប់នោះ ព្រះបាទចុល្លនីព្រហ្មទត្តរាជ ស្ដេចពិភារណាក៏បំរុងប្រុងប្រយ័ត្នទូវពលគ្រប់គ្នា ទាំងសេនា

ទាំង ៨ ជំពូក ចូលទៅតាមឧបការនៃព្រះពោធិសត្វនោះ លុះអស់ចំណែកកត្រៃនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ អាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់វែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលនឹងភិក្ខុផងនូវបទព្រះគាថាថា : ។

រត្តិន្ទា កសិណំ រត្តំ ចុលនេយ្យោ មហាព្ពលោ
ឧទេន្តំ អរុណុគ្គម្ហិ ឧបការមុបាគមិ
អារុយ្ហ បវរំ នាគំ ពលវន្តំ សដ្ឋិហាយនំ
រាជា អវោច បញ្ចាលោ ចុលនេយ្យោ មហាព្ពលោ
សន្នទ្ធោ មណិចម្មេន សមាទាយ បាណិនា
បេសិយេ អជ្ឈភាសិត្ថ បុថុគុម្ពេ សមាគតេតិ ។

ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ ព្រះបាទចុឡនីព្រហ្មទត្តរាជ អាចមានកម្លាំងរេហ៍ពលសកលយោធាសេនាផងច្រើន ក៏តាមរក្សាព្យាបាលឧបការនៃព្រះមហោសថអ្នកប្រាជ្ញអស់រាត្រីនោះ លុះព្រឹកអរុណព្រះអាទិត្យឧទ័យឡើង បពិត្រអើយ ព្រះបាទចុឡនីព្រហ្មទត្តរាជមានរេហ៍ពលសកលយោធាសេនាផងច្រើន ជាអម្ចាស់នៃអ្នកបញ្ចាលរាស្ត្រទាំងឡាយ ស្តេចឡើងគង់លើបាដំរីព្រះទីនាំងដ៏ប្រកបនូវកម្លាំងមានអាយុ ៦០ ឆ្នាំហើយទើបថយកម្លាំងបន្តិច ស្តេចបន្ទូលបង្គាប់នឹង

សេនាអាត្មាព្រះអង្គថា បពិត្រអើយ ព្រះបាទចុឡនី ស្តេចទ្រង់គ្រឿង
ប្រដាប់គ្រោះក្រាយផងទាំងឡាយ សឹងតែវមណីរត្ន ព្រះហស្តស្តេចទ្រង់
នូវកង្វេពេជ្ររត្ន ស្តេចបន្ទូលទៅកាន់សេនាយោធាដែលធ្លាប់ដឹងនូវសំ-
ណឹកឈ្មោសប្រពៃ នៃសិល្បសាស្ត្រទាំងឡាយ ឲ្យមកជុំនុំព្រមពួងឥឡូវ
នេះហោង ។

ឥធានិ តេ សុរូបតោ ធសេស្នត្តិំ អាហា អាចារ្យទាំងឡាយ
គប្បីសំដែងអំពីសេនាទាំងនោះដោយសរុបជាបទគាថាថា : ។

ហត្ថារោហោ អនីកដ្ឋេ រថិកោ បត្តិការកោ
ឧបាសនម្ហិ កតហត្ថេ វាលវេធេ សមាគតេ ។

វីនាយដំរី នាយសេះ នាយរទេះទាំងឡាយ សេនាថ្មើរជើងនូវកំ-
ណាន់ខ្មាន់ការទាំងឡាយ សឹងដឹងឈ្មោសបេះសិល្បសាស្ត្របញ្ញាមុតមែន
ស្ទាត់ត្រង់ក្តាត់ ក៏មកជុំនុំព្រមគ្នា ។

ក្សណនោះ ព្រះបាទចុឡនីព្រហ្មទត្តរាជ ស្តេចបានបង្គាប់សេនា
ដើម្បីនឹងឲ្យគាត់យកនូវជីវិតនៃស្តេចវិទេហរាជ ហើយពោលថា ។

បេសេថ កុញ្ជរេ ទន្តី ពលវន្តេ សដ្ឋិហាយនេ
មទ្ទន្តុ កុញ្ជរា នគរំ វេទេហេន សមាបិតំ

។ល។

ឡៀទិសេហិ បុរក្ខិតោ ឆត្តំ មោក្ខា ឥតោ តរ

បកាវេច្ឆ ឧបសគ្គមិ យេន តំ មិថិលំ វជេតិ ។

តុម្ហេ ភោ ករោថ ម្នាលអ្នកទាំងឡាយដ៏ចំរើនអើយ ចូរអ្នកទាំងឡាយ បរដំរីទាំងឡាយចូលទៅ ដំរីនោះ ដ៏មានកុកនោះល្អ ដ៏មានកម្លាំងនោះច្រើនមានអាយុ ៦០ ឆ្នាំហើយ ទើបថយកម្លាំងបន្តិច រឺបាដំរីប្រសើរនោះ ចូរញីញាំបុកបែនទុបការនគរដែលគេប្រដាប់ប្រពៃ រឺយោធាទាហានកម្លោះទាំងឡាយ ដ៏កាន់គ្រឿងអាវុធដ៏មានជង្គនោះពិចិត្រ ដ៏មានក្បាលនោះពាក់នូវមួកដ៏ប្រពៃ ដ៏មានដៃកាន់នូវធ្នូសរថ្លា ហានក្លាកាប់បាញ់ទៅនូវកាំសរទាំងឡាយ ដ៏មានមុខថ្លាសមុតដូចមុខពន្លាកដ៏ស្រួចធ្មើម អាចបាញ់ទំលាយកំពាយផ្អឹងស្ពឹងជងកាំបិត រឺអស់កាំសរទាំងនោះចូរឲ្យជ្រុះចុះដូចទឹកភ្លៀងដ៏បង្អោរចុះមក ។ រីកូនស្តេចផងទាំងឡាយចូរបរនូវដំរីសារទុក្ខមធំអាចប្រទះមុខដំរីទាំងឡាយ ឬលំពែងទាំងឡាយដ៏ខាត់ជ្រះប្រពៃលាបនូវប្រេងមានរស្មីភ្លឺជ្រះល្អ បីដូចផ្កាយរង្សីដ៏មានរស្មីឮផងកណ្តាលអាកាស រីយោធាសេនាដ៏មានកម្លាំងខ្លាំង កាន់នូវគ្រឿងអាវុធទាំងឡាយ សឹងពាក់គ្រោះក្រោយ សំដីកកាយចំអេងដូចគ្រុឌប្រាកដមានសភាពយល់មុខដូច្នេះ ពុំដែលករត់រន្ធត់ទីងសង្គ្រាមឡើយ សឹងមានចិត្តមោះមានោមនះទិរេពទ្ធ អាចស្អិទជាបរឹងរនៃអញ ពុំដែលថុចថយដល់តិចឡើយ ទុព្រះវិទេហាកជអើយ គាត់ទីងរូបទៅឯណាឡើយ ខ្លាចតែគាត់មានស្លាបហើរទៅកណ្តាលអាកាស ដូចសត្វបក្សីនោះ ក៏ទីងហើរ

ហោះស្ទុះទៅកាន់នគរមិថិលានោះបានអេះ យោធាអញនេះ អញសឹង ឲ្យស្រិតស្រាលរើសសឹងតែពូក តាហានក្លាហានបានដឹងចិត្តនោះ មាន ៣ ម៉ឺន ៤ ពាន់ កំណាន់យោធាទាំងនោះ អញជ្រើសរើសគេយកនីមួយៗ អញពុំដែលយល់យោធាឯណាក៏ទឹងស្មើយោធាអញនេះឡើយ ហើយក៏ អាចផ្ចាញ់អស់យោធាទាំងឡាយ តែងដើរលើផែនដែននេះហោង ដំរី សអញទាំងនេះ មានក្តុកងប្រកបល្អនូវកម្លាំងខ្លាំង អាយុ ៦០ ឆ្នាំហើយ ទើបថយកម្លាំង នាយដំរីទាំងឡាយ សឹងចងរំស្រដគ្គ់ដំខ្ទាប់សំកប់ រាជកុមារ សឹងទ្រង់គ្រឿងប្រដាប់សំពត់ដណ្ដប់ឡើងជិះគដំរីទាំងឡាយ ល្អដូចទេវតាទេវបុត្រប្រាកដមាននៅឰដ៏ត្រ័យត្រឹង្សសួគ៌ ឯពួកយោធា ស្ពាយដាវទាំងនោះមានពណ៌ដូចត្រីឬកានខាត់នូវប្រេងនោះយល់ទេវតា មានដម្បាវនោះកបស្មើ គឺជាងផងទាំងឡាយធ្មើមក គេសរូសប្រពៃ ឲ្យគ្រៀលលេបបាន ៧ ដង ហើយទើបមកធ្គុំជាដាវនីមួយៗ ដ៏ប្រកប នូវផងមាសដ៏ប្រាសលែងមានស្នឹម ល្អប្រពៃព្រោងព្រាយសន្ធោសន្ធៅ ដូចរស្មីព្រះអាទិត្យនាថ្ងៃត្រង់ គឺយោធាទាំងឡាយដ៏មានកម្លាំងខ្លាំង អស្ចារ្យ សត្រូវផងនានាខ្ចបខ្លាច គរកាន់ដាវនោះហើយ ហូតចេញអំពី ស្រោម នោះយល់ពណ៌ពពាលថ្វាដូចព្រះឥន្ទ្រនៅប្រកត់ឰដ៏ស្រពាប់មេឃ ក្រាស យោធាខ្លះសោតមានដៃកាន់នូវខែល កាន់ដាវនូវសេលោស្ទាត់ ស្ទុះឡើងទៅឰដ៏កណ្ដាលអាកាសបាន ខាន់ឆ្ងូទាំងឡាយសោត ចេះ

កាន់ផ្លូវស្ទាត់ជំនាញពេកក្តាត់ អាចបាញ់កំចាត់ស្លាប់មនុស្សទាំងឡាយ ដែលជិះលើក្បាលដំរីដំរុះឲ្យជ្រុះបាន ។ ឯតានិ សោ ហិ មិថិលា វេជេតិ អម្ភោ វេទេហ ។ វេទេហ ម្នាលព្រះវិទេហរាជអើយ គឺយោធាអញទាំងនេះសឹងមានថ្វីដៃដ៏ទៀបចំណោះប្រាកដដូច្នេះ មកពោមព័ទ្ធព័ទ្ធជុំវិញ តើព្រះស្តេចនឹងរួចទៅនោះឥតអង្គីមានឡើយ ហើយព្រះស្តេចនឹងទៅកាន់មិថិលានគរដោយអានុភាពស្តេចឯណា ក៏អញមិនយល់នូវអានុភាពស្តេចនោះសោះ តើព្រះស្តេចនឹងរត់ទៅឯណាបានឡើយបពិត្រអើយ ព្រះបាទចុឡនីព្រហ្មទត្តរាជ ស្តេចទ្រង់នូវកង្វៀពេជ្ររត្នមហាក្សត្រទោគបរដ៏ព្រះទីនាំង ចូលមក នឹងគំរាមព្រះបាទវិទេហរាជដូច្នេះថា ឥឡូវនេះ អញនឹងចាប់យកព្រះបាទវិទេហរាជ ឲ្យលុះនូវក្ស័យជីវិត ស្តេចបង្គាប់អស់សេនាទាំងឡាយថា ម្នាលគ្នាយើងទាំងឡាយចាប់យកព្រះបាទវិទេហរាជនូវមហោសថ បុត្រគហបតីបានមកហើយចូរយកដឹងមកពុះទំលុះទម្លាយកំចាយទ្រូង ចូរចាក់កាប់សម្លាប់ កុំបីឲ្យយូរឡើយ ព្រះបាទចុឡនីចូលទៅកាន់ឧមគ្គនគរ គ្រានោះហាក់ដូចនឹងសង្គ្រប់ហោង ។ លំដាប់នោះ ឧបនិវិត្តបុរសធំទាំងឡាយ យកបុរសដែលបំរើគ្នាដោយគិតថា អ្នកឯណានឹងអាចដឹងជាម្តេច ម៉្លោះហើយសឹងនាំគ្នាចូលមកស្តាប់ព្រះបន្ទូលនៃព្រះបាទចុឡនី ហើយក៏ចូលទៅពោមរោមផាបរិករនោះហោង ។ តស្មឹ ខណេ ពោធិសត្តោ

សិរីសយណា រុង្គាយ ៗ ក្សណនោះ ពោធិសត្វមហាបុរសរត្ន
វិសេស ដោះឡើងអំពីល្អែងមានសិរីសួស្តី មកស្រង់ដំរះព្រះអង្គ ហើយ
អ្នកបរិភោគភោជនាហារក្រកាល មានទុជារសពិសាអំពីព្រឹក ហើយអ្នក
ទ្រង់នូវគ្រឿងប្រដាប់តាំងពួង ស្លៀកសំពត់កាសិកពស្ត្រ មានតម្លៃមួយ
សែនតម្លឹង ហើយយកសំពត់រត្តកម្ពលមកស្ពាយឆៀងឯស្មាខាងបណ្ដោយ
ហើយអ្នកកាន់ផ្ទិតដ៏មានដងពិចិត្ររត្នទាំង ៧ ប្រការ ហើយពាក់នូវសុ-
ពណ៌បាទុក អ្នកយកស្រីពីរនាក់ល្អដូចស្រីសួគ៌ មកឲ្យក្រវាសបក់ផាត់
ស្រេចហើយ អ្នកបើកបង្អួចប្រាសាទនឹងបង្ហាញអាត្មា ឲ្យយល់ចំពោះ
ព្រះភក្ត្រព្រះបាទចុល្យនី អ្នកដើរទៅវិញទៅមក សក្កទេវកដលីលា
មានដំណើរលំអដូចសម្ដេចឥន្ទ្រាធិកដលីលាខាហានសួគ៌ មុខគួរពិតពិល
រមិលមើល ៗ ឯព្រះបាទចុល្យនីព្រហ្មទត្តរាជ ស្ដេចទតយល់លំអស្រីសួស្តី
នៃពោធិសត្វនោះ ពុំអាចដើម្បីនឹងមានព្រះទ័យត្រេកអរសោទរនឹងពោធិ
សត្វនោះដល់តិចឡើយ ហើយបរដំរីព្រះទីនាំងដោយនូវក្រអាលចូលមក
ដោយគិតថា អញនឹងចាប់យកព្រះមហោសថឥឡូវនេះឯង ៗ ព្រះ
មហោសថអ្នកប្រាជ្ញគិតថា ព្រះបាទចុល្យនីម្មាចូលមកនេះ ដោយ
ទុកព្រះទ័យថា ព្រះបាទវិទេហរាជសមបាទអញហោង ស្ដេចមិនជ្រាប
សភាពជាអញឲ្យចាប់យកអស់បុត្រភរិយាទេហ្ន៎ ថាបើដូច្នោះ អញនឹង
បង្ហាញអាត្មា ឲ្យស្ដេចយល់មុខអញល្អដូចពពិលមាស ហើយអញនឹង

សំដែងប្រាប់ស្រដីមួយអន្លើនឹងស្តេចនេះ ។ បពិត្រអើយ ព្រះមហាសថ អ្នកបិតនៅញ៉ាំងហានសីហបញ្ជរបវរបល្ល័ង្ក ហើយអ្នកបើកព្រះសូរមធុរមូល ក្រឹតពីរោះស្មោះជាដម្បូងទៅកាន់ស្តេចនេះថា ។

កឹំ នុ សន្តរមានោវ ធាតំ បេសេសិ កុញ្ជរំ
បហដ្ឋរូបោ អាគមសិ លទ្ធត្ថោស្មិ តំ មញ្ញសិ
ទុំ ហារេតំ ឆដ្ឋុបាទំ ខុរប្បំ បដិសំហារ
ទុំ ហារេតំ សុកំ ធម្មំ វេឡុរិយមណិសន្និភន្តិ ។

មហារាជ បពិត្រព្រះកូមិន្ទនរិន្ទនរាធិបព្រះបាទនរបតីស្រីសម្មតិ-
ទេពមហារាជក្សត្រថ្លៃប្រសើរអើយ ម្តេចឡើយក៏ស្តេចត្រាស់លម្អីយាធាប់ប្រញាប់បរទូលបាដ៏វីព្រះទីនាំងប្រសើរ បហដ្ឋរូបោ សមព្រះអង្គទ្រង់ព្រះអំណរសាទរទុកព្រះពជហឫទ័យថ្លៃថ្លាស្មោះស្មានសន្និដ្ឋានថា ទីង បានដូចក្នានព្រះចំណង់ប្រាថ្នាលុះដល់បរិបូណ៌ ទើបស្តេចលីលាចូលមកដូច្នោះ ចូរមហារាជឲ្យតម្មោះធ្លូស្នាដ៏មានចង្កូយទ្រវូយល្អ ១ ក្រែងរាមិនអាចទឹងកោងកុះអាក្រក់ ព្រះអង្គឲ្យខ្វាន់តម្ងើងកាន់ប្រូងប្រាងមកនោះ តើឲ្យបាញ់នរណា នាគាំព្រាបស្វាបទុងផ្លង់ល្អយកប្រកបំពង់រ៉ា មហារាជអើយនាដាវព្រះអង្គឲ្យហូតត្រីថ្វីដ៏ពន្លឺកមកនោះ តើព្រះអង្គទឹងឲ្យកាប់នរណាឯដែកនោះសាត តិតឲ្យជាងកោសរូសឲ្យក្រៀលរ៉ាលេចស៊ី ៧ ដងទើបយកមកផ្គុំដំជាដាវគនប៉ផ្នែកផ្លង់យង់ល្អ ព្រះអង្គឲ្យប្រកស្រោមទុក

ស្តាយខ្លាចពស្នឹមអាក្រក់ បពិត្រក្សត្រថ្លៃប្រសើរអើយ រីសេះឈ្មោះ ព្រះអង្គឲ្យជាងធ្វើទឹងស្បែកចំឡែកមហិមារចនាដោយនូវពិទូរគន់ប្រពៃ ព្រះអង្គឲ្យកាន់សម្ងាចស្ងាចមកថ្វីអសារ ឥតការស្ដាយរ៉ា ទឹងចាស់ អាក្រក់ ព្រះអង្គឲ្យរុំទុកវា មហារាជអើយ ព្រះអង្គឲ្យយកគ្រឿងអាវុធតាំងពួងមក ស្បែកនោះ ទឹងមានប្រយោជន៍អ្វីដល់ព្រះអង្គឡើយ វាជាអសារឥតការទេ ព្រះមហោសថអ្នកដ៏ប៉ិនលេងជាល្បែងមួយសារវិញទៀតថា ព្រះមហារាជ ព្រះអង្គគង់ថ្វីនៅនេះហ៎ះ? ខ្ញុំបង់អញ្ជើញព្រះអង្គស្ដេចលីលាគ្រឡប់ចូល ទៅក្នុង ព្រះនគរព្រះអង្គបន្តិចមើលហ៎ះ ឲ្យប្រណីព្រះអង្គបង់ទឹងព្រួយ ទៀយព្រះរាជហឫទ័យ កលម្ដេចឥឡូវអើយ ។

សោ តស្ស វចនំ សុត្វា អយំ គហបតិបុត្តោ
មយា សទ្ធឹ គោឡ្យ ករោតិ អជ្ជ តេ កាត្តុំ
ជាតិសប្បមីតិ តំ តជ្ជេន្តោ អាហ

ព្រះបាទចុឡនីមហាក្សត្រស្ដាប់ពាក្យមហោសថអ្នកប្រាជ្ញលេងទៅថា ល្បែងដូច្នោះហើយ ស្ដេចគិតក្នុងព្រះរាជហឫទ័យថា មហោសថបុត្រ គហបតីនេះ ម្ដេចក៏មកស្រដីធ្វើជាល្បែងមកកាន់អញដូច្នេះនេះហ៎ះ ទុក ធ្វើហាក់ដូចជាមិនដឹងខ្លួននោះសោះ ក៏អញទឹងធ្វើទុក្ខវានៅថ្ងៃនេះឯង ទើបស្ដេចគម្រាមព្រះមហោសថ ហើយពោលនូវបទគាថានេះថា ។

បសន្នមុខោ នន្ទាសិ បិហិតបុញ្ញោ ភាសតិ

ហោតិ ខោ មរណ កាលេ ឦទិសី វណ្ណសម្បត្តិ

ហៃចៅមហោសថអើយ ចៅមានរស្មីមកនោះរុងរឿងស្រឡះថ្លាល្អ ដូចអ្នកយកពពឹលមាសគិតអ្នកខាត់ប្រពៃយល់ញញឹមប្រិមប្រិយ៍ ស្រដីគួរស្រឡាញ់ បទធម្មតាទៅទីស្លាប់ហើយរាយលំសទៀត មានមុខសម្បុរនោះល្អចេះឯង អញទឹងលែងអន្ទាល់ទៀត អញទឹងកាត់យកក្បាលទៅដំកល់អង្គុយមើលមុខជាល្អនោះហើយ ក៏ផឹកស្រាដ័យបានកំ-សាន្តចិត្តអញបានហោង ៗ

កាលព្រះមហោសថស្រដីដំបូចទឹងព្រះបាទចុឡនីនោះ អស់ពពួកសកលយោធាផង យល់ព្រះកក្រពោធិសត្វស្រស់ល្អនៅនាបន្ទប់នោះថា ឱព្រះមហោសថអ្នកប្រាជ្ញអើយ ល្អអ៊ីអម្បាយ ក៏មហាក្សត្រអម្ចាស់យើងបន្ទូលអ៊ីទឹងព្រះមហោសថ ចូរអ្នកកល់គ្នាទៅឲ្យទៀបទឹងស្ដាប់ពាក្យអ្នកតាំងពីស្រដីថាអ៊ី ទើបបបួលគ្នាចូលមូលមកទន្ទុំនៅទៀបមហាក្សត្រ ៗ គាថិតមេវ ជា ជាតិ ៗ ព្រះមហោសថអ្នកប្រាជ្ញស្ដាប់ព្រះបន្ទូលព្រះបាទចុឡនីនោះហើយ អ្នកគិតថា មហាក្សត្រនេះមិនដឹងប្រាជ្ញាព្រះមហោ-សថទេហ្ន៎ អញអ៊ូទៅឲ្យសម្លាប់បានដូចបំណងព្រះរាជហឫទ័យនោះ អ្នកគិតដូច្នោះហើយ អ្នកទូលមហាក្សត្រថា បពិត្រមហារាជអើយ ព្រះអង្គស្ដាប់ពាក្យខ្ញុំណា ឯគំនិតព្រះអង្គគិតនោះ រាបែកអស់ហើយ បពិត្រមហារាជអើយ នាព្រះគំនិតព្រះអង្គគិតនោះក្ដី អាចារ្យកេវដ្ដព្រាហ្មណ៍

គិតនោះក្តី តែដង្ហើមចេញពីព្រះនាសា ព្រះអគ្គិគិតស្មានថាខ្ញុំមិនដឹង ខ្ញុំដឹងព្រះគំនិត ព្រះអគ្គិនោះនឹងបានជាអ្វីឡើយ រាបែកអស់ហើយ លំ

បកាសេន្តោ សត្ថា អាហ ភិក្ខវេ ហៃភិក្ខុផងទាំងឡាយ

អើយ កាលព្រះមហោសថអ្នកប្រាជ្ញទូលព្រះបាទចុឡនីថា បពិត្រមហារាជអើយ នាពាក្យកំបាំងព្រះអគ្គិ នឹងអាចារ្យកេវដ្តព្រាហ្មណ៍ចូលទៅក្នុងក្រឡាបន្ទំសុខុមទាំងពីរនាក់ហើយ តែងរិះគិតថានឹងយកសម្តេចព្រះរាជបុត្រីហ្វាងព្រះបាទវិទេហរាជឲ្យបានដូចគ្នាទគំនិត ហើយនឹងកាត់គយកក្បាលព្រះបាទវិទេហរាជ ហើយនឹងកាត់យកក្បាលខ្ញុំផង បំងអគ្គិយលើកជីកស្រាជ័យបាន ឯជំរិះគិតក្តី បំណងប្រាថ្នាព្រះអគ្គិនោះក្តី រាមិនលុះសោះសូន្យទេ ព្រះគំនិតព្រះអគ្គិនោះ កិច្ចំ រាបែកអសារទទេហើយ បពិត្រមហារាជអើយ នាព្រះអគ្គិនឹងយកព្រះបាទវិទេហរាជអម្ចាស់ខ្ញុំនោះរាកម្រនឹងបានទេណា បទព្រះបាទវិទេហរាជអ្នកជិះលើប្រាជ្ញាគំនិត ព្រះមហោសថស្មើអ្នកគង់លើខ្នងសេះអាជានេយ្យ មានកម្លាំងខ្លាំងស្មើខ្យល់ ហោះផ្ទោះកណ្តាលអាកាស តើព្រះអគ្គិគង់លើប្រាជ្ញាគំនិតបានទេ គំនិតប្រាជ្ញាអាចារ្យកេវដ្តព្រាហ្មណ៍ដូចសេះខ្វាក់ ចចកចាស់ដើរផ្ទាស ៗ កណ្តាលដី តើព្រះអគ្គិនឹងតាមទាន់ព្រះបាទវិទេហរាជទេហ៎ះ ៗ

តិណ្ណោ ហិយ្យោ រាជា កត្តិ សាមច្ចោ សបរិជ្ជនោ

ហំសកំ យថា ជង្ឃា អនុជវំ បតិសុត្តិតិ ។

បពិត្រមហារាជអើយ ព្រះបាទវេទេហរាជទ្រង់អាមាត្យសេនាបតី ពលសកលយោធាផង ស្ដេចចម្លងស្ទឹងគង្គាលិទ្ទាគ្រាម លីលាដល់ត្រើយនាយម្សិលមិញហើយ ថាបើព្រះអង្គនឹងតាមព្រះបាទវេទេហរាជអម្ចាស់ខ្ញុំមហារាជសមព្រះអង្គនឹងបានដល់នូវអន្ទាក់កណ្ដាលផ្លូវពុំខាន បទព្រះអង្គគង់លើប្រាជ្ញាអាចារ្យកេវដ្ដព្រាហ្មណ៍ ដូចកលអ្នកជិះលើក្អែកចាស់ ព្រះបាទវេទេហរាជជិះលើប្រាជ្ញាខ្ញុំ ដូចរាជហង្សមាស គឺមានកម្លាំងឆាប់ស្មើខ្យល់ ហើរទៅកណ្ដាលអាកាស កម្លាំងក្អែកចាស់ ក៏ហើរទៅតាមម្ដេចទាន់បាន នឹងធ្លាក់មកនាកណ្ដាលដី អន្ទាក់ប្រាកដមិនលែងឡើយ ។

ពោធិសត្វអ្នកនាំឧទាហរណ៍មកទៀត ទូលព្រះបាទចុឡនីនូវពាក្យសីហនាទជាគគាតដូចកេសររាជសីហ៍ ពុំក្លកម្រឹគទាំងឡាយ ហើយពោលនូវបទគាថាដូច្នេះ ។

សិង្គាលោវ រត្តិភាគេ ជុល្លំ និស្វាន កឹសុកំ
មំសបេសីតិ មញ្ញន្តា បរិព្យូឡ្ហា មិគាធមា
វីតិវត្តាសុ រត្តីសុ ឧគ្គតស្មឹ ទិវាករេ
កឹសុកំ ផុល្លិតំ ទិស្វា អាសាឆិន្នា មិគាធមា
ឯវមេវ តុវំ រាជ វេទេហំ បរិវារយ

អាសាធិន្នា គមិស្សសិ សិង្គាលា គិំសុកំ យថាតិ។

បពិត្រមហារាជអើយ នាព្រះអង្គមកតាមចាប់ព្រះបាទវិទេហរាជអម្ចាស់ខ្ញុំនេះ ទឹងបានអង្កាល់ឡើយ វាទឹងអសារឥតការទេណាមហារាជ បពិត្រមហារាជអើយ ព្រះអង្គនេះដូចចចកឯង កាលណាបើព្រះអាទិត្យអស្តង្គតហើយ ព្រះចន្ទផុសឡើង មានពន្លឺបែងគ្រប់ជ្រះកណ្តាលផ្កាយ ពណ៌កយល្អ យកគ្នាបណ្តើរហៅទៅយល់ផ្កាចារស្មោលឲ្យយាន ៗ ទុកចិត្តស្មានថាជាជៀតសាច់គោហាលក៏អរមហិមា បបួលគ្នាមកតាមចាំជុំវិញដើមចារ ទន្ទឹងថាដល់ណាពទឹងរុះបុះមកទឹងអាលយកធី លុះព្រឹកព្រហាម ព្រះអាទិត្យទុទ័យឡើង ឯចចកបបួលគ្នាឈរមើលហង៌ហើបឡើង យល់តែផ្កាចារប្រាលស្វាចទេ រីឯក្តីប្រាថ្នានោះ វាំពុំសម្រេចបុញជាច់អាល័យហើយនៃ ក៏បបួលគ្នាដើរហៅចេញទៅអសារឥតការទេណា ក៏ចចកចចើងចាំបរិភោគអសារមេច្ចមិញ មហារាជអើយ នាព្រះអង្គចចើងចាំហោមព្រះបាទវិទេហរាជអស់កំឡុងកត្រីនេះ លុះតែព្រឹកឡើងក៏ព្រះអង្គមិនបានព្រះបាទវិទេហរាជឡើយ ដូចព្រះគំនិតនោះហើយអសារឥតការទេដូច្នោះហោង ៗ

កាជា តស្ស តំ អច្ចម្ភីតរបចំ សុត្វា បិនេ្ខសិ

ព្រះបាទចុឡនី ស្តាប់ ពាក្យពោធិសត្វស្រដីសីហនាទឥតក្តីកក្កូរក៏គិតគុំព្រះទ័យថា មហោសថបុត្តគហបតីនេះ រុកពនហើនស្រដីណាស់

ក្តាត់ហះ នាដោយមហោសថស្រដីនេះ សមព្រះបាទវិទេហរាជរត់ព្រា-
រួចមិនទេឡើយ មហាក្សត្រគិតដូច្នោះហើយ ក៏ខ្ញាល់នឹងព្រះមហោសថ
មហិមាក្រៃពេក ក៏រិះគិតយល់ទោសព្រះពោធិសត្វថា នាមហោសថនេះ
ពីរដងនឹងអញហើយ កាលម្ដងពីមុននាយឡើយនោះ អញទៅតាម
មិថិលានគរប៉ុនប៉ងបំណងប្រាថ្នានឹងចាប់ព្រះបាទវិទេហរាជហើយអេះ
ស្រាប់តែវាមកបន្លើលឲ្យផ្អើលអស់ពលសកលយោធាទាំង ១៨ អក្ខោភិនី
នូវស្ដេច ១០១ ឲ្យភិតភ័យរត់ សំពត់មិនបិតនៅចង្កេះ សេះ ដំរី គ្រឿង
អាវុធខ្ចាត់ខ្ចាយពោលបង់មៀត ឥឡូវនេះសត្រូវមកលុះកណ្ដាប់ដៃអញ
ហើយ ក៏វាបំផាយឲ្យរត់រួចទៅនោះហោង ៗ អឆ្កការពេក ៗ វាធ្វើ
ឲ្យបង់ប្រយោជន៍អញច្រើន នាអញគិតក្នុងចិត្ត អញនឹងសម្លាប់ព្រះបាទវិ-
ទេហរាជហើយនិងមហោសថផង រីសេចក្ដីបំណងប្រាថ្នានៃព្រះបាទវិទេ-
ហរាជនោះវាបានសម្រេចហើយ ឥឡូវនៅតែមហោសថ អញអើយទៅ
ទុកឲ្យវាមានជីវិតរស់នៅក្តី អញធ្វើទុក្ខឲ្យល្អិតបង់មៀតទៅ ទើបមហា-
ក្សត្របង្គាប់ទៅសេនាឲ្យសម្លាប់ព្រះមហោសថដោយនូវបទគាថាថា: ៗ

ឥមស្ស ហត្ថបាទេ ច កណ្ណនាសញ្ច ឆិន្ទថ
យោ មេ អមិត្តំ ហត្ថគតំ វេទេហំ បរិមោចយិ

ៗ ល ៗ

ឯវន្តំ វិត្ថុនិត្វាន វេធយិស្សាមិ សត្តិយា

យោ មេ អមិត្តំ ហត្ថគតំ វេទេហំ បរិមោចយិតិ ។

ម្នាលសេនាទាំងឡាយអើយ លោកដែលដូចមហោសថហ្ន៎ះ នាំព្រះបាទវិទេហរាជជាសត្រូវនឹងអញនេះ ចូលមកលុះកណ្ដាប់ដៃអញហើយ ស៊ូរាប់ដាយឲ្យរត់រួចចេញទៅវិញ តើគប្បីប្ដូរអ្នកទាំងឡាយតើចកមហោសថបុត្តគហបតី យកមកកាត់ដៃទាំងសងខាង ចិតស្ទីកត្រចៀកនឹងច្រមុះ ពុះទ្រូង ដាំទឹកក្ដៅទឹងខ្លះ បន្ទះសាច់ស្ងោរឡើងពេលដូចសាច់ម្រឹគ ប្ដូរសំរួចឈើអណ្ដាត ។ ឡើងដែលមានសត្រូវចូលមកលុះកណ្ដាប់ដៃនៃអញហើយឲ្យរួចទៅវិញ ម្នាលសេនាទាំងឡាយ ប្ដូរអ្នកចាប់មហោសថនោះមកសន្ធឹក កាត់យកក្បាល លាត់ស្បែកមកស្ងោរកណ្ដាលដីសន្ធឹងគឹងឲ្យណាស់ ដូចគេស្ងោរស្បែកគោទាំងឡាយ យកលំពែងធំ ៗ ចាក់ប្រំលំអិតឲ្យល្អិតបង់មៀតទៅ ព្រះបាទវិទេហរាជនេះ ជាសត្រូវអញលួងមកលុះកណ្ដាប់ដៃហើយ វាឲ្យដំណើរសត្រូវរត់រួចទៅហ្ន៎ះ ។

ព្រះមហោសថអ្នកស្ដាប់ព្រះបន្ទូលព្រះបាទចុឡនីហើយ អ្នកពុំភ្ញឹកភាំងកិតខ្លាចដល់តិចឡើយ អ្នកទ្រង់ព្រះសំណើចក្អាក ១ ទើបអ្នកទ្រង់ព្រះពិតារណាថា នាមហាក្សត្រនេះជ្រាបសភាពតែព្រះបាទវិទេហរាជរួចទៅមិថិលានគរ មិនដឹងដើមអញឲ្យដំណើរអស់ព្រះរាជបុត្របុត្រា នូវព្រះរាជទេពី ព្រះមាតាទៅជាមួយនឹងព្រះបាទវិទេហរាជអម្ចាស់អញចេញទៅដល់មិថិលានគរនោះឡើយ ទើបមហាក្សត្រខ្ញាល់គុំឲ្យសម្លាប់អញ

យល់មហាក្សត្រខ្វាល់នឹងអញមហិមា មិនទេឡើយ លើកទ័ពអស់ស្ដេច ១០១ នូវពល ១៨ អក្ខោភិនីទំលាយចូលមកយកអញបាន ដោយនូវព្រះរាជាជាមហាក្សត្រនោះឯង ក៏ឥឡូវនេះ បន្ទាយអញតូចមានពលសេនាតិច នឹងផ្ចាញ់មហាក្សត្រនោះពុំបាន នាអញនឹងផ្ចាញ់មហាក្សត្រនេះ ដោយនូវកម្លាំងសាហាវសោះសាពុំបានឡើយ អញផ្ចាញ់តែនឹងប្រាជ្ញាបារមីឧបាយកលវិញទើបបាន ក៏អញនឹងរិះរកនូវឧបាយកលម្ដេចអេះ ព្រះមហោសថអ្នកចប់រិះទៅច្នោះក្ដី ហេតុតែព្រះបារមីព្រះអង្គបានសាងនោះបរិបូណ៌ នឹងបានជាពុទ្ធង្កូលបណ្ដូលប្រាជ្ញាសារពេជ្ញតាញាណ អ្នករិះទៅដូច្នោះហើយក្ដី ប្រាជ្ញាបារមីមកបំភ្លឺយល់ប្រុះស្រុសសារពើឧបាយកលនឹងផ្ចាញ់មហាក្សត្រនេះបានទៀងប្រាកដ ទើបអ្នកគិតថា អញអ៊ីទៅឲ្យសម្លាប់បានដូច្នោះ មិនដឹងប្រាជ្ញាអញមហោសថ អញនឹងពោធឧបាយកលមួយដោយប្រាជ្ញាបារមីអញ ឲ្យជ្រាបក្នុងព្រះហឫទ័យមហាក្សត្រ ឲ្យទន់ទនលំទោនទៅវិញ ហើយអញនឹងធ្វើឲ្យមហាក្សត្រនេះ លុះនៅជម្ងឺវេទនាជាទុក្ខសោកនោះមហិមាសន្ធប់ក្រាបនៅ

(នៅមានត)

ពន្លឺភ្លឺថាគឺបញ្ញា ជនផងនានាគួរសន្សំ

ទុកជាអាវុធពេជ្រឧត្តម ឧបសគ្គតូចធំទប់ពុំបាន ។

ធ. ជ្រីវ

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរត្រូវថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មាំ
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប. ៣.

(វិចារណកថា)

# កិត្តិយសនឹងសុភមង្គល

លោក ផេង-ច្រីវ រៀបរៀង

ភាពរុងរឿង ភាពល្បីឮខ្ចរខ្ចាយ ដោយសារស្នាដៃប្រកបដោយអត្ថប្រយោជន៍សាធារណៈនៃខ្លួនហៅថា « កិត្តិយស » ជាភាពដែលមនុស្សត្រូវការយ៉ាងខ្លាំងពន់ពេក ៗ ប៉ុន្តែកិត្តិយសមានច្រើនក្នុងលោក សម្រាប់មនុស្សម្ដុំទេ? តាមការពិចារណា កិត្តិយសមិនប្លែកគ្នាពីសេចក្តីសុខឡើយ សេចក្តីសុខមាននៅក្នុងលោកពាសពេញ ស្រេចនឹងអ្នកត្រូវការខំប្រឹងស្វែងរកប្រមូលមកចុះ បើខ្លួនចេះរកបាន ៗ

ដូចជនណាម្នាក់កើតជ្រះថ្លាយល់ត្រូវ ចំណាយទ្រព្យផ្ទាល់ខ្លួនកសាងសាលារៀនសាធារណៈ ឬកសាងមន្ទីរពេទ្យជាប្រយោជន៍សា-

ធារណៈជាអាទិ៍ ជននោះមានកិត្តិយសជាប្រាកដ អ្នកផងតែងគោរពសរសើរនិងមានការកោតក្រែងកប់អាន ។ អ្នកខ្លះបានទទួលឋានៈជាមន្ត្រីមួយក្នុងកិច្ចការពេជការ ក៏មានឈ្មោះថាអ្នកមានកិត្តិយសដែរ ។ល។

សម្ដេចព្រះឧបេក្ខមសីហនុឧបយុវរាជ ព្រះប្រមុខរដ្ឋប្រទេសកម្ពុជាព្រះអង្គទ្រង់បរិបូណ៌ដោយកិត្តិយសដ៏លើសលប់ ព្រោះព្រះអង្គបានទ្រង់ស៊ូប្តូរព្រះជន្ម ដើម្បីតាមទារយកឯករាជ្យកម្ពុជា មកជូនមាតុភូមិនិងជាតិខ្មែរ ឃើញថាអំពើរបស់ព្រះអង្គនេះជាមហាកម្មដ៏អស្ចារ្យ ដែលនឹងរកឥស្សរជនខ្មែរណាមកប្រៀបផ្ទឹមនឹងព្រះអង្គពុំបាន មិនតែប៉ុណ្ណោះ ព្រះអង្គទ្រង់ជាស៊ីម៉ង់សម្រាប់ផ្សាប្រជាជាតិខ្មែរ ដែលមានការប្រេះឆាក្នុងពេលមុនរវាងគ្នានិងគ្នាខ្លះនោះ ឲ្យមានការរួមគ្នា ស្រុះស្រួលនឹងគ្នាឡើងវិញ ហើយព្រះអង្គទ្រង់ជាព្រះអគ្គមគ្គុទ្ទេសក៏ផ្ដើមគ្រប់វិស័យទាំងអស់ផង ដើម្បីធ្វើឲ្យជនជាតិខ្មែរមានសន្តិសុខនិងសន្តិភាព ដែលជាប្រភពនៃសេចក្តីចំរើនរុងរឿងនៃប្រទេស ។ល។

សួរថា : គ្រប់តែមនុស្ស សុទ្ធសឹងមានកិត្តិយសឬយ៉ាងណា? -កិត្តិយសជាលទ្ធផលឬជាអានិសង្ស នៃអំពើប្រកបដោយសាធារណប្រយោជន៍ ។ ដូច្នេះ មនុស្សខ្លះទន់ខ្សោយពេក ដែលមិនអាចនឹងធ្វើនូវអំពើជាសាធារណប្រយោជន៍បាន ក៏គ្មានកិត្តិយសទេ មនុស្សនេះរស់នៅគ្រាន់តែកេស៊ីដើម្បីជីវិតខ្លួនប៉ុណ្ណោះ ក៏ប៉ុន្តែ បើជាគេយល់ការណ៍

ច្បាស់ គេអាចរកកិត្តិយសរួមបានដែរ គឺគេប្រមូលកំឡាំងតូចៗ ដែលខ្លួនមាន យកមកធ្វើជាមហាកម្មអ្វីមួយជាសាធារណប្រយោជន៍ គំនិតបែបនេះអាចបណ្តុះកិត្តិយសសម្រាប់ខ្លួនបានៗ ដូច្នេះ បានជាបច្ចុប្បន្នសម័យសម័យសង្គម ឃើញមានមន្ទីរពេទ្យនឹងសាលារៀនផុសដូចផ្សិត នៅគ្រប់ភូមិស្រុក ដែលផ្តល់កិត្តិយសដល់អ្នកភូមិស្រុកនោះៗគ្រប់គ្នា ។

សួរថា កិត្តិយសដែលគេទុកជាវត្ថុជាទីប្រសើរ ហើយដែលមនុស្សត្រូវការចង់បានស្ទើរគ្រប់ប្រាណ សុទ្ធសឹងបរិសុទ្ធល្អទាំងអស់ ឬក៏មានកាឡៃខ្លះដែរ? តាមសេចក្តីសង្កេតនឹងការពិចារណា ឃើញថាកិត្តិយសមិនមែនសុទ្ធតែបរិសុទ្ធទេ មានកិត្តិយសកាឡៃដែរ ។

ក្នុងករណីយណាដែលកិត្តិយសជាវត្ថុកាឡៃ? ក្នុងករណីដែលសាម៉ីខ្លួនមិនអាចបំពេញអំពើអ្វីមួយជាសាធារណប្រយោជន៍បាន ហើយទៅលួចបន្លំយកស្នាដៃអ្នកដទៃមកដាក់ថាជារបស់ខ្លួន ដោយអាងតែខ្លួនមានសក្តិធំជាង ឬដោយសារតែសាម៉ីខ្លួនមិនមានសមត្ថភាពនឹងបញ្ចេញស្នាដៃនោះឲ្យលេចឡើង រួចខ្លួនបន្លំលួចមកបញ្ចេញទុកដាក់ថាជារបស់ខ្លួនៗ មានកិត្តិយសម្យ៉ាង ហៅថាកិត្តិយសផុនដាប ។ សួរថាកិត្តិយសនេះដូចម្តេច? កិត្តិយសនេះបានកើតឡើង ដោយអំណាចការពោលបង្កាច់គេ ឬក៏ដោយសារព្រោះតែចង់បានពេក ទៅសុំគេគ្រង់ៗ តែម្តង ទោះបីបានដឹងច្បាស់ថាខ្លួនមិនមានភាពគួរនឹងទទួលក៏ដោយ ដូចជាមួលបង្កាច់ថា

ឈ្មោះនោះគ្មានសមត្ថភាព បើឲ្យខ្លួនកាន់តំណែងនេះវិញទើបសម ។

មានកិត្តិយសម្យ៉ាងទៀត ហៅថា កិត្តិយសខ្មោចផ្សា ។ សួរថា កិត្តិយសនេះដូចម្តេច? មានជនឃោរឃៅខ្លះ ដោយអំណាចចង់បាន កិត្តិយសខ្លាំងពេក ហ៊ានយកជីវិតអ្នកដទៃទៅប្តូរ ដូចជាជួលគេឲ្យសម្លាប់អ្នកនោះទៅ បាន:នោះនឹងបន្ទោះ ម្លោះហើយទៀងតែធ្លាក់មកលើខ្លួនជាប្រាកដ ។ ចំពោះរឿងកិត្តិយសកាវ្យនេះ គេសង្កេតឃើញមានជាហូរហែតាំងពីអតីតកាលមក ។ ឧទាហរណ៍ ក្នុងព្រះពុទ្ធសាសនា : មានភិក្ខុមួយអង្គឧស្សាហ៍ណាស់ តែងបំរើនឹងគោរពព្រះមហាកស្សបរាល់ថ្ងៃ ទឹកឆាន់ក្តី ទឹកស្រង់ក្តី ទីសោធាសនៈនៃព្រះមហាកស្សបក្តី លោកភិក្ខុអង្គនោះដងទុកនឹងបោសសំអាតប្រគេនជានិច្ច ។ មានភិក្ខុមួយអង្គទៀតត្រូវជាសិស្សព្រះមហាកស្សបដែរ ជាមនុស្សកំជិល មិនដែលជួយធ្វើអ្វីសោះ តែបែរជាបានទទួលសេចក្តីសរសើរ នឹងការរាប់អានពីសំណាក់ព្រះមហាកស្សបពន់ពេក ។ សួរថា ហេតុអ្វីក៏ដូច្នេះ? ឆ្លើយថា ភិក្ខុកំជិលមិនធ្វើអ្វីមែន តែបេះគលល្បិចក្នុងការបន្លំលួចស្នាដៃរបស់ភិក្ខុឧស្សាហ៍ថាជារបស់ខ្លួន គឺថាបើភិក្ខុនោះដងទឹកដាក់ពាងពេញហើយ ឃើញដូច្នោះ ខ្លួនស្ទុះភ្លែតទៅនិមន្តព្រះមហាកស្សបមកស្រង់ទឹក ការធ្វើយ៉ាងនេះជារៀងរាល់ថ្ងៃ ព្រះមហាកស្សប ដោយស្មានថាជាភិក្ខុកំជិលធ្វើ ម្លោះហើយ លោកតែងសរសើរប្រាប់គេប្រាប់ឯង ខ្លួនក៏ទទួលកិត្តិយស

កាឡៃនេះរហូតមក ។

មានមួយថ្ងៃ ភិក្ខុ១ស្បាហ៍ ដោយតុញព្រាន់ទីងអំពើលាមកនៃភិក្ខុកំជិល ក៏លបយកចានទឹកដាក់ពាង ទុកឲ្យពាងនៅហូតហែងគ្មានទឹកមួយដំណក់ ។ ចំណែកភិក្ខុកំជិល ដោយស្មានថាគេចងដាក់ហើយ ព្រោះធ្លាប់តែដូច្នេះ ក៏ទៅនិមន្តព្រះមហាកស្សបមកស្រង់ទឹក ។ វេលានិមន្តមកដល់ លោកមិនឃើញមានទឹកមួយដំណក់ក្នុងពាង ទើបរឿងពិតក៏ផ្ទុះលេចឡើង ។

ក្នុងបច្ចុប្បន្ននេះ រឿងកិត្តិយសកាឡៃក៏មិនមែនមានចំនួនតិច ខ្លះព្រោះតែចង់បានឋានៈអ្វីមួយដ៏ខ្ពង់ខ្ពស់ ចំទទួលស៊ុំគេក៏មាន ខ្លះព្រោះតែចង់ឲ្យលេចឮឈ្មោះខ្លួនខ្លារ ចំទៅនិយាយអង្វរបុគ្គហែងឲ្យគេជួយផ្សាយឈ្មោះខ្លួនតាមវិទ្យុផងក៏មាន ។ល។ សួរថា គេធ្វើយ៉ាងនេះរាចម្រើនដល់សាមីជនឬទេ? ឆ្លើយថា ព្រោះតែមានការចម្រើន ទើបមនុស្សភាគច្រើននិយមធ្វើ ។ តាមការសង្កេតឃើញថា គេធ្វើដូច្នេះ គឺគេបានកិត្តិយសមែន តែជាកិត្តិយសដែលបណ្ឌិត្យរមែងស្អប់ខ្ពើម ។ ចំពោះរឿងនេះគួរឲ្យអៀនខ្មាសណាស់ បើមិនខ្មាសអ្នកដទៃ គួរតែខ្មាសខ្លួនឯង ព្រោះអំពើទុច្ចរិត គ្មាននរណាដឹងប្រាកដជាងខ្លួនឯងឡើយ ។

តទៅនេះ ខ្ញុំលើកយកសុភមង្គលមកដោះស្រាយម្តង ។ ភាពសុខកាយសប្បាយចិត្ត ឈ្មោះថាសុភមង្គល ។ មនុស្សនិយមត្រូវការ

ចង់បានសុភមង្គលនេះដូចជាកិត្តិយសដែរ ។ តាមការសង្កេតនិងសេចក្តីត្រិះរិះ ឃើញថា សុភមង្គល ទុកដូចជាបុប្ផាមានក្លិនក្រអូបដែលករជាតិតែងតោមរោម ឬដូចជានារីមានរូបសម្បត្តិដ៏ឆើតឆាយដែលមាណពទាំងឡាយតែងតែងដើរមកហើយលបចឹកមាត់ផ្ទះ ៗ កាលណាបានឃើញ នេះឧបមាយ៉ាងណា មនុស្សត្រូវការសុភមង្គល មានឧបមេយ្យដូច្នោះ ៗ

សួរថា មនុស្សសព្វថ្ងៃយល់ថា សុភមង្គលកើតមកអំពីអ្វី? តាមការសង្កេតនូវអាកប្បកិរិយានិងការប្រព្រឹត្ត ឃើញថាមនុស្សសព្វថ្ងៃ ចូលចិត្តថាសុភមង្គលកើតតែពីភោគទ្រព្យ គឺភោគទ្រព្យនេះហើយដែលផ្តល់សុភមង្គលដល់មនុស្ស ៗ ភោគទ្រព្យនឹងអាចនិមិត្តអ្វី ៗ ឲ្យមនុស្សបានតាមសេចក្តីប្រាថ្នា គេនិយមទុកភោគទ្រព្យជាកន្សែងបក់កន្សែងបោយ គេនិយមទុកភោគទ្រព្យជាខ្សែបង់ដំបងវាយឯង គេនិយមទុកភោគទ្រព្យជាថ្នាំងថ្នួនឯង ៗ ការនិយមនេះ គួរហើយ តែមិនជាសមរម្យទេ ៗ

សួរថា ការនិយមនេះ ជាសេចក្តីពិត ឬយ៉ាងណា? បើតាមអ្នកសម្ភារនិយម ភោគទ្រព្យពិតជាប្រភពនៃសុភមង្គលមែន ព្រោះអ្វីៗ ទាំងអស់ជាអាទិ៍ គឺផ្ទះ ប្រាសាទ យានយ៉ាងប្រណីត សំលៀកបំពាក់ល្អ អាហារឈ្ងុយឆ្ងាញ់ គ្រឿងអលង្ការ ៗ ល ៗ កើតតែពីភោគទ្រព្យ ៗ ដូច្នេះហើយបានជាក្នុងលោកបច្ចុប្បន្ន គេឃើញមនុស្សស្ទុះស្ទាសម្បើមពេកណាស់ ដើម្បីស្វែងរកភោគទ្រព្យ ៗ មានមនុស្សខ្លះ គឺភាគច្រើនតែ

មួង ស៊ីបួរស្លាប់បួររស់ចំពោះភោគទ្រព្យ គេរកភោគទ្រព្យដើម្បីរស់ ខ្លះរស់ដើម្បីស្លាប់ទៅវិញក៏មានៗ ការខំប្រឹងស្វែងរកភោគទ្រព្យគឺជាករណីយកិច្ចរបស់មនុស្សពិតប្រាកដ តែត្រូវស្វះស្វែងដោយមធ្យោបាយណា ដោយវិធីដូចម្តេច? ត្រង់ចំណុចនេះហើយដែលត្រូវដោះស្រាយ ។ យើងឃើញគេមានផ្ទះថ្ម យើងឃើញគេមានរថយន្ត យើងឃើញគេមានសំលៀកបំពាក់ល្អ ៗ យើងឃើញគេបរិភោគអាហារឆ្ងាញ់ យើងឃើញគេចូលកំសាន្តក្នុងពេនរង្គសាលរាត្រី ។ល។ យើងប្រាថ្នាចង់ឲ្យដូចគេ ចំណង់នេះជាការគាប់ប្រសើរណាស់ហើយ តែចូរប្រយត្ន័ការប្រតិបត្តិ ។ គួរឲ្យអៀនខ្មាសពេកណាស់ ព្រោះតែត្រូវការសុភមង្គល ហើយទៅប្រព្រឹត្តការមិនគប្បី ជាអំពើដែលអ្នកប្រាជ្ញតែងស្អប់ខ្ពើម (ចោរកម្មគ្រប់បែបយ៉ាង ស៊ីសំណូក) ។

គួរពិចារណាឲ្យសព្វ ៗ ជាការថោកទាបពេកណាស់ ព្រោះតែចង់បានសុភមង្គលដល់ខ្លួនដល់គ្រួសារ ហើយទៅឆក់យកពីជនដទៃ ធ្វើជនដទៃឲ្យដល់នូវការសេង្រេងសង្រែ ។ ជាការថោកទាបម្យ៉ាងទៀត ដែលយកសុភមង្គលទៅទិញកិត្តិយស ដែលខ្លួនមិនមានសមត្ថភាពនឹងត្រូវបាន ហើយជាការថោកទាបផុនចុងបំផុត ចំពោះអ្នកដែលហ៊ានលក់កិត្តិយសឲ្យដល់មនុស្សដែលមានសភាពមិនគប្បីទទួល ឧបមាដូចជាត្រីស៊ំមានតែមួយ ហើយមានមនុស្សច្រើនត្រូវការចង់បរិភោគ យើងមិនលក់ឲ្យ

មនុស្សច្រើន យើងសប្បាយចិត្តនឹងលក់ឲ្យដល់មនុស្សម្នាក់ដែលហ៊ានឲ្យថ្លៃច្រើន យើងស៊ូបណ្ដោយទុកឲ្យមនុស្សច្រើនវេទនា វិនាសចាកសុភមង្គល ព្រោះតែចង់បានសុភមង្គលផ្ទាល់ខ្លួនហួសប្រមាណ ។ កុំស្មានថាការមានសុភមង្គលតែម្នាក់ឯងអាចតាំងនៅបានជាស្ថាពរ ការស្មាននេះគឺការច្រឡំពិត ការប្រកាន់គំនិតនេះ ប្រហែលនឹងជួបប្រទះនូវអ្វីមួយជាប្រភពនៃសេចក្ដីអន្តរាយក្នុងអនាគត ។

សូមដំកបបញ្ជាក់ថា ទ្រព្យសម្បត្តិក្ដី យសសក្ដិសម្បត្តិក្ដី បរិវារសម្បត្តិក្ដី នឹងចាត់ទុកជាប្រភពនៃសុភមង្គលក៏មិនប្រាកដ នឹងបដិសេធថាមិនមែនទៅវិញក៏មិនប្រាកដ ។ ការត្រិះរិះនឹងពិចារណាឲ្យវែងឆ្ងាយទៅ ហុចឲ្យយល់ថាសុភមង្គលបរិសុទ្ធ គឺនៅត្រង់ការសុខចិត្ត ។ ឧទាហរណ៍ បើយើងជាមហាសេដ្ឋី បើយើងជាមហារដ្ឋបុរស តែចិត្តយើងមិនស្ងប់ មានពលិពោតជានិច្ចកាល នឹងឲ្យឈ្មោះថាយើងមានសុភមង្គលក៏មិនបាន យើងជាមនុស្សសាមញ្ញទេ តែមានចិត្តស្ងប់រីករាយនឹងវត្ថុដែលយើងមាន ឥតព្រួយបារម្ភក្រែងអ្នកណាលបធ្វើទុក្ខ មិនមានការកង្វល់ហួសប្រមាណ ត្រង់នេះហើយទើបហៅថាសុភមង្គល ។

ដូច្នេះគួរគប្បីសន្និដ្ឋានថា សុភមង្គលជាអានិសង្សនៃភោគទ្រព្យនៃយសសក្ដិ ឬនៃបរិវារក៏មិនមែន នឹងថាជាអានិសង្សនៃការក្រះហោមរហាមក៏មិនមែន គឺពិតជាអានិសង្សនៃការសុខចិត្តជាប្រាកដ ។

ដេង-ជ្រឹះ

# អក្សរសាស្ត្រខ្មែរ

## សិលាចារឹកជ័យ-នន្ទ

ស្រាវជ្រាវដោយ ឌុ. តាម

រក្សាសិទ្ធិគ្រប់យ៉ាង

សិលាចារឹកជ័យ-នន្ទជាភាសាខ្មែរ ដែលខ្ញុំបានប្រទះឃើញជាសិលាចារឹកក្នុងសម័យដែលប្រទេសខ្មែរយើងប្រើមហាសករាជ ។ នៅលើផ្ទាំងសិលាចារឹកនោះ ឃើញមានកាលបរិច្ឆេទពេញគ្រប់គ្រាន់ ។ សិលាចារឹកនោះ គេចារនៅក្នុងគ្រិស្តសតវត្សទី ១៨ ។ សិលាចារឹកនៅសតវត្សនោះមិនសូវជាពិបាកអានប៉ុន្មានទេ ពាក្យពេចន៍ក៏កាន់តែមានលំនាំជិតចូលមករកអក្សរសាស្ត្រខ្មែរសម័យបច្ចុប្បន្ន ។ គេសរសេរប្ដូរចារមិនគិតយកក្បួនអក្ខរាវិរុទ្ធិណាជាគោលទេ គេសរសេរឲ្យតែអានបាន ចំណាំបាន ។ ខ្ញុំសូមជូនព្យញ្ជនៈខ្មែរសម័យនោះសិន មុននឹងលោកអ្នកអានអត្ថបទរបស់លោកជ័យនន្ទ:



ក- ព្យញ្ជនៈនិងស្រៈដែលប្រើនៅសិលាចារឹក ជ័យ-ឧដ្ឋ

ស្រៈដែលមានប្រើនៅសិលាចារឹកនោះ ឃើញប្លែកៗពីគ្នា មិនសរសេរដូចគ្នាទេ ជួនកាលគេសរសេរដូច្នេះ ជួនកាល គេសរសេរដូច្នោះ ឧ. តៀប ជួនកាលសរសេរជា តោយ ។

១– ស្រៈ អ ច្រើនតែសរសេរជាមួយស្រៈ េា ឧ. មោក ជា មក ជោង ជា ជង ។

២– ស្រៈ អិ សរសេរដូច្នេះ ឧ. សេិលសាស= សិល្បសាស្ត្រ តេិប =តិប ។

៣– ស្រៈ អី សរសេរដូច្នេះខ្លះ ៀ ដូច ិ ខ្លះ ឧ. ស្រតិ =ស្រដី ព្យិតេិម្ម = ពីដើម ។

៤– ស្រៈ អឹ សរសេរជា ិ ខ្លះ ជាជើង ្យ ខ្លះ ឧ. សិងប្ចូល= សឹងបួល ត្យង= ដឹង ។

៥– ស្រៈ អឺ សរសេរជា ឹ ខ្លះ ជា ិ ខ្លះ ឧ. ហ្មិណ=ហ្មឹន គិបិ= គឹបឹ ។

៦– ស្រៈ អួ គេសរសេរដោយយកជើងព្យញ្ជនៈ វ ជំនួស ឬសរសេរទីងស្រៈ អូ ឧ. រ្វប = រួប ម្យ្វ = មួយ ។

៧- ស្រៈ អ្អើ ជួនកាលគេសរសេរ េិ ខ្លះ ជួនកាលសរសេរដូច សព្វថ្ងៃ ។. លេិក=លើក ប្រេិន=ប្រើន ។

៨- ស្រៈ អឿ ឃើញមានសរសេរដូចសព្វថ្ងៃនេះដែរ តែកន្លែង ខ្លះមិនសរសេរដូចសព្វថ្ងៃទេ ។. ក្បៀង=ក្បឿង ។

៩- ស្រៈ អ្អេ សរសេរជា ិ ។. បិញ=បេញ បិក=បេក

ខ- សញ្ញា និង វណ្ណយុត្តិខ្លះនៅសិលាចារឹក ជ័យ ឆន្ទ

១- មូសិកទន្តនៅក្រោមព្យញ្ជនៈ មានន័យថាព្យញ្ជនៈនោះជា ស្រៈអៅវិញ ។. ឋាបុង្ស=បារបង តែជួនកាលទៅជាស្រៈអា ។. ពុំឆ្ក=ពំនាក់ ។

២- សំយោគសញ្ញាមានន័យពីរយ៉ាងគឺ:

ក- ជំនួសព្យញ្ជនៈ ង ។. ស័យ=សង្ឃ

ខ- ជំនួសបន្តក់ ។. តាក័=ដាក់

ខ្ញុំសូមជូនពាក្យទាំងព្យញ្ជនៈ និងស្រៈដែលខ្ញុំបានចំឡងផ្ទាល់ខ្លួន ខ្ញុំនៅប្រាសាទអង្គរវត្ត ។ ខ្ញុំមិនបានចម្លងសព្វគ្រប់ទេ ខ្ញុំចំឡងតែកន្លែង ណា ដែលមានស្រៈស្រដៀងនឹងស្រៈសម័យបច្ចុប្បន្ន និងលំនាំព្យញ្ជនៈ ។

សូមលោកជ្រាបថា ពាក្យដែលខ្ញុំយកមកជាឧទាហរណ៍នេះ ខ្ញុំបាន ចំឡងចេញមកពីប្រាសាទអង្គរវត្តនៅថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ១៩៦៣ កាល

ច្រើនក្រៃពព្រាយ ប្រុសគោម្ងសិរ្សឪល...

កាន់ត្រើងក្រយូ សម្រាប្ញត់ប៉ោ...

រៀបក្រយាពិស្ដារ មានជាន់ឱ្យយា...

មានបង្គាយប្រ ម្ហូបលាលា

ខ្លិនស្ពំមាសដំរៅ: ផ្ទុះតាំមាសដំផ្កា.....

ដែលខ្ញុំទៅមើលប្រាសាទបូកណា ។ បើលោកអ្នកបានអញ្ជើញទៅទស្សនាប្រាសាទបូកណានៅខែត្រសៀមរាប សូមលោកធ្មៀកទុកកាសទៅមើលសិលាចារឹកជ័យ-នន្ទកុំខាន ។

ដើម្បីឲ្យស្រួលដល់លោកអ្នកអាន សូមលោកអ្នកជ្រាបថា ប្រាសាទអង្គរវត្តចែកជា ៣ កន្លែងគឺ:

១- ព្រះពាន់: កន្លែងដែលមានព្រះពុទ្ធរូបច្រើន

២- បាកាណ: កន្លែងនៅខាងលើគេបំផុត

៣- ព្រះបៀនថ្នាក់ក្រោម: ឬពេនទង ។

លោកអ្នកទៅដល់ប្រាសាទអង្គរវត្តហើយ សូមលោកអ្នកអញ្ជើញទៅព្រះបៀនថ្នាក់ក្រោម ឬពេនទង សូមលោកចូលពីទិសខាងកើត ត្រង់កន្លែងដែលមានព្រះចេតិយថ្មបាយក្រៀម ។ សិលាចារឹកជ័យ-នន្ទនេះនៅលើជញ្ជាំងខាងលិច ពេនទងខាងកើត ។

## សិលាចារឹកជ័យ-នន្ទ សរសេរតាមសិលាចារឹកអង្គរវត្ត

### ព្រហ្មគីតិ

(១) សព្វមសស្តី ត្រីសព្វត្រីមង្គលា ពហុលព្រះជៃយ្យា គោរ សាទ្ធាអតិរេក ។ (១) នា ១៦២៣ សកនេះ ក . . មសែញ នៃត្វាទស

---

១= នៅសិលាចារឹកជ័យ នន្ទ គេមិនប្រើវិសជ្ជនីយ គេប្រើលេខសូន្យ (០) ជំនួសវិសជ្ជនីយ ។

២- លេខរៀងដែលខ្ញុំយកមកចុះនេះដើម្បីឲ្យស្រួលដល់លោកអ្នកអាន ។

ពេជមាយមៃ ទំពារថ្ងៃព្រះហស្តេ ។ ពិតេម្ចនេះឯងនា គោយគ្រាថា ព្រះបាទ្យ លើកសរសេរពុទ្ធ បទមុះហង្សព្រំហ្មគិត ។ (២) អញខ្ញុំមថ្វាយ បុក្កា ព្រះកត្តរាសតៀជ ស្ថិតត្រាសយល ... ស្ដេចគុណគិតផ្ទុញមារនៃ ។ បទុំមក្រពុំស្អាត ថ្វាយព្រះបាទុសតៀជថ្ងៃលុតលើកទស្សករក្រៃ ផ្ទួនប្រពៃ គាកសិរស៊ែ ។ ខ្ញុំមក្រាប់ក្រោមព្រះបាទុ អត្តីកទវវន្ទី គិតថ្វាយទៅព្រះត្រី រត្នត្រៃយត្រីកាល ។ (៣) រុងរឿងបាលុំពេជ ត្បៀវគ្រស្រេចវិចនា ឆ្នាកផ្តៅជាក្បាច់ក្បាបរបូរបួនទន្តបោហាត ។ គាម្ចបួងសង្ឃគ្រប់ពាណ្ណី ល្អ ឥស្វាប្រទុះប្រពាត្ត គេតង ...ពោធិសត្វ ព្រះគុណស្ថិត ឈ្មោះមារផង ។ ថ្វាយព្រះសាខ្សម្មនៅ ព្រះត្រីអាលសោតហោង ត្រស់ត្រម្ចុំនាំសត្វផង កុងតន្ទុងកាលនៃនះនោះ ។ (៤) ខ្ញុំក្រាបក្រោមព្រះបាទុ អត្តីកទវវន្ទា ប្រណំព្រះសាស្តាបញ្ចពុទ្ធាវត្តត្រៃ ។ គេជះអញខ្ញុំថ្វាយ ទសករកាយ ឥសប្រហៃទ្យ ផ្គុំមផ្គូងគំម្បងថ្ងៃ បំគ្រម្ចូលម្បៃនៃប្រាជ្ញា ។ គីត្តថ្វាយព្រះ ចេត្តីយ៍បុលាម្ចៃត្រត្រឹងនាសានទុកព្រះកេស្សា ឥសទេព្តាថ្វាយបង្គំ ។ (៥) ថ្វាយព្រះប្រត្តិមា មាសនោនាស្ពាណអស្រែម ព្រះត្រៃសណ្ឋិត ជាពុំនូកនៃសត្វផង ។ ថ្វាយព្រះពុទ្ធរូប ឯព្រះសធូបចែត្តីហោង ថ្វាយគ្រុប ព្រះជ្យផង ព្រះសាធតូនព្រះគោហា ។ គេជះអញខ្ញុំថ្វាយ ស្បងកាច កាយកបោហាត្ថា លុតលើកឥសអគ្គា ថ្វាយវន្ទាសូរេចហោង ។ (៦) ថ្វាយ ហៀខ្ញុំទូលផ្តិង សូមទ្យត្យឥសអាផង ជាត្តិសញ្ញាណហោងកុំកំម្បាំង

ភ្ញាំងភ្លេចលើ ៗ កេតបានប្រាំម្ពិលឆ្នាំ ប្រាថ្នា ចាំមហៀបចេះធ្វើយ
ឥសអយៀធម៌គ្រប់ហើយ ត្រៃបីដកគម្ពីរទេ ៗ ឥតខុសស្រឡោងតលតិច
ថ្វើងពាកពេជ្រស្រេចឯង ពោះធ្វើពោធិ៍ងគេពោះប្រស្នាអ្វីគ្រពាល
សាលៀ ៗ (៧) សូមចេះចបត្រៃកេខ សើលសាសសេតអៀតទេសពាល
ធ្មុតធាប៉ូជាឥសចាយ៉ើ តូចព្រះបរមេសូរនៃ ៗ សូមទ័នព្រះគ្រីអាយ៉ើ
មានបរិពារប្រេនក្រាសក្រៃ ជារយេព័នហ្វីណាំនៃ ល្អប្រពៃគៀប្រាថ្នា ៗ
(៨) សេព្ជជ័នគ្រីពោបួស ហ្វើងផលផ្សល្អថ្ងៃថ្វា សំនាក់ព្រះ
សាស្នា បានព្រះពុទ្ធទំនាវទុក្ខ ៗ ព្រះគ្រីអាយ៉ើតវថា អ្នកនេះនា-
គ្រស័ម្បឯមុខ ជាព្រះពុទ្ធស្ងៀសុខ គ្រស័ម្បធម៌ទុក្ខនាំម្នសត្វនៃ ៗ ខ្ញុំ
សូមនោះរើងម្ទោក ជាពទ្ធកសពេជ្រថ្ងៃ អង្គខ្ញុំនេះឯងនៃ គៀនាម្ម-
ហោរៃផយនន្ទ ៗ រីនាងជាកនៃ្យ ឈ្មោះពិរនៃមឹងបែនសួន រូបឆោម
ទនអេនអន យលស្មោកសម្បចរិត្តគ្រី ៗ (៩) លះព្រះបាទ្ធពជ្ញា ទៀ
សក្កាទិនៃវខ្ញុំ ដៃខនស្នាធិពុតៀ ហើយទ្យទៀព្រៃក្តិហោង ៗ តលទៅធៀ
ចៀងឃ្មុំ ហ្នាហ្នឹនធំឯកឯងហោង លុះជាយម្នាកជជោង នោះឯង
ហោងសាងគ្រីសួរ ៗ ឯមិងបែននោះនាយសសក្ខគាគៀគុំនួរ ឈ្មោះ
នោះយលបរបួរ ជាជុំតារទេព្វសុពណ្ណ ៗ (១០) វៀអ្នកនេះទំព័រ គៀរ
មិលយលឥសចយ៉ើ ជាតនេះព្ទទួរពារ កេតទុក្ខព្រាតជាតាយាត ។
ជាតនេះពុំបរបួរ ប្រាសពុំមូលច្រើនឃ្លាឃ្លាត ពោះកើតសព្វ ១ ជាត

កុំគ្រាឃ្លាតគលគេចលៀង ៗ វិបាកនេះផងគ្នា មោកច្រើនគ្រាពុំគ្រា សៀយ អំម្ពិជាតនេះហើយ ខ្ញុំរៀរត្រង់វិបាកប្រាន្ធ ។ (១១) ពោះលែង ជាតនេះទោវ វិលមោកនៅកើតរូមស្ថាណ ត្រង់ទុក្ខអស្រូវប្រាន កុំគ្រា មានគិតកៃរៀ ៗ កាលគៀតខឹងព្រះពន្ធ សោកលេសលូទទួនឥទ្រ្ទី ហើយក្លព្រះតាយតៀ ទុក្ខផាំតទិបីទងកូន ៗ រៀកូនទំពៀរអង្គ អាពុកផ្ចង ធ្វើបុនរៀជូន ប្រកូបម្តាយទិងកូន អ្នកឥម្ទុងនោម្យស្ថាណ ៗ (១២) ហើយ សាងព្រះភ្នកបែក បាកដពែ្ឋកបែកអង្គប្រាន ខ្ញុំត្រខ្លាយអន្ទរោនបាក ឥសប្រានជាកំនាំត ៗ ឯខ្ញុំះបាកស្បូរៈង ព្រះកេសផងផ្តាកចិញបាតព្រះ បាទ្ធជាកុំនាត ព្រះហស័បាត័តាប័ខ្ញុតខ្លាយ ៗ ខំពេករើសប្រម្ចូលពោះ ឋ្មាបៀចូលមូលប្រៀគៀ បើតមាសឥសទំហ្សាជាពន្រោយល្អមានទ្រង់ ៗ (១៣) រៀកបឥសទំហ្សា មរុយបាយ ៣០ ព្រះអង្គ សាងព្រះបទពិរផ្តង គូរគ្រុបអង្គរបតូបទុំ ៗ ហើយបួសឆ្នាំងតាយគៀ ព្រះសាងប្ញនោះឆ្នាំងផ្តុំម ឆ្នាំងវូបទំគូបទុំ ជាទុតំម្ទូផសស្រេចហោង ៗ ស្រតៀតែទូនេះ ពុំរៀបរិះ ពិតេិម្ទផាង ធ្វើបុន្យនោះច្រើនហោង បួសប្រុំម្ទកោងទិងនេះនា ៗ (១៤) កាលបុះព្រះមាសមូល សាងត្រីស្បូរនោះម្បគ្រា សិទ្ធព្រះសី ហិងនាំ បុះព្រះមាសប្រាកច្រើនផាង ៗ ធ្វើបុន្យពិមុន្ទនា សងសាលា វិហាររហោង បម្បួសកូនគ្រុបផាង ប្រោសខ្ញុំហោងបញ្ចុះសីម្មា ៗ និងគិតគៀស្នាទាន តាំមពុំបានបទ្ធច្រើនគ្រា មៀទានខ្ញុំះបានគ្រា

គៅគ្នាតិត្តជាចង្ស ។ (១៥) ស្រត្យគៅតាការ ពុំរៀបកប័ត៌គេមផ្ទន
បេតិតស្យៗានសឃឹ នោះច្រើនហ្ហាស័ចាំមុំពុំបាន ។ គៅគិតផ្ចុំបុនរៀទា
ទិងគន្ទាច្រើនសព្វស្អាន ទិងចាំមនោះពុំបាន បន្ទុគៅស្អានច្រិនគួងនា ។
សូតពៀនែះពោហេ្យ សូតបង់ហេ្យចុះទៅល្បា សូតវ៉ចឺតសនែះនា សូត
សម្ទទូមសំម្រេចហោង ។

បន្ទពូជុង់លេលា

(១៦) នែះបទពូជុង់លេលា លើកគៅកាព្យា ជាល្បាទុំហ្យ ។
លាកឥសលោពោសព្សុំទ្វាយ លាកៃអន្តកយ ព្រាតព្រាយប្រាសគ្នា ។
ខ្ញុំក្រាបទូលព្រះពុទ្ធា ព្រះហេ្យខ្ញុំលា ត្រង់នាទុកសោក ។
ខ្ញុំលាត្រង់កុំណើត្រថោក កេត្រមោកឥសលោក សើចគៀលសន្តាន ។
(១៧) ខ្ញុំលាសព្វជាតវៀរស្ពាន ក្តិអាស្រវប្រាន កុំមានលើ្យនា ។
ខ្ញុំលាត្រង់ឥតប្រាជ្ញា ធ្នូលខ្ទៅមោហា ខ្ចាសគេអៀនប្រៀន ។
ខ្ញុំលាត្រង់ឥតរបៀន ចូលដំទុំស្ងៀម ពុំចេះធ្វើ្យថា ។
ខ្ញុំលាពិសក្យាធកេត្តា ប្រាសបុត្រតិយ្យា ស្វាប័ទបាសប្រាន ។
(១៨) ខ្ញុំលាវិបាកបូព៌ន ជាទុកកង់ប្រាន ស្រិកឃ្លានទោះផាង ។
ខ្ញុំលាឥសបាប៏ពៀរហោង ចំគុកបៀ្យផាង ឬនក់ទៅស្ទៀ្យ ។
ខ្ញុំលាត្រង់គុំទិតផ្ទាយ លាខ្លិលកុំស្ទៀ្យ ហេ្យស្មាតៀតេច ។
ខ្ញុំលាពុំចេះគលកិច សើ្យសាល្យការស្រេច ពាកពេជ្រនោះនា ។

(១៩) ខ្ញុំលាត្រង់ឥតប្រាជ្ញា ពុំចេះកាសា ស្រគៀងទង់គៀង ។
ខ្ញុំលាត្រង់ខ្សែត្រខ្វួនទេ ត្រមោចឯងឯង ឥតប្រៀងខ្ទុក្សា ។
ខ្ញុំលាឥតទ្រព្យកោគ្គតា ចាសៀ្វចាស្ងា ពុំមានតលម្អក ។
ខ្ញុំលាត្រង់ចិត្រប្រតិ្តយាក់ ស្រតិ្តទៀអាក អនអៀនចិត្រគៀង ។
ខ្ញុំលាត្រង់ពាកស្រាលស្រេ ស្រគៀងតូចគៀង មមៃហាក្ចូតនា ។
(២០) ខ្ញុំលាត្រង់គោតកាសា ស្រគៀងទៅជា ពាព្យៀហាឥតកាយៀង ។
ខ្ញុំលាត្រង់ខ្ញាវអែនុពាល ស្រគៀងសារណារ ឥតគេយោគពាក ។
ខ្ញុំលាត្រង់នាគ្គកយាគៀង ទូរយេសពៀងបាក ពុំព្រៀសស្រោបៀង ។
ខ្ញុំលាត្រង់លម្ងៀងកិប្រាយ ធ្វលធ្ញញពៀងមៀង ជ្រងោឥតកាយៀង ។
(២១) ខ្ញុំលាស្នាគៀងសារណារ ស្រគៀងកិចកាយៀង ពុំចាំនោះហើង ។
ខ្ញុំលាពុំនោលស្បូរសង ស្រគៀងពាកគ្គង ពុំត្រូវចិត្រគៀង ។
ខ្ញុំលាគៀងស្អួបសព្វគើ ត្រង់នាខ្នាសគៀង ៗលានោះហើង ។
ខ្ញុំលាឥសវេពផោង តៀរព្រង់ចុំណ្ញង្សៀង កុំយលលៀងនា ។
(២២) ខ្ញុំលាឥស្សក្តិមោហា វង្វើងឃ្លាតឃ្លា ក្វេចក្វាំងប្រមាទ្វ ។
ខ្ញុំលានោះសព្វៗជាតិ ស្រគៀងប្រមាទ ពិឃាដ្ឋសត្វផោង ។
ខ្ញុំលាសាព្វៀក្តិគ្គោង គិតខុសវៃលង ទេព្វយេញឯក្រោយ ។
ខ្ញុំលាត្រង់ក្តិទុំលោយ គិត្តខុសហៀងក្រោយ ទេព្វយេញក្តិគាប៉ៀ ។

ខ្ញុំលាត្រង់នាំអាកាព្យ　ស្បែរនោះតុំស្លាប់　ជាទុក្ខមកឯង ៗ

(២៣) ខ្ញុំលាត្រង់នាំវង្វេង　ស្រគៀវឥតក្រេង　បារំក្រោយលៀ ៗ

ខ្ញុំលាជាតនេះឃើញហើយ　គិត្រេយលឥត្រួយ　ពុំនកល្បៀនា ៗ

ខ្ញុំលាត្រង់ក្តិមោហា　ប្រមាទ្ធមៀបា　ត្រូបាធ្យាយជាង ៗ

ខ្ញុំលាត្រង់ក្តិធាំម្មគោង　ប្រមាទ្ធសឃិជាង　ព្រះពុទ្ធព្រះធម៌ ៗ

ខ្ញុំលាត្រង់ក្តិសាហារ　ស្រតិឡេខាល　អនអៀនព្រះទៃ ៗ

(២៤) ខ្ញុំលាពុំប្រកូបនៃ្យ　នោអំម្ចាស់ថ្លៃ　ប្រពៃព្រេងធម៌ ៗ

ខ្ញុំលាត្រង់ចិត្រសហារ　សាហារឥស្វាយៀ　បន្ទូនក្របាន ៗ

ខ្ញុំលាមនុស្សនាបៀនប្រាន　ស្រតិបង់ខាន្ន　ញុះញុងចិច្ចូ ៗ

ខ្ញុំលាត្រង់ក្តិអស្រុវ　ស្រតីចិច្ចូ　តែះតៀលប្រមាទ្ធ ៗ

(២៩) ខ្ញុំលានោះសព្វជាត្ត　សាព៉ោបង់ឃាត　បង់ខានលាភយស ៗ

ខ្ញុំលាត្រង់នាហៅដ្ឋខ្យស្ស　យស្សសក្ខុរបស្ស　ក្លាតក្លាយបាតបង់ ៗ

ខ្ញុំលាត្រង់គៀញុះញុង　បង់ខានចំណង់　បង់ខុសឃាតន្វា ៗ

ខ្ញុំលាត្រង់កៃយៀវេក　ត្រមោចកុំព្រា　ឥតគ្នាតាមក្រោយ ៗ

ខ្ញុំលាត្រង់ខាចកុំស្មោ្យ　ភិតកៃ្យប្រៃក្រោយ　តគៀ្យចុំប្រប្ហ ៗ

(ទៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ចាំង-ខាត់ រៀបរៀង*

(តមក)

---

អទន្ត គុ. ដែលមិនមានធ្មេញ ។

អទត្ត គុ. ដែលមិនឲ្យ ។ អទត្តា ស្ត្រី. កិរិយាមិនព្រមរៀបការ ។ –ទាន នបុំ. ទានដែលបុគ្គលមិនបានឲ្យហើយ ។ -ផល នបុំ. ផលដែល... មិនឲ្យហើយ ។ អទត្តាទាយិន បុំ. ជនកាន់យកវត្ថុដែលជនមិនបានឲ្យហើយ ចោរ ។

អទន នបុំ. កិរិយាបរិភោគ អាហារ ។ អទនី-ក្ប ធ្វើឲ្យទៅជាអាហារ ។

អទភ្រ គុ. ដែលបរិបូណ៌ គរគោក ។

អទំភ បុំ. កិរិយាមិនប្រវញ្ចន៍ ។ អទំភិន គុ. ដែលមិនប្រវញ្ចន៍ សុចរិត ត្រង់ ។

អទយម៑ ក្រិ.វិ ដោយមិនអាណិត យ៉ាងសាហាវ ។

អទរិទ្រ គុ ដែលមិនក្រីក្រ ដែលមានទ្រព្យ ។

អទប៌ គុ. ដែលមិនឆ្មើងឆ្មៃ ដែលសុភាព ។

អទឝ៌ គុ. ដែលឥតពិធីទត់ ។

អទស្សន — នបុំ. កិរិយាមិនមើល ។ គុ. ដែលមើលមិនឃើញ ។ អទស្សនី-ភូ ត្រឡប់ទៅជាមើលមិនឃើញ ។ –បថ បុំ. ផ្លូវដែលផុតពីចក្ខុន្ទ្រិយ៍ ។

អទស្សនីយ — គុ. ដែលមិនគប្បីមើលឃើញ ។ នបុំ ធម្មជាតដែលបុគ្គលមិនគប្បីមើលឃើញ ។

អទស្សី — គុ. មិនបានឃើញ ។

អទសវស្ស — គុ. ដែលមិនបើកនៅក្នុងអាយុ ១០ ឆ្នាំ ដែលមិនទាន់ដល់អាយុ ១០ ឆ្នាំ ។

អទុ — សព៌. នោះ ឯនោះ អ្នកនោះ អ្នកឯនោះ ។ អទោ– មូល គុ. ដែលមានឫសឯនោះ ។

អទាតុ — កា. ន. អ្នកមិនឲ្យ មនុស្សកំណាញ់ ។ អ្នកមិនសងថ្លៃឲ្យគេ ។

អទាន — គុ. ដែលមិនឲ្យ ដែលមិនចុះប្រេង (ដំរី) ។ នបុំ. កិរិយាមិនឲ្យ ។

អទានវ — បុំ. អ្នកមិនមែនទានវៈ ។

អទាន្ត — គុ. ដែលមិនទាន់ទូន្មានហើយ ។

អទាភ្យ — ដែលកំចាត់បង់មិនបាន ។

អទាយាទ — គុ. ដែលមិនមែនជាទាយាទ ។

អទារ — គុ. ដែលមិនមានភរិយា ។

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ញូ-កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ ។

យូរ-អ៊ុន

ឡេវពីឃើញដូច្នោះក៏ឃាត់ហាមថា ដែលមកធ្វើការនេះគឺខ្ញុំពឹងកំឡាំងអ្នកទាំងពីរ បើខ្វាន់ខ្វាមកប្រកាន់គ្នាដូច្នេះ ការរបស់យើងនឹងមិនខូចអសារទៅទេឬ យើងសូមឲ្យលើកទោសទៅចុះ ៗ ប៉ាំងថងថា អ្នកទាំងពីរកុំវិវាទគ្នាឡើយ អ្នកទាំងពីរសុទ្ធតែមានថ្វីដៃដូចគ្នា បើនឹងឲ្យទៅតែម្នាក់ឯង ក៏មានចិត្តមិនសប្បាយម្ខាង ៗ ត្រូវឲ្យទៅទាំងពីរនាក់ចុះ ដើម្បីនឹងវាយយកបន្ទាយឲ្យបានម្នាក់ ១ បើនរណាវាយយកបានមុនក៏នឹងត្រូវបានសេចក្ដីគាប់ប្រសើរជាងគេ ហើយបែងទាហានឲ្យហងតុងទៅវាយយកបន្ទាយឡេងប៉ៅ ឲ្យអ៊ុយអៀនលើកទាហានទៅវាយយកបន្ទាយគេងហៀន ទាំង ២ នាក់គំនាប់លាឡេវពីហើយក៏ចេញទៅរៀបចំពលទាហាន ក្រោយនោះប៉ាំងថងនិយាយថា នាយទាហាន ២ នាក់ដែលលើកពលចេញទៅ ឥឡូវនេះ មុខជាមិនបានប្រក្រតី ក្រែងទៅកើតវិវាទ

គ្នាកណ្ដាលផ្លូវដោយព្យាបាទក៏មិនដឹង សូមឲ្យលោកលើកទាហានជាកងជំនួនជូនទៅតាមស្ដាប់ការដើម្បីឲ្យឃើញខុសត្រូវផង ទៀតពីក៏ឃើញត្រូវផង ទើបប្រមូលទាហានទុកឲ្យចាំងចងនៅក្រោយបន្ទាយមួយប៉ែក ចំប៉ែកនាំចេញទៅជាមួយនឹងខ្លួនទៀតពីជាទ័ពជំនួយមួយប៉ែក ។

ហានគុងក៏បង្គាប់ទាហានឲ្យដាំបាយស៊ីឲ្យរួចពីព្រឹកនឹងលើកទៅទានដើងគ្នាខានស្ដាំដៃ ខណៈកាលហានគុងបង្គាប់ទាហានឲ្យដាំបាយនោះ អ៊ុយអៀនជីងកិត្តិសព្ទក៏មានអំណរណាស់ ទើបបង្គាប់ទាហានរបស់ខ្លួនឲ្យដាំបាយស៊ីឲ្យរួចពីយាមមួយ ហើយក៏លើកចេញទៅមុន តាំងពីកណ្ដាលអធ្រាត្រ ប្រមាណជាភ្លឺស្វាងឲ្យដល់ លុះទៅដល់កណ្ដាលផ្លូវក៏គិតថា បើយើងនឹងទៅវាយយកបន្ទាយ គេង ហៀន តែមួយឥឡូវនេះ សេចក្ដីគាប់ប្រសើរក៏មិនជាប្រមាណ ឈ្មោះសំឡេងក៏មិនជាល្បីព្ទូទៅខាងមុខ គួរតែនឹងលើកទៅវាយយកបន្ទាយឡេងចៅ ជាចំណែកហានគុងឲ្យបានជាមុនសិន រួចសឹមត្រឡប់ទៅវាយយកបន្ទាយគេងហៀងជាក្រោយ លុះគិតដូច្នោះហើយ ក៏ប្រាប់ទាហានឲ្យលើកបកទៅផ្លូវស្ដាំដៃ ប្រាថ្នានឹងដណ្ដើមយកមុខងារហានគុង លុះលើកទៅជិតបន្ទាយក៏វាយទាហានឲ្យឈប់ត្រៀមខ្លួនដើម្បីនឹងចូលច្បាំង ។

បំរើសេះយកសេចក្ដីទៅប្រាប់ឡេងចៅ ។ ដឹងដូច្នោះក៏រៀបចំទាហានទុក ហើយចាត់ទាហាន ១ កងឲ្យលើកត្រឡប់ទៅចាំវាយពី

ក្រោយ ៗ ពាហាន អ៊ុយ អៀន ទំរេដើរស្រូតទៅ មិនទាន់ក្តីស្រោងក៏ទៀយណាស់ ស៊ូទីងពាហាន ឡេង ប៉ៅ មិនបាន ក៏ចាញ់ថយបែកចំពោះទៅ ៗ អ៊ុយអៀន ឃើញពាហានតាំងពួនបែកក៏ញាក់សេះដេញ ៗ ឡេងប៉ៅ បានការគិបំផាយសេះតាមដេញទៅចម្ងាយប្រហែល ៤០ សិន (២ គ.ម.) ។

កាលអ៊ុយ អៀន លើកទៅនោះ គេងហៀនដឹងក៏លើកពាហានទៅចាំស្ទាក់នៅលើកំពូលភ្នំ ទទួល អ៊ុយអៀន បែករត់ទៅ គេងហៀនក៏បរសេះបញ្ចោះពាហានឲ្យចុះពីលើភ្នំដេញតាមទៅ អ៊ុយអៀន បង្ខំបរសេះរត់ដោយកម្លាំង សេះនោះបោលជាន់លើថ្មគិលដួលចុះ អ៊ុយអៀនក៏ភ្ញាក់ធ្លាក់ពីលើខ្នងសេះ ៗ គេងហៀនបានការ ក៏បំបោលសេះសន្ទុញទៅ លើកលំពែងឡើងទីងចាក់ ទទួលហងគុង លើកពាហានទៅដល់ប្រទះគ្នា ឃើញ គេងហៀន ដេញ អ៊ុយហៀន ប្រកិតជិតណាស់ លើកលំពែងឡើង ហងគុងក៏ស្រែកដោយសម្លេងខ្លាំងថា អញឈ្មោះហងគុងពាហានឯកនៅខាងនេះ នរណាពូកែចូលមកតស៊ូគ្នា ឡេងប៉ៅក៏ងាកទៅតទីង ហងគុង បាន ៤ ក្បួន តទល់ពុំបានក៏ញាក់សេះរត់ ហងគុងបានចំណាប់គិបំបោលសេះដេញពាហានឲ្យចូលទៅ ពាហានឡេងប៉ៅក៏បែកបាក់ខ្ចាត់ខ្ចាយទៅអស់ ឡេងប៉ៅ នឹងចូលបន្ទាយមិនទាន់ ឃើញហងគុងដេញខ្ជាន់ពីក្រោយ ក៏ទាញសេះងាកមកតបាន ១០ ក្បួន ឃើញ

ទាហានហានគុនជាប់តាមមកច្រើនណាស់ ប៉ះពារលើខ្លួនជុំវិញ ក៏ទាញសេះរត់តម្រង់ចូលបន្ទាយ គេងហៀន ខខូលឡៅពីលើកទ័ពជំនូនមកជាកងក្រោយ ចូលដណ្តើមយកបន្ទាយ គេងហៀន បានមុន ឡេងប៉ៅ ក្រឡេកទៅឃើញឡៅពីពាក់គ្រោះមាសឈរពីក្រោយ គួនប៉េងឈរជ្វេង ឡៅហានឈរខាងស្តាំស្រែកមកថា ឥឡូវអញដណ្តើមយកបន្ទាយបានហើយ ឯងនឹងរត់ទៅខាងណា ឡេងប៉ៅទាល់ប្រែកនឹងរាកចូលបន្ទាយមិនបាន ក៏ញាក់សេះវេះទៅតាមប្រកក្តុ នឹងរត់ដម្រង់ទៅស្រុកឡុកសៀ ។

ស៊ុយអៀនថូស់ការ ចាញ់ប្រៀបគេខ្លាំងណាស់ ក៏គិតថានឹងធ្វើការកែខ្លួនឲ្យបាត់ខ្មាស ហើយក៏លើកទាហានខន្ទ្រានដេញតាមឡេងប៉ៅទៅតាមផ្លូវដែលបែកទៅនោះ ស្រុតរូតទៅស្ទាក់ពីមុខ ហើយឲ្យទាហានយកព្រួតចងសន្ទឹងកំងផ្លូវ សេះឡេងប៉ៅបោលទៅប៉ះលើព្រួតក៏ដួលចុះធ្លាក់ឡេងប៉ៅពីលើសេះ ក៏នាំគ្នាស្ទុះចូលទៅព្រួតចាប់ខ្លួនបានចងនាំមក កាលឡៅពីបានបន្ទាយ គេងហៀន ហើយក៏ឲ្យចារិកអក្សរនៅខង់សេចក្តីថា កុំឲ្យនរណាធ្វើទុក្ខបុកម្នេញពួកឈ្លើយឲ្យអន្តរាយជីវិតឡើយ បើនរណាហើយមិនស្តាប់នឹងយកខ្លួនធ្វើទោសប្រហារជីវិតតាមគ្នា លុះចារិកអក្សរហើយក៏លើកខង់ដោតឡើងនៅមុខបន្ទាយ ហើយក៏និយាយនឹងទាហានឡេងប៉ៅនឹងគេងហៀន ដែលចាប់បាននោះមកថា អស់អ្នកពល់គ្នាដែលជាឈ្លើយយើងនេះ បើនរណាមានចិត្តគិតចង់នៅធ្វើការជាមួយនឹងយើងចូរនៅ

ចុះ បើនរណានឹងចង់វិលទៅស្រុកវិញ ព្រោះនឹករលឹកដល់មាតាបិតាញាតិកាបងប្អូនក៏ឲ្យវិលទៅចុះ មនុស្សពួកនោះបានឱកាសដូច្នោះហើយ ណាដែលនឹកដល់បុត្រភរិយាបងប្អូនក៏គំនាប់លាឡើងពីទៅ បណ្ដាមនុស្សដែលមានចិត្តស្រឡាញ់ ក៏នាំគ្នាសរសើរឡើងពីខ្ទរខ្ទារខ្ទួទៅពេញក្នុងស្រុក ៗ

ហង់តុងបានជ័យជំនះហើយ ក៏ចូលទៅគំនាប់ឡើងពីដំណបថា ឥឡូវអ៊ុយអៀនធ្វើខុសថ្ងស់ការនឹងបង្កាមិត្រថែករតំមកដូច្នេះ លុះនឹងមិនយកទោស បើអំណើះតទៅមុខ ការសង្គ្រាមក៏រមែងមានជម្រាបជាចម្ងាប់ដូច្នេះឲ្យខុសនឹងច្បាប់មេតិទ ទាហានទាំងពួងនឹងយកតម្រាប់តាម សុំឲ្យលោកប្រហារជីវិតវាចេញទើបត្រូវ ឡើងពីក៏ប្រើទាហានឲ្យទៅរកហៅខ្លួនអ៊ុយអៀន ទទួលអ៊ុយអៀនចងឡេងប៉ៅនាំចូលមកគំនាប់ឡើងពី ៗ ថាខ្លួនអ្នកឯងមានទោសជាទម្ងន់ធ្ងន់ណាស់ តែគ្រានេះ ហាក់តែអ្នកឯងធ្វើការកែខ្លួនចាប់ឡេងប៉ៅបានៗ ជាយើងត្រូវលើកទោសចោល ពីថ្ងៃនេះតទៅមុខបើនឹងធ្វើការអ្វីកុំគាប្បីធ្វើឲ្យទាស់ទែងខ្វែងគំនិតគ្នា កុំធ្វើការវែកយកតែមុខរបស់ខ្លួនលើកខ្លួនថា គ្រាន់បើជាងគេដូចជាគ្រានេះ ដែលអ្នកឯងរួចពីសេចក្ដីស្លាប់នោះ មិនពីព្រោះហង់តុងទៅជួយទេឬ? ឥឡូវត្រូវតែទៅគំនាប់ហង់តុងតាមប្រពៃណី អ៊ុយអៀន ក៏គំនាប់ហង់តុងសុំខមាទោស ឡើងពីក៏ឲ្យបំណាច់រង្វាន់ដល់ហង់តុងជាច្រើន ហើយក៏ឲ្យទាហាននាំយកខ្លួនឡេងប៉ៅចូលមក ឡើងពីក៏ចុះទៅស្រាយចំណងដែលចងនោះចេញ រួច

ឲ្យរៀបតុលៀងអាហារហើយសួរថា អ្នកឯងនឹងស្ម័គ្រចិត្តគិតភក្ដីនឹងយើង ឬប្រការម្ដេច?

ឡេងចៅដំរាបថា ជីវិតខ្ញុំបាទដល់ស្លាប់ហើយ លោកមានសេចក្ដីករុណាទុកអាយុឲ្យរស់នៅគ្រានេះ ព្រះតេជព្រះគុណនឹងរកទីបំផុតគ្មាន ខ្ញុំបាទនឹងសូមធ្វើការសងគុណលោកតទៅ ដែលនឹងមានចិត្តគិតប្រែពីលោកទៅវិញគ្មាន ឥឡូវទៀវយ៉ឹម ឡៅកុយ ដែលមកតាំងបន្ទាយនៅស្រុកឡុកសៀនោះហើយនឹងខ្ញុំបាទជាមនុស្សចិត្តមួយនឹងគ្នា បើលោកករុណាលែងខ្ញុំបាទឲ្យទៅ ខ្ញុំបាទក៏នឹងទៅនិយាយបញ្ចុះបញ្ចូលអ្នកទាំងពីរ ឲ្យមកស្វាមីភក្ដិនៅនឹងលោក ដើម្បីនឹងជួយគិតការតទៅឲ្យបានស្រុកឡុកសៀមកជាកំណាន់របស់លោក ឡៅពីមានសេចក្ដីត្រេកអរ ក៏ឲ្យអាវសំពត់នឹងរង្វាន់ទៅឡេងចៅហើយថា អ្នកឯងនិយាយទុកទៅមុខ កុំឲ្យត្រឡប់ពាក្យសំដីឲ្យបង់សត្យឡើយ ហើយក៏បើកឲ្យឡេងចៅទៅស្រុកឡុកសៀ ។

អ៊ុយអៀនដំរាបឡៅពីថា ដែលនឹងបើកខ្លួនឡេងចៅឲ្យត្រឡប់ទៅវិញវេលានេះ ខ្ញុំបាទយល់ឃើញថា បើកទៅហើយមិនមែនត្រឡប់មកវិញទេ ឡៅពីថា ខ្លួនយើងមានចិត្តអាណិតជួយជីវិតគេ មិនត្រូវនឹងធ្វើគេឲ្យវិនាស បើគេមិនគិតដល់គុណក៏តាមបុណ្យចុះ នឹងឃាត់ឃាំងយោងទុកប្រយោជន៍អ្វីឲ្យគេទៅចុះ ឡេងចៅគំនាប់លាឡៅពីហើយក៏កម្រង់ទៅស្រុកឡុកសៀ ហើយនិយាយប្រាប់ឡៅកុយថា បានធ្វើ

សង្គ្រាមតនឹងឡៅពីជាសន្ធឹកសន្ធាប់ណាស់ សម្លាប់ទាហានឯកឡៅពីស្លាប់អស់ ១០ នាក់ សត្រូវមានកម្លាំងច្រើនលើសលុបទប់ទល់ពុំឈ្នះបានជាដោះខ្លួនមកតែម្នាក់ឯង ឡៅកុយសំគាល់ថាពិតក៏រឹតតែភ័យខ្លាំងណាស់ ទើបបាត់បំរើឲ្យកាន់សំបុត្រទៅដល់ឡៅជៀងសុំកងទ័ពឲ្យលើកមកជួយ ។

ឡៅជៀងដឹងក្នុងសំបុត្រថា តេងហៀនស្លាប់ បន្ទាយប្រកបដ្បៀតក៏បែកបានទៅសត្រូវ ឡៅជៀងទុក្ខព្រួយណាស់ ក៏ឲ្យហៅនាហ្មឺនភ្នាក់ងារចូលមកប្រឹក្សារាជការ ឡៅឈុនជាកូនជំពបថា ខ្ញុំបាទនឹងសុំលើកទាហានទៅរក្សាស្រុកឡុងសៀងកុំឲ្យអន្តរាយ ឡៅជៀងសួរថាខ្លួននឹងលើកទ័ពទៅគ្រានេះក៏ស្រួលណាស់ហើយ តែថានឹងបាននរណាទៅកំដរជាទីប្រឹក្សាជាមួយផង គឺអ៊ីប្អូនភរិយាឡៅជៀងសុំទទួលអាសាទៅជាមួយ ឡៅជៀងមានអំណរណាស់ថា បើដូច្នោះបួលឲ្យអ្នកបាត់ទាហានរង ២ នាយចេញទៅជាមួយផង ង៉ីអ៊ុក៏បាត់លុយគង ង៉ីឡាន់ ២ នាក់ជាទាហានរង នឹងពួកកូន ២ ម៉ឺនឲ្យទៅឡៅឈុនស្រេចហើយក៏លើកទៅដល់ស្រុកឡុកសៀ ។

( នៅមានត )

# រឿងល្បើកឡាហ្វុងតែន

លោក ជេង-ង្រីវ ប្រែរៀបរៀង

(តមក)

---

## ៥៤– ភ្នែកនៃនាយពៅហ្វាយ

មានក្តាន់មួយត្រូវគេដេញ ក៏រត់មកសុំគោជ្រកនៅទីក្រោលជាមួយផង ហើយនិយាយអង្វរពួកគោថា: «នែបងទាំងឡាយ! សូមបងមេត្តាកុំឲ្យដំណឹងនេះដល់គេឯងរាល់គ្នា អំពើដែលបងទាំងឡាយបានធ្វើដើម្បីជួយលាក់ខ្ញុំនៅទីនេះ មិនមែនគ្មានប្រយោជន៍ឡើយ ហើយមិននាំឲ្យមានការស្តាយក្រោយទេ ព្រោះខ្ញុំមានស្គាល់កន្លែងមានស្មៅខ្ចីលាស់ល្អជាងកន្លែងឯទៀត»។

ពួកគោបានសន្យាជួយបំបិទបំបាំងរឿងនេះ មិនឲ្យអ្នកណាដឹង។ ក្តាន់លាក់ខ្លួនពួនអាត្មានៅត្រង់កន្លៀតមួយជាសុខ។ ពេលល្ងាច គេយកស្មៅខ្ចីនឹងចម្បើងមកដាក់ឲ្យគោជារាល់ថ្ងៃ។ គេទៅ គេមក ពួកឈ្មួញទាំងប៉ុន្មានដើរមួយរយជុំ មេគម្រួតក៏ដែរ គ្មាននរណាម្នាក់បានឃើញក្តាន់សោះ។ ក្តាន់មានសេចក្តីត្រេកអរចំពោះគោពន់ពេក ហើយនឹកថា ចាំពេលណាស្រួល គឺពេលដែលគេចេញភ្ជួរស្រែ នឹងលួចរត់ចេញទៅព្រៃ។ គោមួយទំពាអៀងបណ្តើរនិយាយថា «ដូចសព្វថ្ងៃនេះស្រួលហើយ តែប្រយ័ត្នកុំឲ្យតែមនុស្សភ្នែក១រយមកត្រួតមើល ខ្ញុំមាន

សេចក្ដីបារម្ភជួសបងក្ដាន់ឯងម៉្លេះទេ ខ្លាចក្រែងតែមនុស្សហ្នឹងមក តាំងពីដើមដល់ពេលនេះល្អហើយ តែបងឯងកុំអាលទុកចិត្តឲ្យសោះ» ។

គ្រាន់តែគោះនោះនិយាយហើយភ្លាម ម្ចាស់ទ្រព្យមកដល់ ដើរពិនិត្យមើលហើយសួរចំពោះកូនឈ្នួលថា «ហេតុអ្វីក៏ដូច្នេះ? ចុះស្មៅក៏តិចម៉្លេះនៅក្នុងក្រង់នេះ នែ! ចម្បើងនេះចាស់រលួយអស់ហើយ ចូរឯងទៅយកចំបើងថ្មីធាប់ៗមក ពីថ្ងៃនេះទៅ ត្រូវខំប្រឹងថែសត្វពាហនៈឲ្យស្អាតគួរសមមែនទែន អញមិនចង់ឃើញសោះកខ្វិកកខ្វក់ ចុះបើបោសសរសៃពីងពាងចេញ តើកនឿយហត់ប៉ុន្មានទៅ! គ្មានចេះរៀបចំនឹមនឹងខ្សែទាមទុកឲ្យល្អសោះ» ។ កំពុងតែរមឹលមើល ស្រាប់តែក្រឡេកទៅឃើញក្បាលមួយ ប្លែកពីក្បាលគោធម្មតា គេក៏ស្គាល់ច្បាស់ជាក្ដាន់ជាក់ ។ ដំបងមួយម្នាក់សំពង់ក្ដាន់ស្លាប់ទៅ ។

គ្មានអ្វីពូកែជាងភ្នែកនាយចៅហ្វាយឡើយ ។

## ៥៥– អ្នកស្រែ កូននិងសត្វលា

មានអ្នកស្រែម្នាក់ នឹងកូនប្រុសអាយុ ១៥ ឆ្នាំ ដឹកលាមួយទៅលក់នៅបុណ្យពិពណ៌ (Foire) ។ ដើម្បីកុំឲ្យលាស្គម ឲ្យនៅធាត់ល្អ លក់បានថ្លៃ ឪពុកនឹងកូននាំគ្នាចងជើងលា ហើយសែងដូចគោមរយោ៉ ។ ឪពុកលអកុសល! បុគ្គលល្ងីល្ងើគ្មានដឹងអ្វីសោះ ។ អ្នកទី ១ ដើរមកប្រទះ

អស់សំណើច ហើយពោលថា: « ចុះបុរសទាំងនេះនាំគ្នាលេងកំផ្លែងអ្វីដូច្នេះ? កងបណ្ដាអាចាំងបី អាមួយដែលល្វីល្វើជាងគេ មិនមែនអាដែងដែលគេគិតទុកមកនោះទេ » ។

ឮសំដីតែប៉ុណ្ណោះ អ្នកស្រែដឹងខ្លួនភ្លាមអំពីភាពល្ងង់នៃអាត្មា ក៏ស្រាយលាឲ្យដើរដូចធម្មតា ។ លាបានដើរស្រួល គាំងស្រែកលេងសប្បាយ ។ អ្នកស្រែមិនបានជាគិត ក៏ឲ្យកូនជិះលើលា ហើយខ្លួនដើរតាមក្រោយ ។ មួយសន្ទុះ ស្រាប់តែមានឈ្មួញបីនាក់ដើរមក ។ ទស្សនីយភាពនេះ នាំឲ្យគេទាស់ចិត្ត ។ ម្នាក់ដែលចំណាស់ជាងគេស្រែកឲ្យអាកូនថា: « នែ! ចុះចេញកុំឲ្យគេនិយាយទាន់ អ្នកកំឡោះដែលបណ្ដើរអ្នកបំរើពុកចង្កាប្រផេះ! ឯងត្រូវដើរតាមក្រោយ ហើយចាស់ជិះទើបសម » ។

អ្នកស្រែនិយាយថា « អស់លោកទាំងឡាយ! ខ្ញុំនឹងធ្វើតម្រូវចិត្តលោក » ។

អាកូនចុះដើរដី ហើយឪពុកជិះម្ដង ។ ស្រាប់តែមានស្រីក្រមុំ ៣ នាក់ដើរមកទៀត នាងម្នាក់ពោលថា: ឱ! គួរឲ្យខ្មាសអ្វីម៉្លេះទេ ចូរមើលចុះ ទៅជាឲ្យបងកំឡោះនេះដើរបេកជើងអស់ ចំណែកតាពោលមៀកនេះអង្គុយដូចសង្ឃរាជធ្វើវីនៅលើខ្នងលា ហើយទឹកស្មានថាគាត់ជាមនុស្សត្រឹមត្រូវ » ។

អ្នកស្រីពោលតបថា: «ចំណាស់ខ្ញុំនេះ ឈប់មានការធ្វើបុកពាទៀតហើយ ម្នាលនាងក្រមុំ សូមអញ្ជើញទៅចុះ ហើយសូមជឿស្តាប់ខ្ញុំផង» ។

ខាងក្រោយការពោលចំអកចំអន់-ចំអកឡកឡឺយគ្នាទៅវិញទៅមក អ្នកស្រីដោយស្មានថាខ្លួនខុស ក៏ហៅកូនឲ្យឡើងជិះពីក្រោយ ។

បរទៅបានប្រមាណ ៣០ ជំហាន ត្រូវក្រុមទី ៣ ពោលរិះគន់ទៀត ។ អ្នកម្នាក់ស្តីឲ្យថា: «បុគ្គលទាំងពីរនាក់នេះសុទ្ធសឹងជាមនុស្សឆ្កួត បើជិះយ៉ាងនេះ លាមុខជាមិនអាចទ្រាំបានឡើយ មុខជានឹងស្លាប់ដោយការជិះនេះមិនខាន ។ អើ! ម្តេចក៏ផ្ទុកលាកំសត់យ៉ាងដូច្នេះ នេះចំជាគ្មានអាណិតអាសូរដល់សត្វបរើចាស់ជរាសោះឬ? នេះប្រាកដជាយកតែស្បែកលាទៅលក់ឯបុណ្យពិពណ៌ជាមិនខាន» ។

អ្នកស្រីលាន់មាត់ថា «ឱពុទ្ធោអើយ! អ្នកណាដែលមានចិត្តចង់ធ្វើតម្រូវតាមបំណងមនុស្សទាំងអស់ ចំជាមនុស្សឆ្កួតសុទ្ធសាធ ។ ប៉ុន្តែ ត្រូវល្បងធ្វើតាមមួយបែបនេះទៀតចុះ ក្រែងលោយើងសម្រេចដល់ត្រើយ»។

អ្នកស្រីនឹងកូនក៏ចុះចេញពីលា ។ សត្វនេះបានធូរកម្លាំង ដើរតែឯង បែបអ្នកធំ ពីខាងមុខបុរសឪពុកនឹងកូន ។

ស្រាប់តែមានអាជើងខិលម្នាក់ដើរមកជួបទៀត ហើយស្រែកឲ្យថា «តើរបៀបសម័យ គេឲ្យលាដើរគោរងអើយ ហើយម្ចាស់ដើរទាំងវេទនា

ដូច្នេះឬ? អ្នកណាដែលកើតមក ដើម្បីឲ្យគេពឹងកំឡាំង តើជាសត្វលាឬជាម្ចាស់លា? ដូច្នេះខ្ញុំសូមឲ្យដំបូន្មានថាត្រូវយកលាដាក់ក្នុងហិបទុកគោរព ហើយនាំគ្នាពង្រិចស្បែកជើងរៀងខ្លួន រួចរក្សាលាទុកឲ្យនៅល្អស្រួលហើយ»!....

អ្នកស្រែឆ្លើយថា: «ខ្ញុំជាលាក៏ពិតមែនហើយ ខ្ញុំនិយមតាម ខ្ញុំយឺមទទួលសារភាពថាលោកនិយាយត្រូវ តែពីពេលនេះទៅ ទោះបីគេបន្ទោសខ្ញុំក្ដី គេសរសើរខ្ញុំក្ដី ឬគេនិយាយដូចម្ដេចក្ដី គេមិននិយាយអ្វីក្ដី ខ្ញុំត្រូវធ្វើតាមតែចិត្តខ្ញុំ» ។

## ៥៦– មនុស្សពាលនឹងមនុស្សសប្បុរស

មានអាពាលម្នាក់ដេញបោលអ្នកសប្បុរសនឹងថ្ម ។ អ្នកនេះងាកមកហើយពោលថា: នែ! សំឡាញ់ ឯងធ្វើនេះពិតជាត្រូវល្អហើយ ចូរយកប្រាក់ប៉ុណ្ណេះទៅចាយចុះ ឯងប្រសប់មែន ធ្វើតិចបានចំណេញច្រើន តែគតងពោលថា: គ្រប់ការងារទាំងអស់ រមែងតែបានរង្វាន់ ។ ទុះ! មនុស្សនោះមកទៀតហើយ គេមានប្រាក់ច្រើនសម្រាប់ឲ្យឯង ប្រហែលឯងបោលគេទៀតទៅ មុខជានឹងបានរង្វាន់ឥឡូវមិនខាន» ។

ដោយញ៉ាមនឹងបានចំណេញ អាពាលយើងស្ទុះក្ដើតបោលម៉ុង

ថែមទាំងដេរផង ។ ពេលនេះ គេមិនឲ្យរង្វាន់ជាប្រាក់ ពួកអ្នកបំរើគេ រត់ឈូរមក ចាប់អាពាលដាច់ ហើយលែងក្បាល ធ្មឹងជំនីរ នឹងខ្នងប៉ុន្មានដំបងគ្រប់ៗគ្នា ធ្វើឲ្យអាពាលដិតដល់ថ្ងៃអន្សា ។

## ៥៧- ខ្លាឃ្មុំនឹងតាចាស់

តាចាស់ម្នាក់ នឹងខ្លាឃ្មុំមួយនៅរួមសុខទុក្ខជាមួយគ្នាក្នុងឋានៈជាមិត្រសំឡាញ់ ។ តាចាស់ធ្វើការងាររបស់គាត់ ឯខ្លាឃ្មុំទៅរកចាប់សត្វយកមកធ្វើជាអាហារ ហើយពូកែខាងដេញរុយមិនឲ្យទំពេកសំឡាញ់វា ។

ថ្ងៃមួយ តាចាស់ដេកលក់ មានរុយមួយហើរមកទំច្រមុះតា ។ ខ្លាឃ្មុំឃើញហើយក្តៅចិត្ត ខំដេញៗទៅហើរមកៗ ខ្លាឃ្មុំនឹកក្នុងចិត្តថា «អញចាប់អាឯងឲ្យបានឥឡូវ» ខ្លាឃ្មុំចិត្តស្មោះត្រង់ ស្ទុះចាប់ថ្ម១ដុំ គប់ប៉ុនបែកក្បាលតាចាស់ខ្ទេចទាំងរុយផង ។

គ្មានអ្វីនាំឲ្យមានគ្រោះភ័យជាងមិត្រសំឡាញ់ល្ងង់ឡើយ ។

បើមនុស្សសប្បុរសជាសត្រូវគ្រាន់បើជាជាង ។

(នៅមានត)

## ៦– រឿងព្រេងចិន

(តមក)

# រឿង មេងគីយាង-នីយូ

6ème Meng Kiang-Niu

## រឿងព្រេងជាតិហាន់

នាងមេងគីយាង-នីយូ ក៏បន្តដំណើរទៅទៀត ៗ លេចពលចូលព្រៃ លេចព្រៃឡើងទៅលើភ្នំ, កាត់ជ្រោះបព្វតា . . . នាងដើរ . . . នាងខំដើរទាល់តែដល់កំពែងធំគ្រដាងចំពីមុខ ៗ នាង កាលក្រឡេកទៅឃើញកំពែង នាងមានចិត្តតក់ស្លុតរន្ធត់ឥតឧបមា ៗ កំពែងធំនោះ មើលទៅប្រហែលដូចជាពស់ថ្លាន់ធំលូនលើកំពូលភ្នំ ៗ នៅលើគិរីទាំងឡាយ គ្មានរុក្ខជាតិមួយដើម មានតែស្មៅរីលរល់ ក្រយោ បោកបក់ នាំខ្យល់ត្រជាក់រងាមក ៗ ពួកកម្មករម៉ឺនរដេរដាសនៅជើងកំពែងនោះ ៗ

នាងមេងគីយាង-នីយូដើរសេរសៀរតាមជើងមហាកំពែង ហើយសាកសួរគេថា តើស្វាមីនាងនាមវ៉ាន់ហ្សីលាង ស្ថិតនៅទីណា ធ្វើការនៅកន្លែងណា? គ្មានអ្នកណាតបមកនាង គ្មានអ្នកណាស្គាល់ នាងក៏ត្រាច់ដើរសួរគេអស់កាលជាយូរ ៗ នាងបានក្រឡេកទៅឃើញមនុស្សដែលធ្វើការនៅទីនោះមានមុខស្លេកស្លាំង មានកាយស្គម ៗ ជួនកាល នាងជួបប្រទះនឹងសាកសពដេកនៅលើផែនដី ៗ នាងក៏កាន់តែថប់ព្រួយបារម្ភយ៉ាងខ្លាំង ៗ នាងគិតក្នុងចិត្តថា គ្មានអ្នកណាស្គាល់ស្វាមីនាង! នាងក៏ស្រក់ទឹកភ្នែក

យំទួញសោកអាឡោះអាល័យស្វាមីនាង ។ តែមិនយូរប៉ុន្មាននាងក៏បានដឹងឮព័តិមានដ៏ពិតប្រាកដថា : ស្វាមីនាងទទួលអនិច្ចកម្មទៅហើយហើយសាកសពគេយកទៅកប់ក្រោមមហាកំពែងត្រង់កន្លែង ដែលគាត់ធ្លាក់ពីលើមកស្លាប់នោះ ។

នាងបានដំណឹងដ៏អាក្រក់នោះភ្លាម បេះដូងនាងដូចប្រេះជាប្រាំពីរភាគ នាងយំទួញសោកខ្សឹកខ្សួលអួលអាក់ទាល់តែដួលសន្លប់បាត់ស្មា-រតី ។ អ្នកទាំងឡាយក៏មកជួយថែទាំនាងឲ្យនាងភ្ញាក់ស្មារតីឡើង ។ លុះនាងភ្ញាក់បានដឹងខ្លួនឡើង នាងយំទួញថែមទៀត . . . នាងយំយ៉ាងខ្លាំងពន់ប្រមាណ ទាល់តែមហាកំពែងរលំនោះចម្ងាយ ២០០ គីឡូម៉ែត្រ ហើយ មានខ្យល់បក់បោកធ្វើខ្សាច់និងថ្មឲ្យរបេះពីមហាកំពែង . . . ។

ដំណឹងខុសពីធម្មតាផ្សាយទៅពាសពេញថា : « ស្នូរនៃការសោយសោកនាងមេងគីយាង-នីយូធ្វើឲ្យរលំមហាកំពែង» ។ តទៅទៀត ដំណឹងនោះផ្សាយទៅដល់ព្រះចៅអធិរាជចិន ព្រះអង្គទ្រង់ស្ដេចយាងទៅកាន់ទីនោះ ទ្រង់បានទតទៅឃើញនាងមេងគីយាង-នីយូ មានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ ទ្រង់ក៏ចង់យកធ្វើជាព្រះស្នំព្រះអង្គ ។ នាងមេងគីយាងនីយូ មានចិត្តស្អប់ព្រះចៅអធិរាជពន់ពេក ។ នាងគិតក្នុងចិត្តថា មិនព្រមទទួលធ្វើជាព្រះស្នំព្រះចៅអធិរាជសោះឡើយ ។ តែនាងមានគំនិតឈ្វេងយល់មួយបែបទៀត ទើបនាងក៏ប្រែក្រឡះចិត្តលែង

ស្អប់ព្រះចៅអធិកជទៅវិញ នាងក៏ក្រាបបង្គំទូលតបទៅព្រះចៅអធិកជវិញដោយសូរសំឡេងផ្អែមល្ហែមថា :

«ខ្ញុំម្ចាស់ចង់ធ្វើព្រះស៊ីនៃព្រះអង្គដែរ តែសូមព្រះអង្គទ្រង់ព្រះកជា-នុញ្ញាតឲ្យខ្ញុំម្ចាស់សូមពរពីព្រះអង្គបីយ៉ាង» ។

ព្រះចៅអធិកជទ្រង់មានព្រះបន្ទូលថា :

«តើសំណូមពរនោះយ៉ាងណាទៅ? សូមនាងប្រាប់មកយើង» ។

នាងមេងគីយាង-ន័យូ ក្រាបបង្គំទូលព្រះចៅអធិកជថា :

សូមទ្រង់ព្រះមេត្តាប្រោស សំណូមពរទីមួយសូមព្រះអង្គមានព្រះកជបញ្ញាឲ្យយកសាកសពស្វាមីខ្ញុំម្ចាស់ដាក់ក្នុងម្ឈូសមានគួជាមាសគម្របជាប្រាក់ ។ សំណូមពរទីពីរ គឺខ្ញុំម្ចាស់សូមឲ្យរដ្ឋមន្ត្រីទីងមេទ័ពនៃព្រះអង្គ ចូលទៅរួមក្នុងពិធីបុណ្យសពនេះ ដោយស្លៀកពាក់កាន់ទុក្ខទាំងអស់គ្នា ។ សំណូមពរទីបី គឺខ្ញុំម្ចាស់សូមឲ្យទ្រង់ស្តេចយាងហែសពដោយព្រះអង្គឯង រហូតដល់ស្តូបដ្ឋាន ដោយទ្រង់ស្លៀកពាក់សរសៃដើមកញ្ឆា ហើយព្រះហស្តកាន់ដំបងកាន់ទុក្ខ» ។

ព្រះចៅអធិកជទ្រង់យល់ព្រមតាមសំណូមពរនាង ។

ពិធីបុណ្យសពស្វាមីនាងនាមហ៊ងហ្សុលាង ក៏បានប្រព្រឹត្តទៅតាមបំណងនាងទាំងអស់ឥតខ្ចោះ ។ ព្រះចៅអធិកជ ទ្រង់ស្តេចយាងពីមុខម្ឈូសសព រដ្ឋមន្ត្រីទាំងឡាយទីងមេទ័ពដើរពីក្រោយក្បួនដង្ហែ ។ ព្រះ

ចៅអធិរាជទ្រង់នឹកក្នុងព្រះទ័យថា មុខជានឹងបាននាងមេងគីយាង-ទីយូធ្វើជាព្រះស្នំព្រះអគ្គមិនខាន ។

ក្រោយដែលបានបំពេញកិច្ចរួចជាស្រេច នាងមេងគីយាង-ទីយូ សែនឲ្យស្វាមី រួចនាងយំទួញសោកលើផ្នូរស្វាមីអស់កាលយ៉ាងយូររួចនាងវិលត្រឡប់ខ្លួនមកក្រោយ នាងលោតទៅក្នុងទឹកទន្លេដែលហូរជិតស្តូបដ្ឋាននោះ ។ ព្រះចៅអធិរាជ ទ្រង់ព្រះក្រោធជាខ្លាំង ទ្រង់មានព្រះរាជបញ្ជាឲ្យពួកអាមាត្យលោតទៅចាប់នាងស្រង់ពីទឹក តែមុននឹងពួកនេះទៅដល់នាង ។ ប្រែកាឡាខ្លួនទៅជាត្រីមានពណ៌សដូចប្រាក់ ។ ត្រីនោះក៏ហែលទៅក្នុងទឹកសមុទ្របាត់ទៅ ។

ចប់រឿងនាងមេងគីយាង-ទីយូតែប៉ុណ្ណោះ នៅមានរឿងទី ៧ គឺ: រឿងបឹងអូលីវ៉ៃយេកទៅទៀត ។

ចិត្តល្មោភលោភតណ្ហាប្រាថ្នាអន់
មិនជិនឆ្អន់គាប់ចិត្តតែម្រាថ
ឃើញស្រីល្អ កបនោមពណ៌យ៉ាងស្អាត
ខំសង្វាតគោរព អាប់រស្មី ។

# ជ័យជំនះដោយយុត្តិធម៌របស់ខ្មែរនៅតុលាការអន្តរជាតិ
## អំពីរឿងព្រះវិហារ

(តមក)

---

នៅទីបញ្ចប់ថ្ងៃទី ១៥ មេសា ១៩៦១ ដែលតុលាការអន្តរជាតិបានបញ្ចប់នីតិវិធីដែលគឺដេញដោលមាត់ទទេ ក្រោយដែលលោកទីប្រឹក្សាឌានអាឈីសុន បានឡើងដោះសាតបឆ្លើយតាក់តោលនូវសំអាងរបស់ថៃក្នុងរឿងអ៊ីស្រាអែល-ប៊ុលហ្គារីមក លោក ទ្រឿង-កាង ភ្នាក់ងាររាជរដ្ឋាភិបាលខ្មែរយើង បានឡើងបញ្ជាក់សេចក្ដីសង្កេតជាទូទៅ ។

លោក ទ្រឿង-កាង ថ្លែងជាអាទិ៍ថា:

លោក ចាងហ្វាង និងអស់លោកចៅក្រម ចំពោះប្រទេសដូចជាកម្ពុជានេះ ច្បាប់អន្តរជាតិ (Droit international) បើសិនជាយើងពិនិត្យតែផ្លូវបច្ចេកទេសនៃរឿងនេះ ឃើញហាក់ដូចជាឋិតនៅឆ្ងាយបន្តិចក្នុងពេលជាបឋមនោះ ពីព្រោះច្បាប់នេះបានធ្វើឡើងដោយប្រជាជាតិដែលរស់នៅក្នុងវង្សអារ្យធម៌ និងវប្បធម៌ ផ្សេងពីប្រទេសកម្ពុជា ។

ក៏ប៉ុន្តែ ដោយមកជាប់ទាក់ទងប្រទះច្បាប់អន្តរជាតិយ៉ាងជ្រាលជ្រៅតាមផ្លូវទូត រដ្ឋបុរសនីតិជនខ្មែរ (Juriste Cambodgien) ពុំមានភ្ញាក់ផ្អើលដល់បន្តិចសោះ ព្រោះថាក្រុមញាតិនៃប្រជាជាតិមានតែមួយទេ ។ គោលការណ៍ធំៗដែលរៀបចំតាក់តែងច្បាប់អន្តរជាតិ មានសម្ដែងជាប់នៅ



សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់កំពុងសន្ទនាយ៉ាងរីករាយជាមួយនឹងសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ ក្នុងឱកាសព្រះរាជបូជនិយេសកម្មនៅប្រាសាទព្រះវិហារ នៅថ្ងៃទី ៥-២-៦៣



សម្តេចព្រះនរោត្តម - សីហនុព្រះប្រមុខរដ្ឋទ្រង់កំពុងមានព្រះបន្ទូលជាទីសណ្តាប់ដល់អង្គទូតនានា នឹងប្រជាពលរដ្ឋជាកូនចៅអំពីទិដ្ឋភាពផ្សេងៗ ឯភ្នំព្រះវិហារ ក្នុងឱកាសព្រះរាជបូជនិយេសកម្មនៅថ្ងៃទី ៥-២-៦៣ នាភ្នំនេះ ។



សម្តេចឪ នឹងអ្នកអង្គម្ចាស់កន្តុលនាយករដ្ឋមន្ត្រី កំពុងស្តេចយាងទតបុរាណប្រាសាទសិលាព្រះវិហារក្នុងឱកាសព្រះរាជបូជនិយេសកម្ម ថ្ងៃទី ៥-២-៦៣

ក្នុងអារ្យធម៌យ៉ាងចាស់ទុំនៃអាស៊ីយើង ។

តើគោលការណ៍អ្វីខ្លះ ដែលរឿងបច្ចុប្បន្ននេះ ត្រូវបានចោទឡើង? ។

គោលការណ៍នោះ យើងយល់ថា មានពីរយ៉ាង: គឺគោលការណ៍ខាងការគោរពសំដីដែលបានពោលឡើង និងគោលការណ៍ខាងភាពជាបន្តអចិន្ត្រៃនៃរដ្ឋ (Respect de la parole donnée et continuité de l'Etat) ។

ការគោរពដល់សំដីដែលបានពោលឡើង ជាមូលដ្ឋាននៃច្បាប់ខ្មែរ ទោះបីនៅក្នុងការទាក់ទងជាផ្លូវសាធារណៈ ក៏ដូចជាក្នុងការទាក់ទងផ្លូវឯកជនដែរ ។

បទបញ្ញត្តិមួយនៃអត្ថបទឯកសារបុរាណតារ្យរបស់យើង ដែលអា-ដេម៉ាឡឺក្លែរ (Adhémar Leclere) (les codes Cambodgiens 18 19...) បានបញ្ជាក់ហើយស្រេចថា: « ព្រះមហាក្សត្រ និងមន្ត្រី ទ្រង់មានព្រះបន្ទូលតែមួយ និងមានសំដីតែមួយ ។

ដំឡៃនៃសំដីនេះ បាននាំឲ្យដំកើងនៃគំនិត គឺទឹកចិត្តដែលបានបញ្ជាក់ឲ្យឃើញច្បាស់ឡើងនោះ មានប្រៀបធំជាងទម្រង់ការខាងក្រៅ ។ តាំងពីសតវត្សទី ១៦ មក ច្បាប់ខ្មែរមានចែងអំពីកិច្ចសន្យារវាងឯកជនដែលកើតឡើងដោយសារតែសេចក្តីសម្រេចចិត្តរបស់ខ្លួន ដូចជាខាងការលក់ ខាងការដូរ ខាងការខ្ចីជាដើម (Jean Imbert: Histoire des Institutions khmères) ។ ហេតុដូច្នេះ ការដែលប្រទេសកម្ពុជាបានគាំថា

តុលាការអន្តរជាតិមានសមត្ថកិច្ចនឹងជំនុំជំរះរឿងនេះ គឺមិនមែនគ្រាន់តែធ្វើឡើងដើម្បីប្រយោជន៍នៃហេតុ របស់ខ្លួនតែប៉ុណ្ណោះទេ គឺជាកិច្ចមួយស្របតាមធម្មជាតិនៃទម្លាប់របស់ប្រទេសជាតិខ្លួនផង ។

នៅមានគោលការណ៍មួយទៀត ដែលច្បាប់ខ្មែរបានជាប់ទាក់ទងជាខ្លាំងណាស់ដែរ គឺគោលការណ៍អំពីភាពជាអចិន្ត្រៃយ៍នៃរដ្ឋ (Permanence de l'Etat) ។ ច្បាប់ខ្មែរ បានទទួលអនុវត្តគោលការណ៍ តាំងពីយូរយារណាស់ហើយ ខាងក្នុងប្រទេស នៅឱកាសដែលមានផ្លាស់ប្តូរព្រះមហាក្សត្រម្តង ៗ ។ ក៏ប៉ុន្តែ យើងសុំឲ្យគោលការណ៍នោះអនុវត្តក្នុងផ្លូវអន្តរជាតិផង ។

តាំងពីបុរាណកាលយូរយារណាស់មកហើយ ប្រទេសយើងជារដ្ឋមួយ ហើយរហូតមកដល់សព្វថ្ងៃ រដ្ឋរបស់យើងនៅមានដីភាពជាអចិន្ត្រៃយ៍ឥតឈប់ខានសោះ ។ ទោះបីមានប្រទេសខ្លះនៅចុងបូព៌ា បានបង្ខំឲ្យយើងជួយសួយសារអាករយ៉ាងណា ឬទោះបីជាយើងឋិតនៅក្នុងអតីតសហភាពឥណ្ឌូចិនយ៉ាងណាក៏ដោយ ក៏ប្រទេសយើងនៅមានលក្ខណៈជារដ្ឋមួយជានិច្ច ,, ។

ដើម្បីនឹងបញ្ចប់គំនិតនេះ សហជីវិន ទ្រឿង-កាង បានលើកយកឯកសារច្បាប់អន្តរជាតិមកធ្វើជាតឹកតាង ។

បន្ទាប់មក លោកបានថ្លែងយោបល់ថា តាមផ្លូវនីតិសាស្ត្រក៏ដូចជា



ជនចាស់ម្នាក់កំពុងចាប់ទាញដោយពេញចិត្ត នូវព្រះហស្តដ៏ទន់ត្រជាក់នៃសម្តេចឪ មកដាក់លើក្បាល ខ្លួនដើម្បីសិរីសួស្តី ក្នុងឱកាសព្រះរាជបូជនីយេសកម្មនៅថ្ងៃ ទី ៥ - ២ - ៦៣

តាមផ្លូវសុភវិនិច្ឆ័យ គេមិនអាចយល់បានថា តើហេតុដូចម្តេចបានជាប្រ-ទេសថៃ ដែលបានទទួលស្គាល់ ភារកិច្ច (Obligation) របស់យើងក្នុងរបបអាណាព្យាបាល ហើយទៅជាមិនព្រមទទួលស្គាល់ សិទ្ធិ (Droits) របស់យើងក្នុងរបបនេះទៅវិញ ។

ក្រោយដែលបានបញ្ជាក់អំពីការណ៍ដែលសន្ធិសញ្ញាជាមួយប្រទេសអាណាព្យាបាល មិនត្រូវលោយសាបសូន្យ នឹងក្រោយដែលបានថ្លែងអំណរគុណដល់តុលាការដែលបានទទួលស្តាប់ ដោយយកចិត្តទុកដាក់អំពីសេចក្តីដដែករបស់យើង សហជីវិន ក្រៀង-កាង បានថ្លែងជំនឿជឿជាក់ដល់គតិយុត្តិធម៌នៃតុលាការអន្តរជាតិ ដែលជំរះសេចក្តីរឿងរបស់យើងនេះ ។

---

អភិជ្ឈាលោភឃ្លួសលេចក្បាលធ្លោ
ឃើញជ្រៅដឹកងាកក្បាលត្រងាល
បង់តែបាន គ្មានរំខានរាងបាល
ដល់បាតាល ទើបភ្ញាក់ ឱជ្រុលឃ្លួស។

ធ.ជ្រីវ

# បៀម-ក្រុក ព្រះកក្កុសន្ធោ

## *សហជីវិន ជល-និត្យ នៅពុទ្ធសាសនបណ្ឌិត្យ*

---

*រថយន្តផ្សាយសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ បានទៅឈប់នៅចំមុខផ្ទះតាជួបនឹងយាយមា ។ អ្នកផ្សាយសៀវភៅ បានស្រែកឃោសនាដោយឧគ្ឃោសនៈរំពងសរសើរគុណសម្បត្តិគ្រប់យ៉ាង នៃសៀវភៅទាំងឡាយ ដែលដាក់យកទៅផ្សាយ ។ ប្រជាជនទាំងក្មេងចាស់ នាំគ្នាទៅចោមរោមស្តាប់ឧគ្ឃោសនស័ព្ទអឺងកង ។ តាជួបឮ សំឡេងឡូៗ ទ្រាំមិនបានក៏ចេញទៅមើលជាមួយនឹងគេដែរ ។ គាត់ងាកទៅឃើញរថយន្តនោះច្បាស់ ទើបគាត់ដឹងថា ជារថយន្តផ្សាយសៀវភៅរបស់រាជការ គាត់មិនហ៊ានចូលទៅឈរជិតដូចគេទេ ព្រោះខ្លាចក្រែងចិត្តគាត់ប្រែទៅចុះចូលនឹងធម៌បារាំង គាត់ឈរនៅឆ្ងាយពីគេទាំងពួង ។ បន្តិច មិត្តអ្នកផ្សាយរបស់យើង កាន់សៀវភៅគិហិប្បដិបត្តិ ១ ក្បាលដើរតម្រង់ទៅរកគាត់ ហើយនិយាយពន្យល់គាត់ឲ្យជួយជាវសៀវភៅនោះ យកទៅទុកសិក្សាព្រោះជាសៀវភៅល្អ សម្រាប់ឧបាសក ឧបាសិកា មានធម៌សព្វគ្រប់ត្រឹមត្រូវ រៀបរៀងដោយអ្នកប្រាជ្ញចេះដឹងច្បាស់លាស់ . . . ។ តាជួប ស្តាប់មិនចូលចិត្តសោះ ព្រោះគាត់ធ្លាប់ប្រកាន់ថា សៀវភៅរាជ-ការសុទ្ធតែជាធម៌ថ្មីរបស់បារាំង គាត់ប្រកែកមិនព្រមជាវ ។ មិត្តយើងថ្លែងពន្យល់គាត់ជាច្រើនបែប យ៉ាងប៉ុនប្រសប់ទៅទៀត ទីបំផុត តាជួប*

ប្រថុយជាសៀវភៅគិហិប្បដិបត្តិ ១ ក្បាលនោះ ដោយការទុញទាល់ទីង ពេហារម៉ិត្រយើងខ្ទាំងពេក ។ គាត់កាន់សៀវភៅជាប់ តែមិនហ៊ាន បើកសៀវភៅនោះមើលទេ ព្រោះគាត់ធ្លាប់ឮគេប្រាប់ថា ក្នុងសៀវភៅ រាជការសុទ្ធតែមានយ័ន្តដាក់ស្នេហ៍ពូកែណាស់ បើអ្នកណាមួយបើកមើល ទៀងតែត្រូវស្នេហ៍ចុះចូលធម៌បារាំងមិនខាន ។ លុះត្រឡប់ទៅផ្ទះវិញ យាយម៉ាឃើញតាកាន់សៀវភៅ ក៏ស្រែកទាំងភ័យថា យី! តាទិញសៀវ-ភៅហ្នឹងឬ? ។ តាជួបឆ្លើយថា អើ! គេបេះតែខ្ទួចខ្ទែឲ្យទិញខ្ទាំង ពេក អញទ្រាំមិនបាន ប្រថុយចាយលុយទិញតែមួយក្បាលទៅហើយ ព្រោះអញទ្រាំខឹងពួកអ្នកឃោសនាណាស់ អញទិញនេះ ប្រាថ្នាឲ្យតែ គេទៅផុតទេ! ។ យាយម៉ា: យី! ម៉េចក៏តាហ៊ានទិញ តាមិនដឹងទេឬ ពួកសៀវភៅធម៌ថ្មី ជាធម៌របស់បារាំង ហើយសៀវភៅនីមួយ ៗ សុទ្ធតែ មានគួយ័ន្តមេស្នេហ៍ធំ ៗ ណាស់ តាឯងប្រយ័ត្នត្រូវស្នេហ៍ទៅចុះចូលធម៌ បារាំង មុខជាចុះនរកជាន់ហ្នឹងហើយ! លោកអើយ! ។ តាជួប: ចុះ នរកអី បើអញមិនទាំងខ្វីបើកមើលផង ។ យាយម៉ា: នែ! តាឯងកុំ បើកមើលឲ្យសោះណា! យកទៅចោលឯណាឲ្យបាត់ទៅ! កុំទុកនាំចង្រៃ ណាស់ ។ តាជួបប្រុងយកទៅកប់ចោល ប៉ុន្តែនឹកស្តាយ ដោយឃើញ សៀវភៅនៅថ្មីស្អាតល្អ ក៏លាក់កាន់ចូលទៅក្នុងផ្ទះ បើកហិបញាត់សៀវ ភៅនោះទៅបាតហិប រួចបិទដិតទៅវិញមិនឲ្យយាយដឹងសោះ ។

ពីរបីថ្ងៃក្រោយមក យាយម៉ានិយាយនឹងគាត់ថា តាអើយ! ឥឡូវលោកគ្រូព្រះធម៌ទើបនិមន្តមកគង់ក្នុងវត្តយើងនេះ ខ្ញុំគិតសុំតាឯងទៅរៀនធ្វើសមណធម៌ (សំណាក់ធម៌) នឹងគេមុនហើយ ។ តាជួបៈ អើ! ទៅក៏ទៅចុះ ចាំថ្ងៃក្រោយឯងឈប់ សឹមអញទៅម្តង ។ យាយម៉ាសប្បាយចិត្ត គាត់ប្រើកូនស្រីទៅផ្សារ ឲ្យទិញទៀនគោលនឹងធូប ព្រមទាំងផ្លែឈើនំនែកផ្សេង ៗ ជាច្រើនផង ។ ស្អែកឡើង ជាថ្ងៃឧបោសថ ១៥ កើត គាត់កាន់របស់ទាំងអស់នោះទៅវត្តជាមួយនឹងយាយតាឯទៀតជាច្រើននាក់ ដើម្បីយកទៅប្រគេនលោក ។ ដល់ទៅវត្ត គេនាំគ្នាទៅថ្វាយបង្គំលោកគ្រូព្រះធម៌ ដែលគង់ក្នុងកុដិមួយដាច់ដោយឡែកតែមួយអង្គឯង ។ ពេលជួបជុំគ្នា គេក៏នាំគ្នាសូត្រនមស្ការ ស្មាទានសីលតាមទំនៀម ។ លោកគ្រូព្រះធម៌ សូត្រសិក្ខាបទមួយម្តង ៗ ប្រទានទៅឧបាសកឧបាសិកាទាំងនោះ ពួកឧបាសកឧបាសិកាទាំងនោះ ក៏នាំគ្នាសូត្រទទួលតាមរៀងខ្លួន ខ្លះសូត្រញាប់ទាន់ ខ្លះសូត្រមួយ ៗ ខ្លះសូត្រខ្លាំង ៗ ខ្លះសូត្រខ្សឹប ៗ សំឡេងក្នុងទីនោះ ក៏លាន់ឡើងដូចជាឃ្មុំយកផ្កា ។ យាយម៉ា មិនសូវចេះចាំចប់ចុងចប់ដើមច្បាស់លាស់ដូចគេទេ គាត់សូត្រខ្សឹប ៗ បន្ទំ ហើយបើគេនៅជិតខាងចប់ គាត់ក៏ចប់ដែរ ។ លុះកិច្ចសមាទានចប់សព្វគ្រប់ហើយ យាយតាខ្លះ មានការប្រញាប់ ក៏ថ្វាយបង្គំលោកត្រឡប់ទៅផ្ទះវិញ ខ្លះទៀត នៅចាំចាត់ចែងបម្រើលោកឆាន់ ហើយនាំគ្នាបរិភោគ

បាយដែលសេសសល់អំពីលោក ៗ ឯយាយម៉ា ក៏នៅបរិភោគទឹងគេដែរ លុះរួចហើយ គាត់ក៏លំទោនចូលទៅជិតលោកគ្រូព្រះធម៌ លើកដៃប្រណម្យទូលថា: សូមព្រះតេជព្រះគុណមេត្តាសង្គ្រោះប្រោសសត្វខ្ញុំផងខ្ញុំករុណា មកសុំរៀនធ្វើសមណធម៌ពីព្រះតេជព្រះគុណជាមួយទឹងគេ សូមព្រះអង្គប្រទានធម៌ណាឲ្យសមគួរដល់ខ្ញុំករុណា ដើម្បីយកទៅរៀនធ្វើក្រែងបានសម្រេចមគ្គផលទឹងគេខ្លះ ៗ លោកគ្រូព្រះធម៌ សំឡឹងទៅយាយ ហើយលោកមានថេរដីកាថា: អម្ពរ! ល្អហើយយាយ! បើយាយមានចិត្តជ្រះថ្លាប្រាថ្នារៀនសមណធម៌នោះ មិនអីទេ អាត្មាជួយសង្គ្រោះបាន យាយយកព្រះនាមព្រះពុទ្ធមួយអង្គទៅធ្វើបរិកម្មភាវនាចុះ ប៉ុន្តែត្រូវរៀបគ្រែព្រះធម៌ មានបាយសី បារីស្លា ទៀនធូប ឲ្យសព្វគ្រប់ក្នុងកន្ទួងដាច់ដោយឡែកតែម្នាក់ឯង លុះដល់ពេលយប់ស្ងាត់ ត្រូវយាយចូលទៅអង្គុយឲ្យស្រួល នមស្ការថ្វាយបង្គំព្រះ រួចភាវនាថា អរហំ ៗ . . . ឲ្យដាច់កុំឲ្យដាច់ ហើយបើឃើញហេតុកេតចំឡែកយ៉ាងណា ៗ ព្រឹកឡើងកុំប្រាប់អ្នកណាឲ្យសោះ ត្រូវប្រញាប់មកបកធម៌ទឹងអាត្មា ព្រោះធម៌ក្នុង គេមិនត្រូវឲ្យមនុស្សឯទៀតក្រៅពីខ្លួនឯងដឹងផងទេ សូមអញ្ជើញយកទៅចុះ ៗ យាយម៉ាសប្បាយចិត្តណាស់ នាំយកព្រះនាមថា អរហំ . . . . នេះទៅផ្ទះវិញទាំងទឹកមុខញញឹមញញែម ៗ ទៅដល់ផ្ទះ គាត់ប្រាប់តាទឹងកូនចៅឲ្យរៀបចំតាមបង្គាប់លោកគ្រូព្រះធម៌ ៗ កូនចៅរកកន្ទួងដទៃមិន

បាន  ក៏នាំគ្នារៀបចំក្នុងជង្រុកស្រូវឲ្យគាត់ ។ លុះដល់ពេលយប់ យាយមាំ ទៅអង្គុយស្ងាត់ម្នាក់ឯង នមស្ការថ្វាយបង្គំព្រះរូប តាំងប្រឹងស្មឹងស្មាធិ៍បរិកម្មភាវនាថា អរហំ . . . អរហំ . ។ អរហំ គាត់ភាវនាបណ្ដើរ គាត់ចង់ឃើញអ្វីៗអស្ចារ្យ ហើយចេះតែនឹកចង់ឃើញស្ថានសួគ៌ ឋាននរក ។ល។ រហូតដល់ឈូបង្គុយ ទើបគាត់សម្រាន្តសម្រាកបន្តិច ហើយក្រោកឡើងប្រឹងស្មឹងស្មាធិ៍បរិកម្មភាវនាទៅទៀត ។ គាត់ធ្វើតែរបៀបយ៉ាងនេះ លុះដល់ពេលជិតភ្លឺ ស្រាប់តែឮសូរស័ព្ទយ៉ាងអស្ចារ្យគួរឲ្យរំភើបក្នុងខ្លួន ដែលគាត់ដូចជាធ្លាប់ឮផង មិនធ្លាប់ឮផង ។ សំឡេងនោះដំបូងលាន់ឮយ៉ាងតូចឆ្មារថា «ចៀប» ហើយបន្ទាប់គ្នានេះ ឮសំ-ឡេងធំមួយទៀតថា «ក្រុក» ។ គាត់ឮមិនច្បាស់ថា តើសំឡេងនោះលាន់ឮមកពីប្រភពទិសណាទេ ប្រុងស្មារតីចាំពិនិត្យស្ដាប់ទៅទៀត តែលែងឮអ្វីសោះ ។ ព្រឹកឡើង គ្មានប្រាប់អ្នកណាឲ្យដឹងឡើយ គាត់រៀបខ្លួនប្រាណប្រញាប់ប្រញាល់ទៅវត្ត ហើយចូលទៅថ្វាយបង្គំ រៀបរាប់ទូលតាមដំណើរដែលឮសូរស័ព្ទអស្ចារ្យពីយប់នោះដល់លោកគ្រូ ។ លោកគ្រូសញ្ជឹងមួយសន្ទុះ ក៏មានថេរដីកាថា មិនអីទេយាយ! កើតហើយ! យាយកើតធម៌ហើយ! យាយបានព្រះកកុសន្ធមួយព្រះអង្គហើយ សូមយាយប្រឹងប្រែងឲ្យពេញទំហឹងតទៅទៀតចុះ ។ យាយមាំត្រេកអរណាស់ នឹកឃើញថា ខ្លួនគាត់ធ្វើធម៌ឆាប់កើតណាស់ គាត់ថ្វាយ

បន្តុំហើយត្រឡប់ទៅវិញ ។

លុះដល់យប់ទីពីរ គាត់ក៏ចូលទៅអង្គុយប្រឹងស៊ីងស្មាធ៍នៅកន្លែងដដែលតាមរបៀបដូចពីយប់មុនទៀត ។ យប់នេះ ដល់ពេលជិតភ្លឺ សំឡេងដែលគាត់ឮពីយប់មុននោះបានលាន់ឡើងទៀត ប៉ុន្តែឮផ្ទួនគ្នាពីរដង គឺឮថា «ចៀប-ក្រុក! ចៀប-ក្រុក!» ។ យាយម៉ារឹតតែពិកាល់សង្ស័យខ្លាំងឡើង តែគាត់នៅតែលាក់លៀមទុក ចាំយកទៅបកធម៌ដូចពីថ្ងៃម្សិលទៀត ។ ព្រឹកនេះ លោកគ្រូព្រះធម៌ឃើញយាយមកថ្វាយបង្គំសុំបកធម៌តាមដំណើររឿងគាត់ទៀត លោកជញ្ជឹងបន្តិច ហើយមានថេរដីកាថា ល្អណាស់លោកយាយ! លោកយាយរៀនធម៌ចេះតែកើនចម្រើនទៅមុខ យាយបានព្រះកក្កុសន្ធោពីព្រះអង្គហើយ! ប្រឹងទៀតទៅ កុំរួញកបន្ធូរបន្ថយ ហើយបើឃើញយ៉ាងណាតទៅ សឹមប្រញាប់ប្រញាល់មកបកទៀតចុះ ។ យាយម៉ារឹតតែជោរចិត្តត្រេកអរពេកហួសឧបមា គាត់ញញឹមញញែមតែម្នាក់ឯងដោយនឹកឃើញថា ក្នុងជាតិនេះគាត់មានភ័ព្វ រៀនធ្វើសមណធម៌ជាប់បានណាស់ ។ គាត់ដើរក្តីអង្គុយដេកក្តី និយាយជាមួយនឹងគេក្តី ទឹកមុខគាត់ស្រស់ប៉ែប្រជានិច្ច [illegible] តែគាត់នឹងកូនចៅព្រមទាំងអ្នកជិតខាងកើតសង្ស័យ ហើយជួយអបអរផងដែរ

លុះដល់យប់ទីបី គាត់ចូលទៅអង្គុយធ្វើសមណធម៌នៅកន្លែងដដែល ដូចពីយប់មុនទៀត ។ ចម្លែកណាស់! អស្ចារ្យណាស់! យប់នេះ

គាត់គ្រាន់តែចូលទៅអង្គុយមួយសន្ទុះ សំឡេង «ចៀប-ក្រុក» ដូចពីមុនក៏លាន់ឡើងភ្លាម ចិត្តគាត់រឹងរឹតតែរំភើបអស្ចារ្យខ្លាំងឡើង ប្រឹងធ្វើតទៅទៀត មិនយូរប៉ុន្មានគាត់ឮទៀត គាត់ចេះតែឮយូរៗម្តងៗថា «ចៀប-ក្រុកៗ» ជាវៀងហូរហែរទៅ ៗ ដល់ពេលជិតភ្លឺស្រាប់តែសំឡេង «ចៀប-ក្រុក» លាន់ឡើងរំពងព្រមគ្នាច្រហឹងអឹងកាប់ ៗ យាយម៉ាភ្ញាក់ព្រើត សង្ស័យណាស់ ខំផ្ទៀងស្តាប់ទៅ ដូចព្រោកដជាឮខាងក្រោមខ្ទមគាត់ មិនអស់ចិត្ត ក៏បង្អើបកន្ទេលដែលក្រាលអង្គុយ ក្រោលក្លឹងមើលទៅក្រោមតាមចន្លោះនោះ ស្រាប់តែស្រងាកចិត្តដោយឃើញកូនមាន់មួយសំបុកមានមេកំពុងក្រាប ខ្លះនៅជាពង ខ្លះទៀតញាស់ហើយ ក៏ឃើញក្មេងក៏នាំគ្នាស្រែកថា ចៀបៗ ហើយមេវាក៏ស្រែកថា ក្រុកៗថែមម្តងទៀត ទឹកមុខយាយម៉ា ក៏ប្រែក្លាយទៅជាស្រពោនស្រប់មួយរំពេចហាក់ដូចជាទឹកស្តាយណាយទឹងការម្ហូរមៅក្តៅក្រហាយ គាត់អស់សំណើចតាំងមុខស្ងួតលាន់មាត់ទាំងទោមនស្សថា «នេះ បានជាតូកែបកធមិមែន» ៗ ព្រឹកឡើងគាត់ធ្វើទឹកមុខស្ងួ និយាយប្រាប់គានឹងកូនចៅទាំងអស់គ្នាថា អញឈប់ធ្វើសមណធម៌បែបនេះទៀតហើយ មើលទៅមិនស្រួលទេ!ៗ គានឹងកូនចៅក៏ភ័យក្រែងមានឧបសគ្គគ្រោះថ្នាក់យ៉ាងម៉េចៗ ក៏ប្រញាប់ផ្ទឹកសួរថា មិនស្រួលយ៉ាងម៉េច? យាយ ៗ យាយម៉ាទប់មិនបាន ក៏ញឹមៗនិយាយថាវាដែលមានខ្លួ? អញធ្វើទៅឮសំឡេងថា «ចៀប-ក្រុក» ប្រឹងលាក់យក

ទៅបកទឹងលោកអស់ពីព្រឹក លោកថា អញបានព្រះកក្កុសន្ធោ ១ អង្គ ២ អង្គហើយ តាឯងទៅមើលចុះ នៅខាងក្រោមកន្ទែងសមណធម៌ មិនអ្វីគឺសំបុកកូនមាន់សោះ បើយ៉ាងហ្នឹង តើវាយ៉ាងម៉េចទៅ ? ។ តាទីងកូនទៅចេញទឹកមុខចង់អស់សំណើចគ្រប់គ្នា ខ្វះណាទមាត់ថា ឱមែនហើយ សំបុកមាន់នោះ ខ្ញុំដាក់ឲ្យវាពងយូរហើយមិនបានជាតិតសោះ មើលទៅប្រហែលជាសំឡេង «ចៀប-ក្រុក» នោះ គឺកូនមាន់វាទម្លាយស្រោមពងចេញមកហើយយំព្ញថា «ចៀប» មេវាស្រែកទទួលថា «ក្រុក» ហ្នឹងហើយ ដល់យប់ក្រោយៗមក កូនមាន់វារឹតតែញាស់ច្រើនឡើងៗ បានជា «ចៀប ក្រុកព្រះកក្កុសន្ធោ» នោះ រឹតតែបានច្រើនឡើងហ្នឹងឯង ។ អ្នកចាំស្តាប់ក៏ផ្ទុះសំណើចគឹលឡើងទាំងអស់គ្នា នាំឲ្យយាយសើចទាំងខ្មាសជាមួយទីងគេដែរ ។ គាត់និយាយបញ្ចប់ធម៌យ៉ាងស្រងូតស្រងាត់ថា អញលែងទៅរៀនធ្វើសមណធម៌ទីងលោកគ្រូហ្នឹងទៀតហើយ ! ។

តាជួប គាត់ធ្លាប់ប្រកាន់ជំនឿក្នុងលោកគ្រូព្រះធម៌ដែរ គាត់ក៏ប្រែជាទទើរត់និត ដោយចេះតែរឭកឃើញព្រឹត្តិការណ៍ «ចៀប-ក្រុក ព្រះកក្កុសន្ធោ» នេះ ជារឿយ ៗ ។ ថ្ងៃមួយ គាត់ចូលបើកហិបយករបស់ផ្សេងៗ គាត់ក៏ទៅប៉ះសៀវភៅដែលទិញពីថ្ងៃមុន ។ ចិត្តគាត់ ស្រាប់តែចង់បើកសៀវភៅនោះសាកមើល ប៉ុន្តែចិត្តមួយទៀតកាំងកឲ្យភ័យខ្លាចឡើងៗ គាត់អង្គុយគិតម្នាក់ឯងមិនដាច់ស្រេចមួយសន្ទុះ ទីបំផុត គាត់ក៏សម្រេច

ចិត្តថា ត្រូវតែបើកសាកមើលម្ដងចុះ តើសៀវភៅហ្នឹងវាយ៉ាងម៉េចខ្លះ ៗ គាត់ប្រឹងស្មារតីយ៉ាងមាំ ដើម្បីកុំឲ្យត្រូវស្នេហ៍បាកាំង ទាញវ៉ែនមកពាក់ ធ្មេចភ្នែកយ៉ាងជិត បើកសៀវភៅជាស្រេច ទើបបើកភ្នែកខ្វាកធ្លុះមើលទៅ អក្សរ ៗ គាត់ប្រឹងសង្កេតពាក្យមួយ ៗ ដកបដិតអស់មួយទំព័រ ស្រាប់តែលាន់មាត់ថា ណ៎ា! ធម៌អញធ្លាប់ចេះហើយទេតើ ចុះអ្នកណាហ៊ានថាធម៌ថ្មីធម៌បាកាំងទៅវិញ! ៗ គាត់សំឡឹងទៅទៀត ឃើញអក្សរមានសណ្ឋានដូចជាគួយ័ន្ត ទឹកភ័យកើត តែលុះពិនិត្យមែនទែនទៅ ស្រាប់តែលាន់មាត់ទៀតថា ឲ! អក្សរតែមួយគូ គេគ្រាន់តែដាក់បន្ថបែរបុះបែរឡើងជាក្បាច់ក្បូរវិចិត្រសិល្បៈល្អមើលប៉ុណ្ណឹងទេតើ មានយ័ន្តដាក់ស្នេហ៍ដូចជាគេប្រាប់ឯណា! អើរុយ! ពាក្យមនុស្សវែងជាងផ្លូវមែន ៗ គាត់បើកត្រួស ៗ តាំងតែពីទំព័រខាងដើមរហូតដល់ចប់ ហើយស្ទុះក្រោកឡើងកាន់កាំងសៀវភៅចេកស្រេច ញញឹមញញែមដើរទៅរកយាយ ៗ យាយម៉ាឆាកមកឃើញដូចជាធ្លាក់ចិត្តកណ្ដុក នឹកឃើញថា « តាពិតជាត្រូវស្នេហ៍សៀវភៅហើយ » គាត់ស្រែកសួរទាំងភ័យថា វាយ៉ាងម៉េចទៅហើយតា! ៗ តាផ្ទួបស្រែកប្រាប់ថា យាយអើយ! យើងយល់ខុសទៅហើយ! សៀវភៅនេះមានធម៌បាកាំងឯណា! ធម៌ព្រះពុទ្ធដែលយើងធ្លាប់ចេះហើយគ្រប់គ្នាទេតើ! យាយមើលណ៎ះ នេះធម៌ថ្វាយបង្គំព្រះ នេះធម៌ស្មាទានសីល នេះធម៌ផ្សេង ៗ ទៀតច្រើនមុខណាស់ មានប្រែជាសម្រាយស្រេច យើង

គ្រាន់តែរៀនចាំ យើងអាចយល់ន័យបានសព្វគ្រប់ ៗ មិនតែប៉ុណ្ណោះ មានទាំងរបៀបរៀនធ្វើបរិកម្មការនៃសមណធម៌ លោកអ្នករៀបរៀងបាន ធ្វើបរិយាយយ៉ាងច្បាស់លាស់ផង មិនមែនឲ្យធ្វើស្មាន ៗ ដូចយាយឯង គ្រាន់តែឮសំឡេង «ចៀប–ក្រុក» ក៏បានព្រះកក្កុសន្ធោមួយព្រះអង្គនោះទេ ៗ យាយម៉ាញញឹម សុំឲ្យតាអានស្តាប់ គាត់ចាប់ចិត្តណាស់ លុះថ្ងៃបន្ទាប់មក គាត់លែងជឿអ្នកណាទៀតហើយ ប្រឹងរៀនតែតាមសៀវភៅគិហិប្បដិបត្តិនោះប៉ុណ្ណោះ ដោយឲ្យតាអានប្រាប់មួយម៉ាត់ ៗ លុះត្រាតែគាត់ទន្ទេញចាំ ទើបឲ្យតាអានប្រាប់តទៅទៀត បើមានពេលទំនេរ គាត់ឲ្យតាអានសៀវភៅនោះឲ្យស្តាប់សាចុះសាឡើងជាញឹកញយ គាត់បានយល់ច្រើន ហើយយូរមក តាជួបយាយម៉ាអាចសូត្រធម៌បានច្រើនជាងគេក្នុងភូមិនោះ ប៉ុន្តែព្រឹត្តិការណ៍ដែលគាត់បំភ្លេចចោលមិនបាននោះ គឺគាត់ចង់សើចរឿងខ្លួនឯង ដោយនឹកឃើញថា: ចៀប - ក្រាកា ព្រះកាក្កុសន្ធោ ៗ

– ចប់ –

# អំពីការតាំងមន្ត្រីសង្ឃ

កាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ ខុង-សាលី នាមឆាយា បរិបុណ្ណោ ព្រះជន្មបាន ២៤ ឆ្នាំ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តអម្ពខទិយារាម ឃុំតាមក្រសោប ស្រុកកោះកុង ខេត្តកោះកុង ។

កាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ សេង វឿង នាមឆាយា អមរោ ព្រះជន្មបាន ២២ ឆ្នាំ វស្សា ៣ ជាគ្រូសូត្រឆ្វេង វត្តអម្ពខទិយារាម ឃុំតាមក្រសោប ស្រុកកោះកុង ខេត្តកោះកុង ។

កាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ យី-ចិចា៉ នាមឆាយា សមាចារោ អាយុ ២៦ ឆ្នាំ វស្សា ៧ ជាគ្រូសូត្រស្តាំវត្តអម្ពវ័ន ឃុំតាមក្រសោប ស្រុកកោះកុង ខេត្តកោះកុង ។

កាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ ឈុំ-ឈៀ នាមឆាយា ធម្មទិន្នោ អាយុ ២១ ឆ្នាំ វស្សា ២ ជាគ្រូសូត្រឆ្វេង វត្តអម្ពវ័ន ឃុំតាមក្រសោប ស្រុកកោះកុង ខេត្តកោះកុង ។

កាលពីថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ អួង-ហ៊ឹម នាមឆាយា រក្ខិតោ អាយុ ២៦ ឆ្នាំ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តព្រៃមាស-សាគរ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ។

កាលពីថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ សេក-កោគ នាមឆាយា អគ្គបញ្ញោ អាយុ ២៥ ឆ្នាំ វស្សា ៥ ជាគ្រូសូត្រឆ្វេង

វត្តជ្រៃមាសសាគរ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ។

កាលពីថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ១៩៦៣ បានតាំងលោកគ្រូ ធី-ហ៊ាម នាមឆាយា មុនីកេសរ អាយុ ៣៨ ឆ្នាំ វស្សា ១៨ ជាគ្រូសូត្រស្ដាំវត្តសិរីជយមង្គល ឃុំគោហេ ស្រុកមុខកំពូល ខេត្តកណ្ដាល ។

កាលពីថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ សាន់-ឈាង នាមឆាយា ឥន្ទបញ្ញោ អាយុ ៣១ ឆ្នាំ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្តសិរីជយមង្គល ឃុំគោហេ ស្រុកមុខកំពូល ខេត្តកណ្ដាល ។

កាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ ខាត់-ម៉ុត នាមឆាយា មន្ទុត្តោ អាយុ ៤៣ ឆ្នាំ វស្សា ២២ ជាចៅអធិការវត្តអង្គត្រគៀត ឃុំកន្ទោក ស្រុកក្នុំពេញ ខេត្តកណ្ដាល ។

កាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ ហ៊ឹម-ប៉ែង នាមឆាយា ធម្មសុវណ្ណ អាយុ ៤៦ វស្សា ២៦ ជាចៅអធិការវត្តសុវណ្ណសនាកម ឃុំពោធិ៍ម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

កាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូក្វង-ហ៊ឹង នាមឆាយា ឥន្ទបញ្ញា អាយុ ៣៣ វស្សា ៩ ជាគ្រូសូត្រស្ដាំវត្តរុន ឃុំរុនតាឯក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

កាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ ឡូវ-ឯង នាមឆាយាសុវណ្ណជោតិ អាយុ ៣០ វស្សា ៩ ជាគ្រូសូត្រឆ្វេងវត្តរុន ឃុំរុនតាឯក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

កាលពីថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ សៀ-ជុង នាមឆាយា សទ្ធាសចារី អាយុ ២៩ ឆ្នាំ វស្សា ៨ ជាចៅអធិការវត្តសាលាម្នាង ឃុំត្រពាំង ស្រុកកំពង់សោម ខែត្រកោះកុង ។

កាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ ជា-ប៉ែត នាមឆាយា ឥន្ទុត្តោ អាយុ ៤៦ ឆ្នាំ វស្សា ២៦ ជាចៅអធិការវត្តសិរីវ័ន ឃុំត្រា ស្រុកសំរោង ខែត្រតាកែវ ។

កាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ ស-សាមឿន នាមឆាយា មុទីវេក អាយុ ២៨ ឆ្នាំ វស្សា ៤ ជាគ្រូសូត្រស្តាំ លោកគ្រូ ចេត-សុខ នាមឆាយា វិរិយបញ្ញោ អាយុ ២៤ ឆ្នាំ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្តសិរីវ័ន ឃុំត្រា ស្រុកសំរោង ខែត្រតាកែវ ។

កាលពីថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ សូ-ម៉ុម នាមឆាយា គុរុធម្មថេរ អាយុ ៧៧ ឆ្នាំ វស្សា ៥៦ ជាចៅអធិការ, លោកគ្រូ អ៊ុច-សេង នាមឆាយា សុវណ្ណថេរ អាយុ ៥៤ ឆ្នាំ វស្សា ១៩ ជាគ្រូសូត្រស្តាំ, លោកគ្រូ ទឹម-ម៉ាង នាមឆាយា ធម្មថេរ អាយុ ៥០ វស្សា ១ ជាគ្រូសូត្រឆ្វេងវត្តចំការខ្សាច់ ឃុំស្ពានថ្ម ស្រុកកណ្តាលស្ទឹង ខែត្រកណ្តាល ។

កាលពីថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៦៣ បានតាំងលោកគ្រូ ឈាង-ហុង នាមឆាយា សុវណ្ណត្តោ អាយុ ៣៣ វស្សា ១២ ជាចៅអធិការ, លោកគ្រូ ពុត-វង់ នាមឆាយា មុទិសត្តោ អាយុ ៣១ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តពោធិព្រឹក្ស ឃុំក្តៀងកយ ស្រុកកញ្ជៀច ខែត្រព្រៃវែង ។